30/March 2021

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

**សាលក្រមព្រហ្មទណ្ឌ**

-លេខ ១១១៨ "ល"

ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២១

-សំណុំរឿងព្រហ្មទណ្ឌលេខ ១៤៥១

ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០

-សំណុំរឿងស៊ើបសួរលេខ ១០៥៣

ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០២០

-សំណុំរឿងជំនុំជម្រះលេខ ៤៦៣៧

ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២០

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២០ វេលាព្រឹក, ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២០ វេលាព្រឹក និងល្ងាច និងថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២០ វេលាព្រឹក និងល្ងាច នៅសាលសវនាការទី០២ ដោយមានសមាសភាព៖

**ចៅក្រមជំនុំជម្រះ**

-លោកស្រី [redacted] ជាចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

**តំណាងអយ្យការ**

-លោក [redacted] ជាព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

-លោកស្រី [redacted] ជាក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ១៤៥១ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០ ដែលមាន៖

**-ជនជាប់ចោទ៖**

១-ឈ្មោះ [redacted]រតន៍ ភេទស្រី អាយុ ៣១ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរបេឡាករផ្នែកទទួលប្រាក់ពន្ធនៅស្នាក់ការកណ្ដាលធនាគារកាណាឌីយ៉ា អ.ក ទីកន្លែងកំណើតនៅសង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ទីលំនៅមុនពេលឃ[redacted] សង្កាត់ចោមចៅទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ[redacted] "រស់" ម្ដាយឈ្មោះ [redacted] "រស់" ប្ដីឈ្មោះ [redacted] "រស់" មានកូនចំនួន ០២នាក់ ទោសពីមុនគ្មាន ជាតិជន។

-ឃាត់ខ្លួន ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២០។

-ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ២៦១៤ "ណ" ដ.ឃ.ង ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២០។

-មានលោកមេធាវី [redacted] វិបុល និងលោកមេធាវី **ផុយ សុគន្ធ** ជាមេធាវីការពារសិទ្ធិឱ្យ។

២-ឈ្មោះ [redacted]បញ្ញាសុជាតា ភេទស្រី អាយុ ៣១ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរបុគ្គលិកនៅធនាគារវឌ្ឍនៈអាស៊ីចំកាត់ ទីកន្លែងកំណើតនៅសង្កាត់ផ្សារកណ្ដាលទី២ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទីលំនៅមុនពេលឃុំខ្លួន [redacted]ណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ឪពុកឈ្មោះ ឆុត ចិត្រា "រស់" ម្ដាយឈ្មោះ [redacted] "រស់" ប្ដីឈ្មោះ[redacted] "រស់" មានកូនចំនួន ០៣នាក់ ទោសពីមុនគ្មាន ជាតិជន។

-ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៩១៣១ "ណ" ដ.ឃ.ង ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២០។

-មានលោកមេធាវី [redacted]ចន្ថុល ជាមេធាវីការពារសិទ្ធិឱ្យ។



Scanned with CamScanner

៣-ឈ្មោះ [redacted] សុវណ្ណចរិយា ភេទស្រី អាយុ ៣០ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរមន្ត្រីជាន់ខ្ពស់ត្រួតពិនិត្យផ្នែកទទួលប្រាក់ពន្ធនៅស្នាក់ការកណ្ដាលធនាគារកាណាឌីយ៉ា អ.ក ទីកន្លែងកំណើតនៅភូមិក្បាលហុង ឃុំផ្ទះព្រៃ ស្រុកសំពៅមាស ខេត្តពោធិ៍សាត់ [redacted] សង្កាត់កាកាបទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "រស់" ម្ដាយឈ្មោះ [redacted] "ស្លាប់" ប្ដីឈ្មោះ [redacted] "រស់" មានកូនចំនួន ០២នាក់ ទោសពីមុនគ្មាន ជាទីតិជន។

-ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៩១៥៦ "ណា" ដ.ឃ.ដ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០២០។

-មានលោកមេធាវី [redacted] ប៊ុនកែវ ជាមេធាវីការពារសិទ្ធិឱ្យ។

៤-ឈ្មោះ [redacted] រចនា ភេទស្រី អាយុ ៣៩ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរអនុប្រធានប្រតិបត្តិការស្នាក់ការកណ្ដាលទទួលបន្ទុកផ្នែកទទួលប្រាក់ពន្ធ និងគម្រោងរដ្ឋាភិបាលនៅស្នាក់ការកណ្ដាលធនាគារកាណាឌីយ៉ា អ.ក ទីកន្លែងកំណើតនៅសង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ [redacted] ផ្លូវលេខ ៦១២ស្ទួន ភូមិ២០ សង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "ស្លាប់" ម្ដាយឈ្មោះ [redacted] "ស្លាប់" ប្ដីឈ្មោះ [redacted] "រស់" មានកូនចំនួន ០២នាក់ ទោសពីមុនគ្មាន ជាទីតិជន។

-ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៩១៣២ "ណា" ដ.ឃ.ដ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២០។

-មានលោកមេធាវី [redacted] ប៊ុនរ៉ា ជាមេធាវីការពារសិទ្ធិឱ្យ។

៥-ឈ្មោះ [redacted] សុឆាយ ភេទប្រុស អាយុ ៣១ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរមន្ត្រីជាន់ខ្ពស់ផ្នែកព័ត៌មានវិទ្យា (IT) និងជាប្រធានក្រុមប្រព័ន្ធស្នូលធនាគារនៅស្នាក់ការកណ្ដាលធនាគារកាណាឌីយ៉ា អ.ក ទីកន្លែងកំណើតនៅភូមិ០១ ឃុំកំពេញ ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ ទីលំនៅមុនពេលឃុំខ្លួន [redacted] ទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] រស់" ម្ដាយឈ្មោះ [redacted] "រស់" ប្រពន្ធឈ្មោះ [redacted] សុវណ្ណចរិយា "រស់" មានកូនចំនួន ០២នាក់ ទោសពីមុនគ្មាន ជាទីតិជន។

-ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៩១៥៧ "ណា" ដ.ឃ.ដ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០២០។

-មានលោកមេធាវី [redacted] ច័ន្ទប៊ុនកែវ ជាមេធាវីការពារសិទ្ធិឱ្យ។

ជនជាប់ចោទទាំង ០៥នាក់ជាប់ចោទពីបទ **រំលោភលើទំនុកចិត្តពិសេសដោយអភិបាល ឬបុគ្គលផ្សេងទៀត** ប្រព្រឹត្តនៅចំណុចស្នាក់ការកណ្ដាលធនាគារកាណាឌីយ៉ា អ.ក ផ្លូវព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីដើមខែមករា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩៣ នៃក្រមព្រហ្មទណ្ឌ។

៦-ឈ្មោះ [redacted] ហៀង ភេទប្រុស អាយុ ៤៣ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរបុគ្គលិកផ្នែកសន្តិសុខ និងបើកបររថយន្តនៅស្នាក់ការកណ្ដាលធនាគារកាណាឌីយ៉ា ក.អ ទីកន្លែងកំណើតនៅភូមិក្រាំងពង្រ ឃុំកុមាររាជា ស្រុកបាទី ខេត្តតាកែវ [redacted] សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "រស់" ម្ដាយឈ្មោះ [redacted] "រស់" ប្រពន្ធឈ្មោះ [redacted] រស់" មានកូនចំនួន ០២នាក់ ទោសពីមុនគ្មាន ជាទីតិជន។

-ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៩០១៤ "ណា" ដ.ឃ.ដ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២០។

-មានលោកមេធាវី [redacted] សម្បត្តិ, លោកមេធាវី [redacted] សុខនី និងលោកមេធាវី [redacted] ករកុលរ័ត្ន ជាមេធាវីការពារសិទ្ធិឱ្យ។

៧-ឈ្មោះ [redacted] ស៊ីមន្ថា ភេទប្រុស អាយុ ៣៩ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរមន្ត្រីនាយកដ្ឋានត្រួតពិនិត្យ និងវាយតម្លៃនៅក្រសួងមុខងារសាធារណៈ ទីកន្លែងកំណើតនៅសង្កាត់អូរឫស្សីទី៣ ក្រុងភ្នំពេញ ទីលំនៅមុនពេលឃុំខ្លួន



Scanned with CamScanner

[redacted] សង្កាត់ចោមចៅទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] “រស់” ម្តាយឈ្មោះ [redacted] “រស” ប្រពន្ធឈ្មោះ [redacted]វណ្ណនារីរតន៍ “រស់” មានកូនចំនួន ០២នាក់ ទោសពីមុនគ្មាន ជាទីតិជន។

-ឃាត់ខ្លួន ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២០។

-ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ២៦១៣ “ណ” ដ.ឃ.ដ ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០២០។

-ដីកាបង្គាប់ឱ្យដោះលែងលេខ ១០/២០ មអក ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០២០ របស់មហាអយ្យការអមតុលាការកំពូល។

-លិខិតដោះលែងលេខ ១៣៨៧ ពគ/២០ មអក ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០២០ របស់ពន្ធនាគាររាជធានីភ្នំពេញ។

-មានលោកមេធាវី[redacted]វិបុល និងលោកមេធាវី [redacted] សុគន្ធ ជាមេធាវីការពារសិទ្ធិឱ្យ។

ជាប់ចោទទាំង ០២នាក់ជាប់ចោទពីបទ **សមគំនិតក្នុងអំពើរំលោភលើទំនុកចិត្តពិសេសដោយអភិបាល ឬបុគ្គលផ្សេងទៀត** ប្រព្រឹត្តនៅចំណុចស្នាក់ការកណ្តាលធនាគារកាណាឌីយ៉ា អ.ក ផ្លូវព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីដើមខែមករា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៩ និងមាត្រា ៣៩៣ នៃក្រមព្រហ្មទណ្ឌ។

**-ដើមបណ្តឹងរដ្ឋប្បវេណី និងជាជនរងគ្រោះ ធនាគារកាណាឌីយ៉ា ក.អ** (CANADIA BANK PLC.) មានអាសយដ្ឋានស្ថិតនៅអគារលេខ ៣១៥ វិថីព្រះអង្គឌួងកែងនឹងមហាវិថីព្រះមុនីវង្ស សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ដែលមានលោក [redacted] **ឆារស័** ជាអគ្គនាយករងប្រតិបត្តិធនាគារកាណាឌីយ៉ា អ.ក ជាអ្នកតំណាង។

-មានលោកមេធាវី [redacted]ហេង, លោកមេធាវី [redacted]រតនា, លោកមេធាវី [redacted]បុរមុនី, លោកស្រីមេធាវី [redacted]កនិកា, លោកមេធាវី [redacted] ផានិត ជាមេធាវីតំណាងឱ្យ។

## អង្គហេតុនៃរឿងមានដូចតទៅ

មុនពេលកើតហេតុឈ្មោះ [redacted] **វណ្ណនារីរតន៍** ជាបុគ្គលិកនៅស្នាក់ការកណ្តាលធនាគារកាណាឌីយ៉ា ក.អ ទទួលបន្ទុកផ្នែកបង់ប្រាក់ពន្ធជូនរដ្ឋពីអតិថិជនតាមរយៈការវេរចូលគណនីរបស់អគ្គនាយកដ្ឋានពន្ធដារ ហើយក្នុងរយៈពេលដែលបានទទួលតួនាទីនេះឈ្មោះ [redacted] **វណ្ណនារីរតន៍** បានធ្វើសកម្មភាពគៃបំបាត់ប្រាក់របស់ធនាគារកាណាឌីយ៉ា ក.អ ជាច្រើនលើក។ នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២០ ឈ្មោះ[redacted]**វណ្ណនារីរតន៍** បានធ្វើសកម្មភាពទៀត ដោយយកប្រាក់ចេញពីធនាគារកាណាឌីយ៉ា ក.អ ចំនួន ៦,១៦០,០០០$ (ប្រាំមួយលានដប់ប្រាំមួយម៉ឺនដុល្លាអាមេរិក) ច្រកក្នុងថង់ខ្មៅចំនួន ៣ ថង់ ហើយបានហៅឈ្មោះ[redacted]**បញ្ញាសុជាតា** ដែលជាអតីតបុគ្គលិកធនាគារកាណាឌីយ៉ា ក.អ មកជួយនាំសន្តិសុខ ៣ នាក់ជញ្ជូនប្រាក់ទាំងនេះពីជាន់ផ្ទាល់ដីឡើងទៅជាន់ទី៥ នៃអគារស្នាក់ការកណ្តាលធនាគារកាណាឌីយ៉ា អ.ក រួចរង់ចាំនៅជាន់ទី៥ ប្រហែលកន្លះម៉ោងទើបឈ្មោះ[redacted] **ស៊ីមន្ថា** ជាប្តីរបស់ឈ្មោះ [redacted] **វណ្ណនារីរតន៍** មកដល់ រួចជញ្ជូនថង់ប្រាក់ទាំងនេះដាក់ក្នុងរថយន្ត ហើយដឹកចេញទៅបាត់។ ក្នុងការប្រព្រឹត្តិរបស់ឈ្មោះ [redacted] **វណ្ណនារីរតន៍** នេះមានការសម្រួលសម្រួលពីឈ្មោះ[redacted]ហៀង ជាសន្តិសុខ និងជាអ្នកបើកបររថយន្តនៅស្នាក់ការកណ្តាលធនាគារកាណាឌីយ៉ា អ.ក ផងដែរ ដោយឈ្មោះ [redacted]ហៀង នេះបានជួយលីថង់ប្រាក់ពីជាន់ផ្ទាល់ដីទៅកាន់ជាន់ទី៥ នៃអគារកណ្តាលធនាគារកាណាឌីយ៉ា អ.ក។ រីឯឈ្មោះ [redacted]**សុវណ្ណចរិយា** និងឈ្មោះ [redacted]**រចនា** ជាបុគ្គលិកមានតួនាទីត្រួតពិនិត្យការងាររបស់ឈ្មោះ [redacted] វណ្ណនារីរតន៍ ដោយផ្ទាល់នោះបានឃុបឃិតគ្នាមិនរាយការណ៍ជូនថ្នាក់គ្រប់គ្រងធនាគារឡើយ ដោយឈ្មោះ [redacted]



Scanned with CamScanner

សុវណ្ណចរិយា បានទទួលប្រាក់ពីឈ្មោះ [redacted] **វឌ្ឍនទារីរតន៍** រួចយកទុកក្នុងថតតុរបស់ខ្លួន រហូតដល់ចប់ម៉ោងធ្វើការក៏យកប្រាក់នេះដាក់ចូលកាបូបរបស់ខ្លួន រួចចេញទៅផ្ទះដោយមានឈ្មោះ [redacted] **ស៊ីមន្ថា** ជាប្តីបានមកទទួល។ ក្នុងការប្រព្រឹត្តនេះឈ្មោះ [redacted] **បញ្ញាសុជាតា** ជាអ្នកសហការប្រព្រឹត្តយ៉ាងសកម្ម និងជាអ្នកយកប្រាក់ដុល្លារអាមេរិកដែលឈ្មោះ [redacted] **វឌ្ឍនទារីរតន៍** បានកិបកេងបានសម្រេចនោះទៅប្តូរជាប្រាក់រៀលវិញ។ លុះដល់ថ្ងៃទី២៤ ខែមករា ឆ្នាំ២០២០ ខាងធនាគារកាណាឌីយ៉ា អ.ក បានស្រាវជ្រាវរកឃើញថាឈ្មោះ [redacted] **វឌ្ឍនទារីរតន៍** បានកែបំបាត់ប្រាក់របស់ធនាគារកាណាឌីយ៉ា អ.ក ជាច្រើនលើក ទើបខាងធនាគារដាក់ពាក្យបណ្តឹងអ្នកទាំង ០២នាក់ប្តីប្រពន្ធខាងលើ ហើយសមត្ថកិច្ចបានឃាត់ខ្លួនអ្នកទាំង ០២ និងកសាងសំណុំរឿងបញ្ជូនមកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដើម្បីចាត់ការតាមនីតិវិធី និងបានប្តឹងបត្តឹងបញ្ជូនមក...

-បានឃើញរបាយការណ៍សំយោគលេខ ១០/២០២០ រ.ប.ក ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០ របស់នាយកដ្ឋាននគរបាលព្រហ្មទណ្ឌកម្រិតធ្ងន់ នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ១១៧៦ អ.យ.ប ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២០ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ៤៤៤២ អ.យ.ប ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២០ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះលេខ ៥៥៦៨ “ណ” ង.ង ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] **វឌ្ឍនទារីរតន៍** បានឆ្លើយថា៖ ខ្លួនធ្វើការនៅក្នុងធនាគារកាណាឌីយ៉ាប្រហែលជាឆ្នាំ ២០១៥, ឆ្នាំ២០១៦ រហូតដល់បច្ចុប្បន្ន។ តាំងពីដើមមកខ្លួនធ្វើការមានតួនាទីជាបេឡាផ្នែកបង់ពន្ធ។ ពេលអតិថិជនយកប្រាក់មកបង់ពន្ធខ្លួនមានតួនាទីទទួលប្រាក់ពីអតិថិជន រាប់ប្រាក់ បញ្ចូលទិន្នន័យនៅក្នុងប្រព័ន្ធពន្ធដារ និងប្រព័ន្ធធនាគារ ហើយពិនិត្យ និងចេញបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធឱ្យអតិថិជន នៅពេលដែលគ្រប់ចំនួនហើយក្នុងមួយថ្ងៃខ្លួនរាប់ និងបូកបញ្ចូលនៅពេលល្ងាច។ ការទទួលប្រាក់ពន្ធ ០១ថ្ងៃ ត្រូវផ្ទៀងផ្ទាត់ ០១ថ្ងៃ នៅពេលផ្ទៀងផ្ទាត់ខ្លួនរាប់ឱ្យត្រូវជាមួយទិន្នន័យក្នុងបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធ និងប្រាក់ឱ្យត្រូវគ្នា ទើបយកប្រាក់ចូលឃ្លាំង។ នៅពេលអតិថិជនយកប្រាក់មកបង់មានជាប្រាក់ដុល្លារ និងប្រាក់រៀល តែទិន្នន័យនៅក្នុងប្រព័ន្ធចុះជាប្រាក់ខ្មែរ ហើយបើអតិថិជនយកប្រាក់ដុល្លារមកខ្លួនត្រូវយកប្រាក់នោះទៅប្តូរជារៀលវិញ មិនមែនយកប្រាក់សុទ្ធទៅប្តូរផ្ទាល់ទេ ប្តូរតាមប្រព័ន្ធ ដូរតាមក្រដាស ផេរទៅផេរមកតែប៉ុណ្ណោះ។ អ្នកដែលមានសិទ្ធិចេញបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធ គឺខ្លួន និងបុគ្គលិកនៅក្នុងក្រុមបង់ពន្ធទាំងអស់។ ចំពោះទម្រង់បង្កាន់ដៃបង់ពន្ធ គឺខាងពន្ធដារគេជាអ្នកដាក់ឱ្យមក ដោយបង្កាន់ដៃនោះមានឈ្មោះថា “បង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធ”។ ហើយបង្កាន់ដៃនោះ ខ្លួនអាចចុះហត្ថលេខាទុកដោយសារតែអតិថិជនច្រើន ហើយការចុះហត្ថលេខាទុកមានការឯកភាពពីធនាគារ។ បង្កាន់ដៃនេះមាន ០៣ពណ៌ គឺពណ៌ស ពណ៌លឿង និងពណ៌ផ្កាឈូក អតិថិជនយកទៅប្រកាសនៅពន្ធដារ ពេលប្រកាសរួច ពណ៌សពន្ធដារយកទុក ពណ៌ផ្កាឈូកឱ្យអតិថិជន ចំណែកពណ៌លឿងរក្សាទុកនៅ

ក្នុងធនាគារ។ បើអតិថិជនយកប្រាក់ដុល្លារមក គឺខ្លួនចេញបង្កាន់ដៃប្តូរប្រាក់ឱ្យទៅអតិថិជន បង្កាន់ដៃនេះមាន ០៣ពណ៌ គឺពណ៌ស ពណ៌ផ្កាឈូក និងពណ៌ខៀវ ហើយឱ្យអតិថិជនតែពណ៌ផ្កាឈូកទេ ចំណែកពណ៌ស និងពណ៌ខៀវ រក្សាទុកនៅធនាគារ។ ក្រៅពីនេះ គឺមិនមានចេញអ្វីផ្សេងទៀតទេ។ បន្ទាប់ពីបញ្ចូលទឹកប្រាក់ និងទិន្នន័យចូលក្នុងប្រព័ន្ធពន្ធដាររួច ហើយទើបខ្លួនចេញបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធឱ្យអតិថិជន ហើយប្រព័ន្ធពន្ធដារនោះ គឺទូទៅថ្នាក់លើក៏អាចមើលបានដែរ គឺមានឈ្មោះ [redacted] រចនា ,ឈ្មោះ [redacted] សុវណ្ណរចនា និងឈ្មោះ [redacted] សុធារី ដែលគាត់ជាមេខ្លួន ហើយគាត់ជាអ្នកព្រីនឯកសារយកមកឱ្យខ្លួនមើលផ្ទៀងផ្ទាត់ក្នុងមួយថ្ងៃ ០២ដង ពេលថ្ងៃត្រង់ និងពេលល្ងាច ដើម្បីផ្ទៀងផ្ទាត់ប្រាក់ដែលទទួល និងឯកសារជាក់ស្តែងដែលមាននៅនឹងខ្លួន។ នៅពេលយកប្រាក់ពីអតិថិជនថ្នាក់លើខ្លួនដឹងទាំងអស់ ហើយរាល់ពេលចេញឯកសារឱ្យអតិថិជនត្រូវតែបញ្ចូលប្រាក់នៅក្នុងប្រព័ន្ធពន្ធដារ និងប្រព័ន្ធធនាគារ ក្នុងករណីដែលខ្លួនមិនបញ្ចូល គឺថ្នាក់លើត្រូវតែដឹងទាំងអស់។ ការងាររបស់ឈ្មោះ [redacted] រចនា និងឈ្មោះ [redacted] សុវណ្ណចរិយា គឺគាត់មើលលើខ្លួន ដោយប្រាក់ពន្ធក្រោម ៨,០០០,០០០៛ (ប្រាំបីលានរៀល) ចុះ ខ្លួនអាចចេញបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធ និងបញ្ចូលទិន្នន័យក្នុងប្រព័ន្ធពន្ធដារ និងប្រព័ន្ធធនាគារបានដោយខ្លួនឯង។ តែបើប្រាក់ពន្ធចាប់ពី ៨,០០០,០០០៛ (ប្រាំបីលានរៀល) ឡើងទៅ ខ្លួនទទួលត្រូវយកទៅឱ្យនរណាម្នាក់ក្នុងចំណោមឈ្មោះ [redacted] សុវណ្ណចរិយា និងឈ្មោះ [redacted] រចនា មើលពីលើថាឯកសារដែលខ្លួនចេញ និងប្រាក់ទទួលត្រូវគ្នាឬអត់ គឺខ្លួនកាន់ប្រាក់ជាក់ស្តែងទៅឱ្យពួកគេពិនិត្យទាំងប្រាក់ និងលិខិតទាល់តែពួកគាត់ថាត្រឹមត្រូវទើបខ្លួនចេញឯកសារឱ្យអតិថិជនបាន គឺទាល់តែគាត់អនុញ្ញាតឱ្យចេញបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធបានចេញបាន។ កន្លងមកខ្លួនធ្លាប់យកតែប្រាក់ ៦លានដុល្លាអាមេរិកជាង ទៅប្តូរឱ្យអតិថិជន តែខ្លួនមិនចាំថ្ងៃខែណាទេ។ ចំពោះបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធលេខ ០០៤០៤៥៨៣៨ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០២០ មានទឹកប្រាក់ ២៤,៣៦៨,៦៣២,១៤៧៛ (ម្ភៃបួនពាន់បីរយហុកសិបប្រាំបីលានប្រាំមួយរយសាមសិបពីរពាន់មួយរយសែសិបប្រាំពីររៀល) និងលេខ ០០៤០៤៥៨៣៩ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០២០ មានទឹកប្រាក់ ៣៨៨,០៣៦,៥២៧៛ (បីរយប៉ែតសិបប្រាំបីលានសាមសិបប្រាំមួយពាន់ប្រាំរយម្ភៃប្រាំពីររៀល) ខ្លួនមិនបានកិបកេងប្រាក់របស់ធនាគារនេះទេ ខ្លួនទទួលស្គាល់ថាខ្លួនពិតជាបានយកប្រាក់ ៦លានដុល្លាអាមេរិកជាងនេះយកទៅប្តូរ គោលបំណងដើម្បីចំណេញក្បាលកាក់ប៉ុណ្ណោះ ហើយប្រាក់ទាំងនោះ គឺខ្លួនបានយកដាក់នៅក្នុងប្រព័ន្ធពន្ធដារ និងធនាគារសងវិញរួចហើយ គឺសងក្រោយពេលធនាគារដឹងរឿងហើយ ពីព្រោះពន្ធដារបានចេញលិខិតមកថាយឺតប្រាក់ពន្ធគេ។ ខាងធនាគារមិនអនុញ្ញាតឱ្យបុគ្គលិកយកប្រាក់ចេញទៅខាងក្រៅនោះទេ។ ចំពោះប្រាក់ ៦លានដុល្លាអាមេរិកជាងនោះ គឺអតិថិជនឱ្យខ្លួនយកទៅប្តូរឱ្យ ដោយគាត់មិនបានប្រាប់ថា ឱ្យខ្លួនយកទៅប្តូរនៅក្រៅធនាគារនោះទេ គឺខ្លួនយកប្រាក់នោះទៅប្តូរខ្លួនឯង។ ចំពោះប្រាក់ចំណេញពីការប្តូរខ្លួនមិនចាំ តែខ្លួនបានឆ្លើយនៅចៅក្រមស៊ើបសួររួចហើយ ដោយខ្លួនរក្សាចម្លើយដែលឆ្លើយ ០៣ដំណាក់កាលមុនដដែល។ មូលហេតុដែលខ្លួនមិនបានយកប្រាក់ប្តូររួចយកទៅដាក់បញ្ចូលធនាគារវិញភ្លាមៗ ដោយសារពេលខ្លួនយកទៅប្តូរខាងក្រុមហ៊ុនប្តូរប្រាក់ លី ហួរ មានប្រាក់មិនគ្រប់ ហើយនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២០ ខ្លួនធ្វើការតែពេលព្រឹកមួយពេល ពីព្រោះ

ជាថ្ងៃសៅរ៍ និងស្អែកឡើងថ្ងៃអាទិត្យមិនអាចយកទៅដាក់បញ្ចូលបាន ម្យ៉ាងខ្លួនក៏មានរវល់កម្មវិធីឡើងផ្ទះ និងមានដំណើរកំសាន្តទៅក្រៅប្រទេសរយៈពេល ១១ថ្ងៃ ទើបខ្លួនខកខានមិនបានដាក់ឱ្យខាងធនាគារវិញ។ ខ្លួនចេញទៅក្រៅប្រទេសមិនចាំថ្ងៃទេ តែពេលមកវិញ គឺនៅថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២០។ បង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធលេខ ០០៤០៤៥៨៣៨ និងលេខ ០០៤០៤៥៨៣៩ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០២០ គឺខ្លួនជាអ្នកចុះហត្ថលេខា និងជាអ្នកចេញជូនអតិថិជនក្រុមហ៊ុនគ័ន ហ្គ័ង ខនស្ត្រាក់សិន (ខេមបូឌា) ឯ.ក។ ចំពោះប្រាក់ដែលទទួលតាមបង្កាន់ដៃទាំង ០២នេះឈ្មោះ [redacted] សុវណ្ណចរិយា និងឈ្មោះ [redacted] រចនា អត់ដឹងទេ ដោយពេលនោះអតិថិជនច្រើន និងចុងម៉ោងទើបគាត់អត់ដឹង។ ខ្លួនហ៊ានអះអាងថាអ្នកទាំង ០២អត់ដឹង ដោយសារបើគាត់ដឹង គឺគាត់ត្រូវសួរខ្លួនហើយ។ ខ្លួនបានជួបអតិថិជននៅបន្ទប់ទទួលភ្ញៀវជាន់ទី៥ ដើម្បីទទួលប្រាក់នោះ មូលហេតុដែលខ្លួនមិនទទួលប្រាក់នៅកន្លែងបង់ពន្ធដោយសារប្រាក់ច្រើន។ ប្រាក់នោះអតិថិជនបានដាក់ក្នុងថង់ខ្មៅចំនួន ០៣មកស្រាប់ ដូចនៅក្នុងឯកសាររូបថត ១៦/៦៨ ដោយអតិថិជនពាក់អាវពណ៌ស ក្រោយពេលបានប្រាក់ពីអតិថិជនហើយ គឺខ្លួនយកចេញទៅខាងក្រោម ហើយប្រាក់នេះខ្លួនបានបញ្ចូលទិន្នន័យទៅក្នុងប្រព័ន្ធពន្ធដាររួចហើយទើបខ្លួនចេញបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធទាំង ០២ខាងលើឱ្យអតិថិជន។ ខ្លួនបានពឹងឈ្មោះ [redacted] បញ្ញាសុជាតា ឱ្យមកជួយមើលប្រាក់នោះឱ្យ គាត់ជាអតីតបុគ្គលិកផ្នែកបង់ពន្ធនៅធនាគារកាណាឌីយ៉ា អ.ក។ ខ្លួនមិនចាំថាខ្លួនទូរស័ព្ទហៅឈ្មោះ [redacted] បញ្ញាសុជាតា មុនពេលទទួលបានប្រាក់ ឬក្រោយពេលទទួលប្រាក់នោះទេ។ ខ្លួនទូរស័ព្ទហៅឈ្មោះ [redacted] បញ្ញាសុជាតា ឱ្យមកជួយមើលប្រាក់ខ្លាចមានអ្នកយក។ ចំពោះសន្តិសុខគាត់គ្រាន់តែជួយយកអីវ៉ាន់ធម្មតាក្នុងនាមសន្តិសុខ ហើយខ្លួនក៏មិនបានហៅគាត់ឱ្យជួយយួរដែរ។ ចំពោះប្រាក់នោះខ្លួនឱ្យឈ្មោះ [redacted] បញ្ញាសុជាតា ទុក និងអង្គុយចាំនៅជាន់ទី៥ ចាំប្តីខ្លួនមកយកដាក់ឡាន ពេលប្តីខ្លួនយកដាក់ក្នុងឡានហើយ ឈ្មោះ [redacted] បញ្ញាសុជាតា ចេញទៅវិញ។ ក្រោយពេលដាក់ប្រាក់នៅក្នុងឡាន ប្តីខ្លួនមិនបានសួរថា យកប្រាក់ទៅប្តូរ ឬធ្វើអ្វីនោះទេ ពីព្រោះគាត់មិនជ្រៀតជ្រែកការងារខ្លួនទេ។ ប្រាក់នោះខ្លួនទុកនៅក្នុងឡានរហូត ហើយឡាននោះមិនបានយកទៅណាទេ គឺចតនៅក្នុងផ្ទះរហូត ពីព្រោះខ្លាចបាត់ប្រាក់។ ឈ្មោះ [redacted] បញ្ញាសុជាតា ក្រៅពីជួយមើលប្រាក់ គឺខ្លួនមិនបានឱ្យទៅគាត់ធ្វើអ្វីផ្សេងទៀតទេ។ ខ្លួនបានពឹងឱ្យឈ្មោះ [redacted] បញ្ញាសុជាតា ជួយប្តូរប្រាក់ជាង ៦លានដុល្លាអាមេរិកនោះឱ្យខ្លួន ពីព្រោះខ្លួននៅក្រៅប្រទេស។ ប្តូរប៉ុន្មានដងម្តងប៉ុន្មាន ខ្លួនមិនដឹងទេ។ មូលហេតុដែលម្តាយខ្លួនទៅប្តូរប្រាក់ជាមួយឈ្មោះ [redacted] បញ្ញាសុជាតា ដោយសារឈ្មោះ [redacted] បញ្ញាសុជាតា មិនព្រមមកយកនៅផ្ទះខ្លួន។ អំឡុងពេលខ្លួននៅក្រៅប្រទេស ខ្លួនបានវេរប្រាក់ឱ្យឈ្មោះ [redacted] បញ្ញាសុជាតា ទៅគណនី ABA របស់គាត់ចំនួន ២០០,០០០$ (ម្ភៃម៉ឺនដុល្លាអាមេរិក) ចំនួន ០២ដង ប្រាក់នេះ គឺជាប្រាក់ដែលក្រុមហ៊ុនគ័ន ហ្គ័ង ខនស្ត្រាក់សិន (ខេមបូឌា) ឯ.ក យកមកបង់ពន្ធ ដើម្បីឱ្យឈ្មោះ [redacted] បញ្ញាសុជាតា ប្តូរយកទៅបង់ពន្ធឱ្យអតិថិជនវិញ ចំពោះការជួយខ្លួននេះឈ្មោះ [redacted] បញ្ញាសុជាតា មិនបានទទួលអ្វីពីខ្លួនទេ ខ្លួនមិនបានឱ្យប្រាក់អ្វីទៅគាត់ទេ គាត់គ្រាន់តែជួយខ្លួនដោយមនោសញ្ចេតនា។ ចំពោះប្រាក់ ៥៣០,០០០$ (ហាសិបបីម៉ឺនដុល្លាអាមេរិក) គឺជាប្រាក់នៅក្នុងទឹកប្រាក់ ៦លានដុល្លាអាមេរិកជាងដែលខ្លួនយកទៅប្តូរ មិនមែនប្រាក់ផ្សេងទេ។ ខ្លួនមិនដែលខ្ចីប្រាក់ពីឈ្មោះ [redacted] សុវណ្ណ

ចរិយា និងឈ្មោះ [redacted]រចនា ទេ ហើយខ្លួនក៏មិនដែលខ្ចីប្រាក់ពីឈ្មោះ[redacted]សុផាយ ដែរ។ ចំពោះរូបភាពខ្លួនហុចប្រាក់ទៅឱ្យឈ្មោះ[redacted]សុវណ្ណចរិយា និងឈ្មោះ [redacted]រចនា គឺជាប្រាក់ដែលគេយកមកបង់ពន្ធ ពីព្រោះប្រាក់ចាប់ពី ៨,០០០,០០០៛ (ប្រាំបីលានរៀល) ឡើងទៅត្រូវយកឱ្យពួកគាត់ពិនិត្យ និងអនុញ្ញាតឱ្យបញ្ចូលក្នុងប្រព័ន្ធ។ ឈ្មោះ[redacted]សុវណ្ណចរិយា គាត់មានតួនាទីជាអ្នក Checker។ ឈ្មោះ[redacted]រចនា មានតួនាទីជា BM។ តួនាទីពួកគាត់ប្រចាំថ្ងៃ គឺត្រួតពិនិត្យមើលទាំងប្រាក់ និងបង្កាន់បញ្ជាក់ការបង់ប្រាក់ពន្ធ។ នៅថ្ងៃដែលខ្លួនយកប្រាក់ទៅក្រៅធនាគារនោះ គឺឈ្មោះ[redacted]សុវណ្ណចរិយា គាត់ជាអ្នកត្រួតពិនិត្យជាមួយឈ្មោះ[redacted]រចនា ពីព្រោះពួកគាត់មកធ្វើការរាល់ថ្ងៃ។ កន្លងមកខ្លួនធ្លាប់លក់អីវ៉ាន់តាមអនឡាញ ហើយឈ្មោះ[redacted] សុវណ្ណចរិយា ក៏ធ្លាប់ទិញអីវ៉ាន់ពីខ្លួនដែរ ហើយប្រាក់ដែលនៅក្នុងកាមេរ៉ាសុវត្ថិភាព គឺខ្លួនមិនដឹងជាប្រាក់អ្វីទេ។ ប្រាក់ ៦លានដុល្លារអាមេរិកជាងនោះ ខ្លួនមិនបានបញ្ចូលទៅក្នុងប្រព័ន្ធធនាគារ ទើបឈ្មោះ [redacted] សុវណ្ណចរិយា និងឈ្មោះ[redacted]រចនា មិនដឹង។ ការបញ្ចូលទិន្នន័យក្នុងប្រព័ន្ធពន្ធដារ និងធនាគារ មិនពាក់ព័ន្ធនឹងផ្នែកព័ត៌មានវិទ្យាទេ។ បង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធអាចព្រីនចេញជូនអតិថិជនបាន បន្ទាប់ពីខ្លួនបញ្ចូលប្រាក់ និងទិន្នន័យចូលក្នុងប្រព័ន្ធពន្ធដាររួចរាល់ហើយ។ ឈ្មោះ[redacted]ហៀង ខ្លួនទើបស្គាល់ក្នុងឋានៈគាត់ជាសន្តិសុខធនាគារ ហើយទំនាក់ទំនងខ្លួននឹងគាត់គ្រាន់តែជាបុគ្គលិក និងសន្តិសុខ និងធ្លាប់ពឹងគាត់ឱ្យទិញបាយទឹកឱ្យហូប។ នៅថ្ងៃដែលខ្លួនឱ្យគាត់ជញ្ជូនថង់ខ្មៅ គឺគាត់មិនដឹងថាជាអ្វីទេ ហើយខ្លួនក៏មិនប្រាប់គាត់ដែរ ហើយគាត់ជួយយកអីវ៉ាន់ខ្លួនដោយសារក្នុងនាមសន្តិសុខ។ ប្រាក់ពន្ធដែលទទួលបានពីអតិថិជន គឺខ្លួនទុកនៅក្នុងថតតុរបស់ខ្លួនកន្លែងធ្វើការ។ ហើយមូលហេតុដែលប្រាក់ជាង ៦លានដុល្លារអាមេរិក ខ្លួនមិនយកចូលក្នុងបន្ទប់ធ្វើការបែរជាទទួលនៅក្នុងបន្ទប់ទទួលភ្ញៀវ វីអាយភី ពីព្រោះបើយកចូលកន្លែងធ្វើការខ្លួនមិនអាចយកទៅប្តូរចំណេញនោះទេ។ ហើយនៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២០ នោះ ខ្លួនមិនបានទាក់ទងប្តីខ្លួនឱ្យមកយកខ្លួនទេ គឺប្តីខ្លួនឈ្មោះ [redacted] ស៊ីមន្ថា គាត់បានមកយកខ្លួនចេញពីធ្វើការពេលដែលគាត់ទំនេរ។ នៅម៉ោង៩ និង ១៣នាទី ថ្ងៃទី១៨ ខែមករា ឆ្នាំ២០២០ ឈ្មោះ[redacted]បញ្ញាសុជាតា បានមកដល់ធនាគារកាណាឌីយ៉ា អ.ក ហើយគាត់ និងឈ្មោះ[redacted] ហៀង បានយកប្រាក់ថង់ខ្មៅយកទៅទុកនៅជាន់ទី៥។ ថ្ងៃទី១៨ ខែមករា ឆ្នាំ២០២០ គឺមានថង់ខ្មៅមួយនៅក្រោមជើងខ្លួនតែមិនមែនជាប្រាក់ដែលក្រុមហ៊ុន ត័ន ហ្គ័ង ខនស្ត្រាក់សិន (ខេមបូឌា) ឯ.ក យកមកបង់ពន្ធនោះទេ ខ្លួនមិនបានឱ្យប្រាក់ថង់ខ្មៅនេះទៅឈ្មោះ[redacted]ហៀង នោះទេ។ រូបថតឯកសារលេខ ៧៧/៣ គឺជារូបខ្លួនឱ្យឈ្មោះ[redacted]ហៀង យកប្រាក់ទៅប្តូរយកជាប្រាក់យ៉ូរ៉ូ ពីព្រោះខ្លួនត្រូវទៅដើរលេងនៅក្រៅប្រទេស។ ឈ្មោះ [redacted]សុផាយ ខ្លួនគ្រាន់តែស្គាល់គាត់ជាបុគ្គលិកធនាគារជាមួយគ្នា ហើយគាត់ចេញចូលបន្ទប់បង់ពន្ធក្នុងម៉ោងធ្វើការ ខ្លួនអត់ដឹងទេ គាត់មកជួបប្រពន្ធគាត់ឈ្មោះ [redacted] សុវណ្ណចរិយា រឿងអ្វីខ្លួនមិនដឹងទេ។ ឈ្មោះ[redacted] ហៀង ចូលមកក្នុងការិយាល័យបង់ពន្ធតាមរបៀបណាខ្លួនមិនដឹងទេ។ មូលហេតុដែលខ្លួនដាក់ប្រាក់សងធនាគារវិញច្រើនលើកដោយសារតែខាងក្រុមហ៊ុន លី ហួរ ប្តូរប្រាក់ អត់ប្រាក់ប្តូរឱ្យ។ រាល់ប្រព្រឹត្តការណ៍ប្តូរប្រាក់អតិថិជនដាក់ចូលទៅក្នុងប្រព័ន្ធធនាគារវិញ គឺប្តូរជាមូលប្បទានប័ត្រសិន ហើយបានដាក់ចូលប្រព័ន្ធពន្ធដារ និងធនាគារតែម្តង។ សូមបញ្ជាក់ថាបើប្រាក់ពន្ធចាប់ពី ៨,០០០,០០០៛ (ប្រាំបីលានរៀល) ឡើងទៅ



Scanned with CamScanner

លុះត្រាតែមានការអនុញ្ញាតពីថ្នាក់លើខ្លួនឈ្មោះ [redacted]រចនា និងឈ្មោះ [redacted]សុវណ្ណចរិយា ឱ្យចេញទើបខ្លួនអាចចេញបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធឱ្យអតិថិជនបាន ជាដំបូងខ្លួនត្រូវយកបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធ និងប្រាក់ពន្ធយកទៅជូនពួកគាត់ពិនិត្យ ដោយពួកគាត់ពិនិត្យមើលផ្ទៀងផ្ទាត់ថាប្រាក់ដែលទទួល ទឹកប្រាក់ដែលពួកខ្លួនបញ្ចូលក្នុងប្រព័ន្ធគណនីពន្ធដារ និងឯកសារបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធត្រូវគ្នា ឬអត់ បើត្រឹមត្រូវទើបពួកគាត់ឱ្យពួកខ្លួនចេញបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធឱ្យអតិថិជន។ ថ្នាក់លើរបស់ខ្លួនគាត់ត្រួតពិនិត្យក្នុងប្រព័ន្ធកុំព្យូទ័រ តែបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធគាត់មិនបានមើលទេ ពួកគាត់មើលតែលើបង្កាន់ដៃតូចមួយដែលខ្លួនប្រើសម្រាប់បញ្ចូលប្រាក់ប៉ុណ្ណោះ។ បង្កាន់ដៃដែលចេញឱ្យអតិថិជនក្រុមហ៊ុន គ័ន ហ្គ័ង ខនស្ត្រាក់សិន (ខេម បូឌា) ឯ.ក បើខ្លួនបញ្ចូលប្រាក់ក្នុងប្រព័ន្ធធនាគារថ្នាក់លើខ្លួនគាត់នឹងដឹង តែបើមិនបញ្ចូលថ្នាក់លើអាចមិនដឹង ពីព្រោះខ្លួនមិនបានរាប់ប្រាក់នៅក្នុងការិយាល័យបង់ពន្ធ នៅពេលចុងម៉ោងខ្លួនមិនដឹងថាគាត់បានឆែកបង្កាន់បញ្ជាក់ការបង់ប្រាក់ពន្ធទាំង ០២ដែលខ្លួនចេញឱ្យក្រុមហ៊ុន គ័ន ហ្គ័ង ខនស្ត្រាក់សិន (ខេមបូឌា) ឯ.ក ឬអត់ទេ។ ប៉ុន្តែខ្លួនមិនបានដឹងទេថានៅក្នុងថង់ខ្មៅ ៣ថង់នោះជាប្រាក់ រហូតដល់ពេលខ្លួនយកប្រាក់នេះចុះដល់ខាងក្រោមដាក់ក្នុងឡាន ទើបដឹងនៅពេលខ្លួនប្រាប់គាត់ថាជាប្រាក់របស់អតិថិជនបង់ពន្ធត្រូវយកទៅប្តូរនៅក្រុមហ៊ុន លី ហួរ ប្តូរប្រាក់។ ប្រាក់នោះខ្លួនដាក់ក្នុងឡានរហូត ពីព្រោះខ្លាចបាត់ ហើយខ្លួនមិនដាក់ចូលក្នុងបន្ទប់ដោយសារខ្លាចអ្នកផ្ទះដឹង។ ពេលប្តូរប្រសិនបើបានចំណេញខ្លួនទុកសម្រាប់ខ្លួនឯងទាំងអស់ មិនបានចែកឱ្យនរណាទេ។ ឈ្មោះ [redacted]សុភាយ គាត់មិនដឹងរឿងខ្លួនយកប្រាក់ចេញទេ។ នៅថ្ងៃគេបង់ពន្ធនោះ ខ្លួនមិនចាំថាឈ្មោះ [redacted]រចនា និងឈ្មោះ [redacted]សុវណ្ណចរិយា នៅ ឬអត់ទេ ខ្លួនភ្លេចបាត់ហើយ។ ប្រព័ន្ធរបស់ពន្ធដារ គឺភ្ជាប់គ្នាជាមួយប្រព័ន្ធធនាគារ អ៊ីចឹងពេលខ្លួនព្រីនបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធឱ្យអតិថិជន មានន័យថាប្រាក់គេបានដាក់ចូលក្នុងប្រព័ន្ធធនគារហើយ។ ការផ្ទៀងផ្ទាត់ប្រាក់ គឺមិនមែនត្រូវតែមើលក្នុងប្រព័ន្ធទេ គាត់ក៏ត្រូវតែរាប់ដែរ ហើយត្រូវពិនិត្យមើលប្រាក់ជាក់ស្តែងទៀងផង ពីព្រោះបើប្រាក់បាត់ ឬប្រាក់រហែក គឺពួកខ្លួនជាអ្នកទទួលត្រូវសង អ៊ីចឹងត្រូវឱ្យគាត់ផ្ទៀងផ្ទាត់ឡើងវិញ។ ខាងពន្ធដារ គឺបានទទួលប្រាក់តែជាតួលេខទេ ចំណែកប្រាក់សុទ្ធ គឺពួកខ្លួនជាអ្នករក្សាទុក ហើយពេលបិទប្រព័ន្ធប្រចាំថ្ងៃឈ្មោះ[redacted]សុវណ្ណចរិយា និងឈ្មោះ [redacted]រចនា ត្រូវប្រមូលបង្កាន់ដៃទៅផ្ទៀងផ្ទាត់បន្ថែមទៀត។ ពេលទទួលប្រាក់ដុល្លារពីក្រុមហ៊ុន គ័ន ហ្គ័ង ខនស្ត្រាក់សិន (ខេមបូឌា) ឯ.ក ខ្លួនមិនបានបញ្ចូលប្រាក់នោះចូលទៅក្នុងប្រព័ន្ធធនាគារទេ ដល់ពេលប្តូរទៅជាមូលប្បទានប័ត្រប្រាក់រៀលហើយ និងពេលខាងពន្ធដារដឹងបាត់ប្រាក់ ទើបខ្លួនយកមូលប្បទានប័ត្រប្រាក់រៀលទៅបញ្ចូលក្នុងប្រព័ន្ធធនាគារ។ ខ្លួនមិនចាំថា ថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២០ ខ្លួនបានធ្វើប្រតិបត្តិការបង់ពន្ធសងចូលក្នុងប្រព័ន្ធធនាគារវិញនោះទេ។ នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២០ នោះ ខ្លួនបានចេញបង្កាន់ដៃប្តូរប្រាក់០១ និងបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធ០១ ឱ្យក្រុមហ៊ុន គ័ន ហ្គ័ង ខនស្ត្រាក់សិន (ខេមបូឌា) ឯ.ក ដើម្បីបញ្ជាក់ថា បានទទួលប្រាក់ជាង ៦លានដុល្លាអាមេរិកពីក្រុមហ៊ុនគាត់។ នៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០២០ ឈ្មោះ[redacted]រចនា បានទូរស័ព្ទមកប្រាប់ខ្លួនតាមប្រព័ន្ធហ្វេសប៊ុកថា មានការបាត់ប្រាក់ ៦លានដុល្លាអាមេរិក ពីព្រោះខាងពន្ធដារគេប្រាប់មក ហើយខ្លួនក៏មិនបាននិយាយអ្វីតបវិញដែរ ពីព្រោះពេល



Scanned with CamScanner

នោះខ្លួននៅប្រទេសក្រៅបាត់ទំនាក់ទំនង ក្រោយមកខ្លួនមកជួបខាងធនាគារតែម្តង។ ពេលឈ្មោះ[redacted]រចនា ទូរស័ព្ទមកខ្លួនប្រាប់ពីការបាត់ប្រាក់នោះ ខ្លួនមិនបាននិយាយអង្វរគាត់ ហើយខ្លួនក៏អត់បាននិយាយឆ្លើយឆ្លងទៅគាត់ដែរ ខ្លួនគ្រាន់តែបាននិយាយថា "ចាំគិតមើលសិន" ដោយសារខ្លួននៅក្រៅប្រទេស ហើយប្រាក់មិននៅជាប់នឹងខ្លួន។ **នៅថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០២០ ទើបខ្លួនផ្ញើសារប្រាប់ឈ្មោះ[redacted] រចនា ថាខ្លួនបានយកប្រាក់ដាក់សងហើយ។ ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២០** ខ្លួនបានទៅធនាគារ ហើយធនាគារបញ្ជូនខ្លួនឱ្យធ្វើការចាត់ចែងបញ្ចូលសងធនាគារវិញ ទើបថ្ងៃនោះខ្លួនបានឱ្យភ្នាក់ងារក្រុមហ៊ុន លី ហួរ ប្តូរប្រាក់ យកមូលប្បទានប័ត្រចំនួន ០៣សន្លឹកទៅដាក់ចូលក្នុងប្រព័ន្ធធនាគារ **ដើម្បីបន្ថែមឱ្យគ្រប់ចំនួន**ដែលខ្លួនបានយក អ្នកណាជាអ្នកបញ្ចូលប្រាក់នោះក្នុងប្រព័ន្ធធនាគារខ្លួនមិនដឹង។ ថ្ងៃនោះឈ្មោះ [redacted] **សុវណ្ណចរិយា** មកធ្វើការអត់ខ្លួនមិនដឹង។ **ខ្លួនធ្លាប់បានខ្ចីប្រាក់ឈ្មោះ[redacted]ចនា** តែមិនចាំទេថាពេលណា ហើយចំនួនប្រហែល ៥០០$ (ប្រាំរយដុល្លារអាមេរិក) ទៅ ១,០០០$ (មួយពាន់ដុល្លារអាមេរិក) ហើយនៅដើមខែមករា ឆ្នាំ២០២០ **ខ្លួនមិនចាំថាធ្លាប់ខ្ចីប្រាក់ពី**ឈ្មោះ [redacted]ចនា ឬអត់ទេ។ ប្រាក់ខ្លួនខ្ចីសងគាត់អស់ហើយ។ ខ្លួនមាឝគំនិតយកប្រាក់ ៦លានដុល្លារអាមេរិកជាងទៅក្រៅនៅពេលអតិថិជនមកបង់ ហើយមិនបានរៀបគម្រោងទុកមុនទេ ហើយខ្លួនមិនចាំថាខ្លួនបានឱ្យប្រាក់ទៅសន្តិសុខ ឬអត់នោះទេ នៅថ្ងៃដែលគាត់ជួយយកឥវ៉ាន់ថង់ខ្មៅទាំង ០៣នោះ។ ប្តីខ្លួនមិនស្គាល់ឈ្មោះ[redacted]**បញ្ញាសុជាតា** ទេ។ ចំពោះឈ្មោះ[redacted]**បញ្ញាសុជាតា** ប្រហែលជាស្គាល់ប្តីខ្លួន ពីព្រោះខ្លួនធ្លាប់ទៅចូលរួមមង្គលការមេខ្លួនជាមួយប្តីរបស់ខ្លួន។ ខ្លួនមិនបានខ្ចីប្រាក់ពីឈ្មោ[redacted]**សុឆាយ** ទេ ហើយម្តាយខ្លួនក៏មិនបានឈឺដែរ។

-ជនជាប់ចោទឈ្មោះ[redacted]**ស៊ីមន្ថា** បានឆ្លើយថា៖ ពេលសមត្ថកិច្ចឃាត់ខ្លួន ខ្លួនធ្វើការនៅក្រសួងមុខងារសាធារណៈ បានប្រាក់ខែសរុបមួយខែប្រហែលជា ៥,០០០,០០០៛ (ប្រាំលានរៀល)។ ខ្លួនត្រូវជាប្តីរបស់ឈ្មោះ[redacted] **វណ្ណនទារីរតន៍**។ **ថ្ងៃទី១៨ ខែមករា ឆ្នាំ២០២០** ខ្លួនបានទៅយកប្រពន្ធនៅធនាគារកាណាឌីយ៉ា អ.ក ចន្លោះម៉ោង ១០ និងម៉ោង ១១ថ្ងៃត្រង់ ហើយថ្ងៃនោះប្រពន្ធខ្លួនជាអ្នកទូរស័ព្ទហៅ ហើយជាទម្លាប់ខ្លួន គឺទៅយកប្រពន្ធរហូត។ នៅពេលខ្លួនមកដល់ធនាគារកាណាឌីយ៉ា អ.ក ខ្លួនក៏បានទូរស័ព្ទហៅប្រពន្ធ ហើយប្រពន្ធរបស់ខ្លួនបានឱ្យខ្លួនជួយយកអីវ៉ាន់ថង់ខ្មៅចំនួន ០៣នៅខាងលើ ហើយពេលនោះប្រពន្ធខ្លួនមិនបានប្រាប់ថាអីវ៉ាន់អីទេ ក្រោយពេលជិះឡានទៅផ្ទះទើបប្រពន្ធខ្លួនបានប្រាប់ថាប្រាក់បង់ពន្ធយកទៅប្តូរ តែមិនបានប្រាប់ថាចំនួនប៉ុន្មានទេ ហើយខ្លួនក៏មិនបានសួរនាំអីទៀតដែរ ពីព្រោះនេះជាការងាររបស់គាត់។ ខ្លួនទៅយកប្រាក់ថង់ខ្មៅទាំង ០៣នោះតែម្នាក់ឯង ថង់ខ្មៅនោះគេទុកនៅក្នុងបន្ទប់មួយចុងក្រោយគេនៃជាន់ទី៥ ហើយខ្លួនឃើញមានមនុស្សស្រីម្នាក់អង្គុយនៅក្នុងបន្ទប់នោះ តែខ្លួនមិនស្គាល់គាត់ និងមិនធ្លាប់ជួបគាត់ទេ ហើយពេលនេះបើឃើញមុខក៏មិនចាំដែរ ខ្លួនមិនបាននិយាយជាមួយមនុស្សស្រីម្នាក់នោះទេ ប្រពន្ធរបស់ខ្លួនក៏បាននៅក្នុងបន្ទប់ដាក់ថង់ខ្មៅនោះដែរ ខ្លួនមិនបានជួបសន្តិសុខទេ។ ខ្លួនជញ្ជូនថង់ខ្មៅទាំង ០៣នោះចេញមកម្តងមួយៗតែម្នាក់ឯង យកទៅដាក់នៅក្នុងឡានរបស់ខ្លួន ហើយយកទៅផ្ទះដោយទុកក្នុងឡានដដែល ហើយការចាត់ចែងប្រាក់យ៉ាងម៉េចខ្លួនមិនដឹងដែរ ពីព្រោះប្រពន្ធខ្លួនជាអ្នកចាត់ចែង។ ខ្លួនមិនបានយកឡាននោះជិះទៅធ្វើការទេ គឺទុកនៅផ្ទះរហូត។ ពេលយកប្រាក់ទៅប្តូរខ្លួនមិនដឹងទេ។ ខ្លួនទៅប្រទេសអឺរ៉ុបនៅថ្ងៃទី២៦ ខែមករា ឆ្នាំ២០២០ មកវិញថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២០ ទៅ ០២នាក់

ប្រពន្ធ។ ប្រាក់នៅក្នុងគណនីប្រាក់ខែខ្លួនមានចំនួន ៤០,០០០,០០០៛ (សែសិបលានរៀល) ក្នុងគណនីធនាគារ ABA មាន ប្រហែល ១០,០០០$ (មួយម៉ឺនដុល្លារអាមេរិក) ជាង ប្រាក់ទាំងនោះជាប្រាក់ចំណូលពីប្រាក់ខែ និងរបរដែលខ្លួនបានរកស៊ីនៅក្រៅ។ ខ្លួនដឹងថាក្នុងថង់ខ្មៅទាំង ០៣នោះ គឺជាប្រាក់នៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២០។ ពេលខ្លួនទៅយកប្រពន្ធនៅធនាគារកាណាឌីយ៉ា អ.ក គឺខ្លួនចតឡាននៅចំហៀងកាច់ជ្រុងធនាគារកាណាឌីយ៉ា អ.ក គឺខាងធនាគារវឌ្ឍនៈ មិនមែននៅពីក្រោយធនាគារកាណាឌីយ៉ា អ.ក ទេ។ កន្លងមកថ្ងៃផ្សេងៗប្រពន្ធខ្លួនមិនដែលបានឱ្យយកប្រាក់ទៅណាទេ ហើយក៏មិនដែលឱ្យទៅយកពីធនាគារដែរ នេះជាលើកទី១។ មូលហេតុខ្លួនទៅយកប្រពន្ធមុនពេលដល់ម៉ោងចេញទៅផ្ទះ ដោយសារតែផ្ទះខ្លួនឆ្ងាយ។ ខ្លួនបានយកថង់ខ្មៅចំនួន ០៣នោះ ចុះតាមជណ្តើរយន្តខាងក្រោយ ហើយក្រោយពេលដែលជញ្ជូនថង់ខ្មៅទាំង ០៣រួច ខ្លួនបានចាំប្រពន្ធខ្លួននៅខាងក្រោយធនាគារនៅក្នុងរថយន្តខ្លួន។ ក្រៅពីថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០ ខ្លួនក៏ធ្លាប់ចូលទៅក្នុងធនាគារកាណាឌីយ៉ា អ.ក ដើម្បីរង់ចាំប្រពន្ធខ្លួននៅកន្លែងបញ្ជរបង់ពន្ធ។ ខ្លួនមិនស្គាល់ឈ្មោះ [redacted] បញ្ញាសុជាតា, ឈ្មោះ [redacted]ថនា, ឈ្មោះ [redacted] សុភាយ និងឈ្មោះ [redacted]ហៀង ទេ។ ខ្លួនមិនបានយកឡានទៅប្រើប្រាស់ ដោយសារប្រពន្ធទុកប្រាក់ក្នុងថង់ខ្មៅទាំង ០៣នៅក្នុងឡាននោះ ខ្លួនមិនដឹងថាប្រពន្ធចាត់ចែងប្រាក់នោះយ៉ាងម៉េចទេ។ ខ្លួនមិនដឹងថាយកប្រាក់ទៅប្តូរនៅពេលណាទេ។ ពេលទៅប្រទេសគេខ្លួនមិនដឹងថាប្រាក់នោះទុកនៅកន្លែងណាទេ ប្រហែលទុកនៅក្នុងឡានដដែល។ នៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២០ ខាងធនាគារកាណាឌីយ៉ា អ.ក បានហៅខ្លួនទៅធនាគារយកប្រពន្ធខ្លួន។ ពេលខ្លួនលើកថង់ខ្មៅទាំង ០៣ ចុះក្រោម ខ្លួនបានជួបប្រពន្ធខ្លួននៅមាត់ជណ្តើរយន្ត ហើយគាត់បានប្រាប់ខ្លួនឱ្យចុះទៅមុន គាត់ទៅបម្រើការងារសិន។ ខ្លួនមិនធ្លាប់ចូលកន្លែងបង់ពន្ធដែលជាការិយាល័យប្រពន្ធខ្លួនទេ។

-ជនជាប់ចោទឈ្មោះ [redacted] សុភាយ បានឆ្លើយថា៖ ខ្លួនធ្វើការងារផ្នែកព័ត៌មានវិទ្យា (IT) នៅក្នុងធនាគារកាណាឌីយ៉ា អ.ក តាំងពីឆ្នាំ ២០១២ មានតួនាទីជួយសម្របសម្រួលឱ្យបុគ្គលិកដែលគាត់មានបញ្ហាផ្នែកព័ត៌មានវិទ្យា ផ្តល់យោបល់ជូនធនាគារទៅលើផ្នែកព័ត៌មានវិទ្យា និងជាអ្នកគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យា ទទួលបានប្រាក់ខែ ៧៥០$ (ប្រាំពីររយហាសិបដុល្លារអាមេរិក) ក្នុងមួយខែ ខ្លួនបានឡើងជាប្រធានផ្នែកកាលពីឆ្នាំ២០១៧។ ប្រពន្ធខ្លួនឈ្មោះ[redacted]សុវណ្ណចរិយា ជាបុគ្គលិកផ្នែកទទួលប្រាក់ពន្ធ ជាមន្ត្រីផ្នែកត្រួតពិនិត្យ តែខ្លួនមិនបានដឹងថាគាត់មានតួនាទីត្រួតពិនិត្យអ្វីខ្លះនោះទេ ហើយប្រពន្ធខ្លួនក៏មិនដែលនិយាយអំពីការងាររបស់គាត់ប្រាប់ខ្លួនដែរ គាត់ជា Checker ជាអ្នកត្រួតពិនិត្យសកម្មភាពថ្នាក់ក្រោមគាត់ផ្នែកបង់ពន្ធ។ ខ្លួនមិនស្គាល់ឈ្មោះ [redacted]ស៊ីមន្ថា ទេ ចំណែកឯឈ្មោះ [redacted]វឌ្ឍនទារីរតន៍ គាត់ជាមន្ត្រីផ្នែកទទួលប្រាក់បង់ពន្ធ តែខ្លួនមិនដឹងថាគាត់ជាមន្ត្រីកម្រិតណានោះទេ ហើយស្ថិតក្រោមការពិនិត្យរបស់ប្រពន្ធខ្លួន ឬអត់ទេ។ ខ្លួនស្គាល់ឈ្មោះ [redacted] រថនា ជាមេរបស់ប្រពន្ធខ្លួន ហើយគាត់ជាអនុប្រធានផ្នែកបង់ពន្ធ តែមិនដឹងថាការងារធ្វើអ្វីខ្លះទេ។ ចំណែកឈ្មោះ [redacted]ហៀង ខ្លួនស្គាល់ គាត់ជាសន្តិសុខធនាគារកាណាឌីយ៉ា អ.ក។ ខ្លួនមិនបានចូលរួមគិបកេងប្រាក់ធនាគារកាណាឌីយ៉ា អ.ក នោះទេ ហើយប្រពន្ធខ្លួនដឹង ឬអត់ក៏ខ្លួនមិនដឹងដែរ ហើយពេលឈ្មោះ[redacted]វឌ្ឍនទារីរតន៍ យកប្រាក់ក៏ខ្លួនមិនដឹងដែរ។ ចំណែកឯឈ្មោះ [redacted]ញ្ញាសុជាតា ខ្លួនមិនស្គាល់ទេ។ នៅថ្ងៃដែលឈ្មោះ [redacted] វឌ្ឍនទារីរតន៍ ត្រូវចាប់ខ្លួន ទើបខ្លួនដឹងថាគាត់យកប្រាក់ធនាគារកាណាឌីយ៉ា អ.ក តែខ្លួនមិនចាំថ្ងៃណាទេ។ ប្រាក់នៅក្នុងគណនីធនាគាររបស់ខ្លួនជាប្រាក់របស់ម្តាយខ្លួនលក់ដីបាននៅខេត្តព្រះសីហនុ នៅឆ្នាំ២០១៧ ក្នុងតម្លៃ ៩០០,០០០$ (កៅសិបម៉ឺនដុល្លារអាមេ



Scanned with CamScanner

រិក) ម្ដាយខ្លួនបានឱ្យខ្លួនយកទៅដាក់ក្នុងគណនីធនាគារ ដើម្បីយកការប្រាក់។ ខ្លួនមិនមានសិទ្ធិលុបទិន្នន័យដែលបាន
បញ្ចូលក្នុងប្រព័ន្ធរួចហើយនោះទេ។ នៅថ្ងៃទី០៨ ខែមករា ឆ្នាំ២០២០ ឈ្មោះ[redacted] **វណ្ណនារីរតន៍** មិនបានខលមកខ្លួនទេ។
ហើយនៅពេលគេមកសវនកម្ម គឺខ្លួនគ្រាន់តែដឹងថាប្រាក់បាត់ តែមិនដឹងចំនួនដែលបាត់នោះទេ។ បើប្រាក់បាត់នៅក្នុង
ប្រព័ន្ធធនាគារខ្លួនអាចដឹង ហើយចំពោះប្រតិបត្តិការណ៍នៅក្នុងប្រព័ន្ធធនាគារមិនអាចលុបបាននោះទេ តែបើប្រាក់បាត់មិន
មានបញ្ចូលទិន្នន័យនៅក្នុងប្រព័ន្ធធនាគារខ្លួនមិនអាចដឹងទេ។ ហើយលុះណាគេទូរស័ព្ទសុំឱ្យឆែកទើបខ្លួនបានឆែក នៅ
ពេលឆែកខ្លួនអាចដឹងថាប្រាក់គ្រប់ ឬអត់។ ខ្លួនមិនមានសិទ្ធិលុប ឬបង្កើតកម្មវិធីណាមួយក្នុងប្រព័ន្ធធនាគារទេ។ ខ្លួន
ស្គាល់ឈ្មោះ[redacted] **វណ្ណនារីរតន៍** ក្នុងលក្ខណៈបុគ្គលិក ហើយនៅឆ្នាំ២០១៧ ខ្លួនធ្លាប់ឱ្យឈ្មោះ[redacted] **វណ្ណនារីរតន៍** ខ្ចី
ប្រាក់ ដោយគាត់ប្រាប់ថាម្ដាយរបស់គាត់ឈឺ តែខ្លួនមិនចាំថាចំនួនប៉ុន្មាននោះទេ ហើយក៏មិនបានយកការប្រាក់ពីគាត់ដែរ
ប្រាក់នោះគាត់បានសងខ្លួនវិញអស់ហើយ។ ឈ្មោះ[redacted] **ស៊ីមន្ថា** ខ្លួនមិនស្គាល់ទេ។ ខ្លួនធ្លាប់ទៅដើរលេងនៅសិង្ហបុរី
ជាមួយឈ្មោះ[redacted] **ស៊ីមន្ថា** និងប្រពន្ធគាត់ តែខ្លួនមិនដឹងថាពួកគាត់ទិញកញ្ចប់ទេសចរណ៍ជាមួយគ្នាទេ។ ឈ្មោះ[redacted]
**បញ្ញាសុជាតា** ខ្លួនស្គាល់គាត់ជាអតីតបុគ្គលិកធនាគារកាណាឌីយ៉ា អ.ក។ ខ្លួនចូលការិយាល័យបង់ពន្ធរបស់ប្រពន្ធខ្លួនមិន
ញ៊ុកញាប់ទេ ហើយខ្លួនទៅ គឺដើម្បីសង្កេតការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យា (IT) ដោយខ្លួនគ្រាន់តែឈរពីក្រោយពួកគាត់
មើល ហើយក្រៅពីទៅសង្កេតការងារ ខ្លួនមិនបានទៅធ្វើអ្វីផ្សេងទេ ហើយពេលខ្លះខ្លួនទៅជាន់ទី៥ ដើម្បីចាំប្រពន្ធខ្លួនទៅ
ហូបបាយ។ ខ្លួនធ្លាប់ទៅអង្គុយកន្លែងគាត់ញ៊ុកញាប់ពេលណាមិនចាំទេ។ ប្រពន្ធខ្លួនមិនបានទទួលប្រាក់ចំនួន ១២០,០០០$
(ដប់ពីរម៉ឺនដុល្លារអាមេរិក) ជាងពីឈ្មោះ[redacted] **វណ្ណនារីរតន៍** ទេ។ ចំពោះប្រាក់ និងការប្រាក់ ១២៨,៥០០$ (ដប់ពីរម៉ឺន
ប្រាំបីពាន់ប្រាំរយដុល្លារអាមេរិក) ដែលប្រពន្ធខ្លួនថាឈ្មោះ[redacted] **វណ្ណនារីរតន៍** ជំពាក់នោះ ដំបូងខ្លួនមិនដឹងទេ ទាល់តែ
ធនាគារឃាត់ខ្លួនទើបប្រពន្ធខ្លួនប្រាប់។ ពេលធនាគារឃាត់ខ្លួន ប្រពន្ធខ្លួនបានប្រាប់ថាប្រាក់ចំនួន ១២៨,៥០០$ (ដប់ពីរម៉ឺន
ប្រាំបីពាន់ប្រាំរយដុល្លារអាមេរិក) នេះ ធនាគារសួរគាត់រឿងខ្ចីប្រាក់គាត់ក៏ប្រាប់ធនាគារថាគាត់ចងការប្រាក់ឱ្យឈ្មោះ[redacted]
**វណ្ណនារីរតន៍** តែ ០២ខែ ទៅ ០៣ខែទេ។ ខ្លួនមានសិទ្ធិចេញចូលសេរីនៅក្នុងបន្ទប់ធ្វើការរបស់ប្រពន្ធខ្លួន ពេលខ្លះខ្លួនចូល
យកកាហ្វេឱ្យប្រពន្ធខ្លួន និងទៅសួរសុខទុក្ខប្រពន្ធខ្លួន ពេលខ្លះក៏ទៅសម្របសម្រួល រឺសង្កេតការ។ ខ្លួនគ្រាន់តែជាអ្នកផ្ដល់
យោបល់ឱ្យគេធ្វើតាម តែពេលមានបញ្ហា គឺមានអ្នកផ្សេងជាអ្នកដោះស្រាយ។ ការផ្ទេរសាច់ប្រាក់ក្នុងគណនីរបស់ប្រពន្ធ
ខ្លួនមកខ្លួន គឺជាប្រាក់ដែលគេសងម្ដាយខ្លួន ហើយខ្លួនឱ្យប្រពន្ធខ្លួនជួយយកទៅដាក់ក្នុងគណនីខ្លួន តែគាត់បែរជាយកទៅ
ដាក់ចូលក្នុងគណនីរបស់គាត់ ហើយបានគាត់ផ្ទេរចូលគណនីសន្សំរបស់ខ្លួនទៅវិញ ដោយប្រពន្ធខ្លួនធ្វើប្រតិបត្តិការផ្ទេរ
ប្រហែល ០២ដង ខ្លួនមិនចាំថាប្រាក់ប៉ុន្មានទេ។

-ជនជាប់ចោទឈ្មោះ[redacted]បញ្ញាសុជាតា បានឆ្លើយថា៖ នៅអំឡុងដើមខែមករា ឆ្នាំ២០២០ ខ្លួនមិនបានចូលរួម
សហការយកប្រាក់នៅធនាគារកាណាឌីយ៉ា អ.ក ជាមួយពួកគាត់ទេ។ ខ្លួនបានចូលធ្វើការនៅធនាគារកាណាឌីយ៉ា អ.ក
កាលពីខែកញ្ញា ឆ្នាំ២០១០ រហូតដល់ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨ ក្រោយមកក៏បានឈប់ ហើយទៅធ្វើការនៅធនាគារវឌ្ឍនៈ

អាស៊ីចំកាត់ មានមុខងារខាងទទួលកាត នៅឆ្នាំ២០១៨។ ខ្លួនធ្វើការនៅធនាគារកាណាឌីយ៉ា អ.ក ឆ្លងកាត់ ០៣តំណែង ទី០១. ជាបុគ្គលិកផ្នែកកាត ទី២.ជាបុគ្គលិកផ្នែកបេឡាបង់ពន្ធ មានតួនាទីទទួលប្រាក់ពីអតិថិជន ហើយចេញបង្កាន់ដៃបញ្ជាក់ ការបង់ប្រាក់ពន្ធជូនអតិថិជន ពីឆ្នាំ២០១៣ រហូតដល់ដើមឆ្នាំ២០១៧ ទទួលបានប្រាក់ខែ ៤៥០$ (បួនរយដុល្លាអាមេរិក) ទី០៣. ពីឆ្នាំ២០១៧ ដល់ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨ ជាបុគ្គលិកជំនាញផ្នែកប្រតិបត្តិការណ៍។ ខ្លួនស្គាល់ឈ្មោះ[redacted] ឈ្មោះ[redacted] វណ្ណនារីរតន៍, ឈ្មោះ[redacted] សុវណ្ណចរិយា, ឈ្មោះ[redacted] ហៀង, ប្តីរបស់ឈ្មោះ[redacted] វណ្ណនារីរតន៍ តែមិនជិតស្និត និងឈ្មោះ[redacted] សុភាយ។ ចំពោះឈ្មោះ[redacted] ស៊ីមន្ថា ខ្លួនជួបគាត់ប្រហែលបានជា ០២ដងក្នុងឆ្នាំ២០១៩-២០២០ នៅក្នុងកម្មវិធីឡើងផ្ទះគាត់។ ខ្លួនគ្រាន់តែជួបមុខគ្នា ឈ្មោះ [redacted] ស៊ីមន្ថា គាត់មិនដែលហៅខ្លួនទេ គាត់ស្គាល់ខ្លួនពេលគាត់ទៅយកប្រពន្ធគាត់ ទើបគាត់ធ្លាប់ឃើញខ្លួននៅកន្លែងបង់ពន្ធ។ ខ្លួនមិនបានយកប្រាក់ធនាគារទេ គ្រាន់តែថ្ងៃទី១៨ ខែមករា ឆ្នាំ២០២០ វេលាម៉ោង ០៩ព្រឹក ឈ្មោះ[redacted] វណ្ណនារីរតន៍ បានទូរស័ព្ទប្រាប់ខ្លួនឱ្យមកជួយមើលប្រាក់ ពីព្រោះគាត់ចង់យកប្រាក់ទៅប្តូរនៅខាងក្រៅដែលជាប្រាក់បង់ពន្ធ និងបានប្រាប់ខ្លួនថាចំនួនប្រហែលជាជាង ៦លានដុល្លាអាមរិក ហើយខ្លួនក៏ប្រាប់គាត់ថាឱ្យប្តូរនៅធនាគារទៅ តែគាត់ថាបានទាបពេក។ ខ្លួនដឹងថាជាប្រាក់របស់អតិថិជនដែលយកមកបង់ពន្ធ។ ពេលឈ្មោះ[redacted] វណ្ណនារីរតន៍ ទូរស័ព្ទមកខ្លួននោះ គឺមិនបានទូរស័ព្ទប្រាប់ទុកមុនយូរទេ ពេលមកដល់ធនាគារកាណាឌីយ៉ា អ.ក ខ្លួនឡើងទៅជាន់ទី២ ដើម្បីជួបឈ្មោះ [redacted] វណ្ណនារីរតន៍ ពេលជួបគាត់ គាត់បានឱ្យខ្លួនមកជាន់បេឡា (ជាន់ផ្ទាល់ដី) ជួបអតិថិជនដែលដកប្រាក់នៅជាន់ក្រោម ដើម្បីយកប្រាក់ពីអតិថិជន ពេលនោះក៏មានសន្តិសុខ០៣នាក់នៅទីនោះ (មានឈ្មោះ[redacted] ហៀង ចំណែក ០២នាក់ទៀតខ្លួនមិនស្គាល់)។ បន្ទាប់ពីបានប្រាក់ហើយ ខ្លួនបានយកប្រាក់នោះទៅលើជាមួយសន្តិសុខ ០៣នាក់មានឈ្មោះ[redacted] ហៀង យកទៅទុកក្នុងបន្ទប់ វីអាយភី ជាន់ទី៥។ ពេលយកប្រាក់ទៅទុកនៅបន្ទប់ជាន់ទី៥ ហើយ ខ្លួនអង្គុយចាំប្តីរបស់ឈ្មោះ [redacted] វណ្ណនារីរតន៍ មកយក បន្ទាប់មកប្តីរបស់ឈ្មោះ[redacted] វណ្ណនារីរតន៍ បានមកយកប្រាក់នោះតែម្នាក់ឯង គាត់យកម្តង ០១ថង់ៗរហូតដល់អស់ ខ្លួនក៏ត្រឡប់ទៅផ្ទះវិញ។ ពេលទៅដល់ធនាគារកាណាឌីយ៉ា អ.ក ឈ្មោះ[redacted] វណ្ណនារីរតន៍ ប្រាប់ថាក្នុងថង់ខ្មៅនោះជាប្រាក់ជាង ៦លានដុល្លាអាមេរិក គាត់ចង់យកទៅប្តូរនៅខាងក្រៅ។ ខ្លួនដឹងថាការយកប្រាក់ចេញក្រៅធនាគារ គឺខុស ហើយមូលហេតុដែលខ្លួនជួយឈ្មោះ [redacted] វណ្ណនារីរតន៍ យកចេញក្រៅនោះ ដោយសារតែមនោសញ្ចេតនាការរាប់អានគ្នា ពីព្រោះគាត់ធ្លាប់មានគុណជួយខ្លួនឱ្យខ្លួនខ្ចីប្រាក់គាត់ ២០,០០០$ (ពីរម៉ឺនដុល្លាអាមេរិក) ដើម្បីសងគេ កាលពីឆ្នាំ២០១៦ ខ្លួនមិនបានអីមកវិញពីការជួយនោះទេ។ ប្រាក់ ៦លានដុល្លាអាមេរិកជាង ដែលយកទៅនោះ ឈ្មោះ [redacted] វណ្ណនារីរតន៍ យកទៅធ្វើអ្វីខ្លួនមិនដឹងទេ។ ឈ្មោះ [redacted] វណ្ណនារីរតន៍ បានពឹងខ្លួនឱ្យជួយយកប្រាក់នោះទៅប្តូរនៅក្រុមហ៊ុន លី ហួរ ប្តូរប្រាក់ ចំនួន ០៣ដង គឺថ្ងៃទី២៨ ខែមករា ឆ្នាំ២០២០ ប្តូរជិត ៥លានដុល្លាអាមេរិក ថ្ងៃទី០៤ ឬទី០៥ ខែកុម្ភៈ ឆ្នាំ២០២០ ប្តូរប្រហែលជាជាង ១លានដុល្លាអាមេរិក ហើយថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២០ ប្តូរ ១០០,០០០$ (ដប់ម៉ឺនដុល្លាអាមេរិក) ដោយប្រាក់ទាំងនោះប្តូរចេញជាមូលប្បទានប័ត្រ ហើយយកទៅដាក់បញ្ចូលទៅក្នុងប្រព័ន្ធពន្ធដារ។ ការជួយប្តូរប្រាក់នេះដោយសារឈ្មោះ[redacted] វណ្ណនារីរតន៍ នៅក្រៅប្រទេស ហើយឪពុកម្តាយគាត់ចាស់ៗ។ ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២០ ឈ្មោះ[redacted] វណ្ណនារីរតន៍ ត្រឡប់មកប្រទេសខ្មែរវិញ តែគាត់រវល់ជាមួយធនាគារក៏ឱ្យខ្លួនទៅជួយប្តូរឱ្យទៀត។ មូលហេតុដែលឈ្មោះ[redacted] វណ្ណនារីរតន៍ ទុករយៈពេលយូរបានប្តូរប្រាក់នោះ ខ្លួនមិនបានដឹងនោះទេ។ ពេលទៅប្តូរប្រាក់លើកទី១ ខ្លួននៅជាមួយឪពុក



Scanned with CamScanner

ម្ដាយរបស់ឈ្មោះ [redacted] **វណ្ណនារីរតន៍** ប្ដូរលើកទី២ និងលើកទី៣ ខ្លួនទៅតែម្នាក់ឯង។ ឈ្មោះ [redacted] **វណ្ណនារីរតន៍** ធ្លាប់វេរប្រាក់ឱ្យខ្លួន ០២លើក សរុប ២០០,០០០$ (ម្ភៃម៉ឺនដុល្លារអាមេរិក) លើកទី១ វេរថ្ងៃទី២៧ ខែមករា ឆ្នាំ២០២០ លើកទី២ វេរថ្ងៃទី២៨ ខែមករា ឆ្នាំ២០២០ ពេលព្រឹក ដោយប្រាក់វេរទាំង ០២លើកនោះ ជាប្រាក់ក្នុងប្រាក់ប្ដូរ ៦លានដុល្លារអាមេរិកជាង ជាប្រាក់សំរាប់យកទៅបញ្ចូលក្នុងប្រព័ន្ធពន្ធដារឱ្យគ្រប់ចំនួន ៦លានដុល្លារអាមេរិកជាងវិញ។ ការវេរ ០២ដងនេះ គឺដោយសារតែខាងធនាគារ ABA កំណត់ឱ្យវេរមួយថ្ងៃបានតែ ១០០,០០០$ (ដប់ម៉ឺនដុល្លារអាមេរិក)។ ពេលយកប្រាក់នោះចេញទៅក្រៅ ខ្លួនមិនដឹងថា ឈ្មោះ [redacted] សុវណ្ណចរិយា, ឈ្មោះ [redacted] សុភាយ និងឈ្មោះ [redacted] **ហៀង** បានដឹង ឬអត់នោះទេ។ ពេលឈ្មោះ [redacted] **ស៊ីមន្ថា** ទៅយកប្រាក់ពីបន្ទប់ជាន់ទី៥ នោះ ខ្លួនមិនដឹងថាគាត់បានដឹងថាជាប្រាក់ ឬអត់នោះទេ ហើយសន្តិសុខក៏ខ្លួនមិនបានដឹងថា គាត់ដឹងថាថង់ខ្មៅនោះជាថង់ប្រាក់ ឬអត់នោះទេ ហើយទម្លាប់សន្តិសុខនោះ គឺគាត់តែងតែជួយកាន់អីវ៉ាន់ឱ្យអតិថិជន និងអ្នកដែលគាត់ធ្លាប់ស្គាល់។ ពេលប្ដីរបស់ឈ្មោះ [redacted] **វណ្ណនារីរតន៍** មកយកប្រាក់ គាត់មិនបាននិយាយអ្វីជាមួយខ្លួននោះទេ គ្រាន់តែនិយាយពាក្យថា "សួស្ដី" និង "លាហើយ" ប៉ុណ្ណោះ។ ក្រៅពីថ្ងៃទី១៨ ខែមករា ឆ្នាំ២០២០ ខ្លួនមិនដែលជួយមើលប្រាក់ ឬយកប្រាក់ឱ្យឈ្មោះ [redacted] **វណ្ណនារីរតន៍** ទេ។ ឈ្មោះ [redacted] **វណ្ណនារីរតន៍** ធ្លាប់ពឹងខ្លួនឱ្យជួយលក់គ្រឿងអលង្ការគាត់ តែខ្លួនមិនដឹងថាគាត់យកប្រាក់ទៅណាទេ។ ប្រាក់ចំនួន ៦លានដុល្លារអាមេរិកជាងដែលយកទៅប្ដូរនោះ បានយកទៅដាក់បញ្ចូលសងក្នុងប្រព័ន្ធពន្ធដារអស់ហើយ និងនៅសល់ប្រាក់ខ្លះចំនួន ៣,០០០$ (បីពាន់ដុល្លារអាមេរិក) តែឈ្មោះ [redacted] **វណ្ណនារីរតន៍** ថាឱ្យទុកសិនទៅ ពីព្រោះប្រាក់ដែលយកទៅបញ្ចូលសងនោះ គឺគ្រប់ចំនួនអស់ហើយ ប្រាក់សល់នេះឈ្មោះ [redacted] **វណ្ណនារីរតន៍** មិនទាន់បានយកពីខ្លួននៅឡើយ គាត់ថាផ្ញើនឹងខ្លួនសិន។ នៅល្ងាចថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២០ ម៉ោងចេញធ្វើការ ខ្លួនបានពឹងឈ្មោះ [redacted] **ហៀង** ឱ្យជូនខ្លួនទៅប្ដូរប្រាក់ក្រុមហ៊ុន លី ហួរ ប្ដូរប្រាក់ ពីព្រោះថ្ងៃនោះខ្លួនទៅយកប្រាក់ពីឈ្មោះ [redacted] **វណ្ណនារីរតន៍** នៅធនាគារការណាឌីយ៉ា អ.ក ដើម្បីយកទៅប្ដូរប្រហែល ១០០,០០០$ (ដប់ម៉ឺនដុល្លារអាមេរិក) ប្រាក់នេះជាប្រាក់ដែលឈ្មោះ [redacted] **វណ្ណនារីរតន៍** ឱ្យជួយប្ដូរដើម្បីយកទៅដាក់ចូលក្នុងប្រព័ន្ធពន្ធដារសងធនាគារវិញ ហើយខ្លួនបានជួបឈ្មោះ [redacted] **ហៀង** ចែងន្យនៅធនាគារកាណាឌីយ៉ា អ.ក ក៏បានសុំឱ្យគាត់ជូនទៅប្ដូរប្រាក់តែម្ដង។ ខ្លួនឱ្យគាត់ជូនដោយសារម៉ោងចេញពីធ្វើការពិបាកហៅផាសអេបជិះ ហើយផ្លូវក៏ស្ទះទៀង ម្យ៉ាងគាត់ចេញពីធ្វើការស្រាប់ ហើយជិះម៉ូតូចិងអាចលឿន បានជាខ្លួនពឹងគាត់។ ខ្លួនប្រាប់គាត់ថា ជួយជូនខ្លួនទៅប្ដូរប្រាក់បន្តិច ហើយគាត់មិនបានសួរនាំអ្វីទេ ខ្លួនក៏មិនបានប្រាប់ថាជាប្រាក់អ្វីដែរ។ ខ្លួនពឹងគាត់ដោយសារគាត់ជាមនុស្សងាយស្រួលពឹងពាក់។ ខ្លួនពឹងគាត់ជូនទៅ ខ្លួនមិនបានឱ្យអ្វីទៅគាត់ទេ។ ប្រាក់ប្ដូរទាំងអស់ គឺខ្លួនជាអ្នកប្ដូរ។ ខ្លួនមិនដឹងមូលហេតុអ្វីដែលឈ្មោះ [redacted] **វណ្ណនារីរតន៍** ឱ្យខ្លួនទៅប្ដូរប្រាក់ច្រើនដងនោះទេ។ ថ្ងៃទី១៨ ខែមករា ឆ្នាំ២០២០ ជាថ្ងៃសៅរ៍ ខ្លួនបានសុំច្បាប់ខាងធនាគារ វឌ្ឍនៈ អាស៊ីចំកាត់ ឈប់សំរាក ហើយខ្លួនបានទៅដល់ធនាគារកាណាឌីយ៉ា អ.ក ម៉ោងប្រហែល ០៩ព្រឹកជាង ទៅម្នាក់ឯង។ នៅថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២០ ខ្លួនមិនបានពឹងឈ្មោះ [redacted] សំណាង ឱ្យយកមូលប្បទានប័ត្រមកធនាគារកាណាឌីយ៉ា អ.ក ទេ។ នៅថ្ងៃទី១៤ និងថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២០ ខ្លួនបានយកមូលប្បទានប័ត្រមកឱ្យឈ្មោះ [redacted] **វណ្ណនារីរតន៍** ដោយផ្ទាល់។ ខ្លួនមិនស្គាល់ឈ្មោះ **សត្យា** ទេ។ ឈ្មោះ **សត្យា** និងឈ្មោះ [redacted] សំណាង ខ្លួនមិនដឹងថាជាមនុស្សតែម្នាក់ ឬអត់នោះទេ។ លេខទូរស័ព្ទ ០៩៣ ៩២៩៩៩៧ ខ្លួនមិនដឹងថាជារបស់អ្នកណាទេ។ ខ្លួនមិនដឹងថាឈ្មោះ [redacted] សំណាង ធ្លាប់មកធនាគារកាណាឌីយ៉ា អ.ក ទេ។ នៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០ ខ្លួនមិនដឹងថា



Scanned with CamScanner

ឈ្មោះ [redacted]សំណាង មកធនាគារកាណាឌីយ៉ា អ.ក ទេ។ ខ្លួនធ្លាប់ជួយឈ្មោះ [redacted]វឌ្ឍនានារីរតន៍ យកប្រាក់ចេញពីធនាគារតែម្តងទេ។ ខ្លួនមិនដឹងថាឈ្មោះ [redacted]វឌ្ឍនានារីរតន៍ យកប្រាក់ចេញពីធនាគារចំនួនប៉ុន្មានដងទេ។

-ជនជាប់ចោទឈ្មោះ [redacted]សុវណ្ណចរិយា បានឆ្លើយថា៖ ខ្លួនធ្វើការនៅធនាគារកាណាឌីយ៉ា អ.ក តាំងពីចុងឆ្នាំ២០១២ មកដល់ថ្ងៃឃាត់ខ្លួន មានតួនាទីជាបេឡាខាងបង់ប្រាក់សោធននិវត្តន៍ដល់ឆ្នាំ២០១៥ ហើយខ្លួនបានចូលធ្វើជាបេឡាផ្នែកទទួលបង់ពន្ធពីឆ្នាំ២០១៥ ដល់ឆ្នាំ២០១៧ និងចាប់ពីឆ្នាំ២០១៧ ដល់ពេលឃាត់ខ្លួន មានតួនាទីជាអ្នកត្រួតពិនិត្យបុគ្គលិកបេឡាផ្នែកបង់ពន្ធ ដែលនៅក្នុងនោះខ្លួនត្រួតពិនិត្យលើឈ្មោះ [redacted]វឌ្ឍនានារីរតន៍។ ចំណែកឈ្មោះ [redacted]រចនា គាត់ជាអ្នកពិនិត្យការងារលើខ្លួនបន្ថែមទៀត គាត់ជាអនុប្រធានសាខាទទួលបន្ទុកបង់ពន្ធ ខ្លួនធ្វើការងារជាមួយគាត់។ ពីឆ្នាំ២០១៥ ដល់ឆ្នាំ២០១៧ ខ្លួនមានតួនាទីសួរអតិថិជនថាគាត់ចង់មកបង់ពន្ធប្រភេទណា ហើយទទួលប្រាក់បង់ពន្ធពីអតិថិជនបង់ទៅធនាគារ រួចចេញបង្កាន់ដៃធនាគារឱ្យអតិថិជន។ ប៉ុន្តែតាំងពីឆ្នាំ២០១៦ មកមានបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធដែលខាងពន្ធដារឱ្យ ទើបខាងខ្លួនចេញបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធឱ្យអតិថិជន ដោយអ្នកណាអ្នកទទួលអ្នកនោះជាអ្នកចុះហត្ថលេខាលើបង្កាន់ដៃនោះ។ ក្រោយឆ្នាំ២០១៥ គេមានបង្កើតប្រព័ន្ធពន្ធដារ ដូចនេះពេលបេឡាទទួលប្រាក់ហើយ ត្រូវបញ្ចូលប្រាក់នោះក្នុងប្រព័ន្ធពន្ធដារ ហើយព្រីនជាបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធឱ្យអតិថិជន (សម្រាប់អតិថិជនចប់ត្រឹមហ្នឹង) និងព្រីនប័ណ្ណដាក់ប្រាក់ធនាគារមួយទៀត ដើម្បីយកបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធភ្ជាប់ជាមួយប័ណ្ណដាក់ប្រាក់ធនាគារមកឱ្យខ្លួនពិនិត្យ។ ពេលខ្លួនត្រួតពិនិត្យ គេមិនបានយកប្រាក់មកឱ្យពិនិត្យទេ គឺគេឱ្យតែបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធ និងប័ណ្ណដាក់ប្រាក់ធនាគារឱ្យពិនិត្យមើល បើឃើញត្រឹមត្រូវហើយទើបខ្លួនអនុញ្ញាត (Authorize) និងចុះហត្ថលេខាលើប័ណ្ណដាក់ប្រាក់របស់ធនាគារ។ សូមបញ្ជាក់ថា ចំពោះប្រាក់ពន្ធត្រឹម ៨,០០០,០០០៛ (ប្រាំបីលានរៀល) ចុះ បេឡាមានសិទ្ធិចុះក្នុងប្រព័ន្ធពន្ធដារ រួចចេញបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធឱ្យអតិថិជន មិនចាំបាច់ឆ្លងកាត់ការត្រួតពិនិត្យពីខ្លួន ឬពីឈ្មោះ [redacted]ចនា ទេ មានន័យថាប្រាក់នោះនឹងចូលដោយស្វ័យប្រវត្តិទៅក្នុងប្រព័ន្ធធនាគារ ដោយខ្លួនគ្រាន់តែចូលមើលព័ត៌បន្ថែមថា មានខុសអ្វីជាមួយបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធ ឬអត់ បើត្រឹមត្រូវខ្លួនគ្រាន់តែផ្ទៀងផ្ទាត់បញ្ជាក់នៅលើប្រព័ន្ធធនាគារនៅក្នុងកុំព្យូទ័រ។ ចំពោះប្រាក់ពន្ធចាប់ពី ៨,០០០,០០០៛ (ប្រាំបីលានមួយរៀល) ទៅដល់ក្រោម ៤០,០០០,០០០៛ (សែសិបលានរៀល) ត្រូវការខ្លួនជាអ្នកត្រួតពិនិត្យ, អនុញ្ញាត (Authorize) និងចុះហត្ថលេខាជាមុនសិន ទើបប្រាក់ពន្ធនោះអាចចូលទៅក្នុងប្រព័ន្ធធនាគារ ករណីនេះដំបូងបេឡាគាត់ទទួលប្រាក់ពន្ធ ហើយគាត់បញ្ចូលប្រាក់ពន្ធនេះទៅក្នុងប្រព័ន្ធគណនីពន្ធដារ និងព្រីនបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធ ព្រមទាំងព្រីនប័ណ្ណដាក់ប្រាក់ធនាគារមួយទៀតយកមកឱ្យខ្លួនត្រួតពិនិត្យ បើពិនិត្យថាទឹកប្រាក់ និងឯកសារត្រឹមត្រូវ ខ្លួននឹងអនុញ្ញាត (Authorize) នៅលើកុំព្យូទ័រ និងចុះហត្ថលេខានៅប័ណ្ណដាក់ប្រាក់ធនាគារ ទើបប្រាក់នោះអាចចូលទៅក្នុងប្រព័ន្ធធនាគារបាន។ ហើយប្រាក់ពន្ធចាប់ពី ៤០,០០០,០០០៛ (សែសិបលានរៀល) ឡើងទៅ ត្រូវការមានប្រធានសាខា ឬអនុប្រធានសាខាគាត់ផ្ទៀងផ្ទាត់បញ្ជាក់អនុញ្ញាត (Authorize) ពីលើខ្លួនម្នាក់ទៀតថាប្រាក់ពន្ធដែលទទួល និងឯកសារនោះត្រឹមត្រូវ និង



Scanned with CamScanner

គាត់ចុះហត្ថលេខាបញ្ជាក់នៅលើឯកសារនោះ ទើបប្រាក់អាចចូលទៅក្នុងប្រព័ន្ធធនាគារបាន ហើយក្នុងករណីដែលឈ្មោះ [redacted] វចនា អត់នៅត្រូវឱ្យប្រធានសាខាផ្សេងពិនិត្យមើល និងឯកភាពបន្ត។ កន្លែងបេឡាបង់ពន្ធ គឺមានតែខ្លួនទេដែលត្រូវពិនិត្យមើលលើបេឡាបង់ពន្ធ តែក្នុងករណីដែលខ្លួនមិននៅទើបមានអ្នកជំនួស។ ខ្លួនស្គាល់ឈ្មោះ [redacted] វណ្ណនទារីរតន៍ ស្គាល់ប្ដីរបស់គាត់ឈ្មោះ [redacted] ស៊ីមន្ថា ស្គាល់ពេលដែលចូលរួមកម្មវិធីម្ដង ទៅ ០២ដង តែមិនស្និតស្នាលទេ គ្រាន់តែជម្រាបសួរគាត់ មិនដឹងថាគាត់ស្គាល់ខ្លួន ឬអត់ទេ។ ចំណែកឈ្មោះ [redacted] សុភាយ ជាស្វាមីខ្លួន មានតួនាទីជាអ្នកផ្នែកព័ត៌មានវិទ្យា (IT) នៅក្នុងធនាគារកាណាឌីយ៉ា អ.ក តួនាទីគាត់គ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យា (IT) នៅក្នុងធនាគារ។ គាត់ចេញចូលនៅក្នុងបន្ទប់ធ្វើការខ្លួន ដោយសារពេលខ្លះមានបញ្ហាប្រព័ន្ធយឺតទើបគាត់ទៅពិនិត្យមើល និងទិញរបស់ឱ្យខ្លួនហូបជាដើម។ គាត់ឧស្សាហ៍ចេញចូលកន្លែងខ្លួន ដោយសារប្រព័ន្ធធនាគារប្ដូរប្រព័ន្ធ។ ខ្លួនមិនដឹងថាការងារគាត់ធ្វើអ្វីខ្លះទេ។ ខ្លួនមិនដឹងរឿងយកប្រាក់របស់ធនាគារទេ ហើយក៏មិនបានចូលរួមលួចដែរ។ ខ្លួនដឹងថាធនាគារបាត់ប្រាក់នៅពេលដែលគេចុះមកសវនកម្ម តែមិនដឹងថាបាត់ប៉ុន្មាន អ្នកណាជាអ្នកលួចនោះទេ។ មុនពេលគេចុះសវនកម្ម ខ្លួនមិនដឹងថាអ្នកណាជាអ្នកយកប្រាក់នោះទេ។ ថ្ងៃទី១៨ ខែមករា ឆ្នាំ២០២០ ខ្លួនមកធ្វើការធម្មតា។ ខ្លួនមិនបានដឹងថាក្រុមហ៊ុន គ័នហ៊្គង ខនស្ត្រាក់សិន (ខេមបូឌា) ឯ.ក យកប្រាក់មកបង់នោះទេ។ បង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធចេញឱ្យអតិថិជនមុនពេលបញ្ចូលទិន្នន័យទៅក្នុងប្រព័ន្ធធនាគារ។ ការងារប្រចាំរាល់ថ្ងៃ នៅម៉ោង០៥ ខ្លួនត្រូវព្រីនប័ណ្ណដាក់ប្រាក់ធនាគារ ហើយឱ្យបេឡាប្ដូរគ្នាផ្ទៀងប័ណ្ណដាក់ប្រាក់នោះ និងរបាយការណ៍ធនាគារថាទឹកប្រាក់ប៉ុណ្ណឹងត្រូវអត់ បើប្រាក់ក្នុងប្រព័ន្ធធនាគារ និងប្រាក់ជាក់ស្ដែងត្រូវគ្នាទើបបិទបញ្ជី។ ការត្រួតពិនិត្យ គឺធ្វើ ០២ដងក្នុងមួយថ្ងៃ ពេលថ្ងៃត្រង់ម្ដង និងពេលល្ងាចម្ដង។ ការងារខ្លួនជាអ្នកមើលប្រព័ន្ធធនាគារ មិនមែនផែកមើលប្រព័ន្ធពន្ធដារទេ ដូចនេះបើបេឡាបញ្ចូលប្រាក់ត្រឹមតែប្រព័ន្ធពន្ធដារ ហើយតែព្រីនបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធខ្លួនមិនដឹងទេ ទាល់តែចូលប្រាក់ក្នុងប្រព័ន្ធធនាគារបានខ្លួនដឹង មានន័យថាខ្លួនផែកបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធ, ប័ណ្ណដាក់ប្រាក់ធនាគារ និងប្រព័ន្ធធនាគារ មិនមែនផែកក្នុងប្រព័ន្ធពន្ធដារ។ បើបញ្ចូលត្រឹមតែក្នុងប្រព័ន្ធពន្ធដារ ខាងពន្ធដារគាត់អាចដឹង ពីព្រោះគាត់អាចផែកមើលបាន។ ខ្លួនមិនដែលចូលផែកក្នុងប្រព័ន្ធពន្ធដារ។ ខ្លួនធ្លាប់ឱ្យឈ្មោះ [redacted] វណ្ណនទារីរតន៍ ខ្ចីប្រាក់ឯកជនខ្លួនចំនួន ២,៥០០$ (ពីរពាន់ប្រាំរយដុល្លាអាមេរិក) ដោយមានការប្រាក់ ២០% ក្នុងរយៈពេល ១០ថ្ងៃ តែខ្លួនមិនចាំពេលខ្ចីទេ ហើយក៏គ្មានកិច្ចសន្យាដែរ សរុបទាំងការ និងដើម ៤០,០០០$ (បួនម៉ឺនដុល្លាអាមេរិក)។ រូបភាពនៅក្នុងកាមេរ៉ាសុវត្ថិភាព គឺរូបដែលខ្លួនយកការប្រាក់ពីគាត់មិនមែនប្រាក់ផ្សេងទេ។ ឈ្មោះ [redacted] វណ្ណនទារីរតន៍ ឱ្យការប្រាក់មកខ្លួនក្នុងអំឡុងខែធ្នូ ឆ្នាំ២០១៩ និងអំឡុងដើមខែមករា ឆ្នាំ២០២០ គាត់ឱ្យ ០២ដង មាន ៣,០០០$ (បីពាន់ដុល្លាអាមេរិក) និង ៥,០០០$ (ប្រាំពាន់ដុល្លាអាមេរិក)។ មូលហេតុដែលខ្លួនធ្វើកិច្ចសន្យាសងប្រាក់ឱ្យធនាគារ ដោយសារតែខាងធនាគារឱ្យខ្លួនសរសេរទើបគេឱ្យទៅផ្ទះ ពេលនោះខ្លួនគណនាឃើញការប្រាក់ចំនួន ១២០,០០០$ (ដប់ពីរម៉ឺនដុល្លាអាមេរិក) ហើយកិច្ចសន្យានោះខ្លួនជាអ្នកសរសេរដោយផ្ទាល់ដៃ។ ចំពោះបុគ្គលិកផ្សេងដែលចេញចូលក្នុងការិយាល័យខ្លួន គឺត្រូវមានការអនុញ្ញាតពីប្រធាន ហើយចំពោះប្ដីខ្លួនឈ្មោះ ហោង



Scanned with CamScanner

សុភាយ គាត់ចេញចូលការិយាល័យខ្លួនជាការងាររបស់គាត់ខ្លួនមិនដឹងនោះទេ ពីព្រោះខ្លួននឹងគាត់មានការងារផ្សេងគ្នា។ ផ្នែកព័ត៌មានវិទ្យា (IT) អាចចេញចូលកន្លែងរបស់បេឡាបាន ប្រសិនបើមានបញ្ហាពាក់ព័ន្ធប្រព័ន្ធប្រតិបត្តិការ ដោយមានការអនុញ្ញាតពីប្រធានរបស់ខ្លួន។ ប្រាក់ធនាគារខ្លួនបិទបញ្ជីរាល់ថ្ងៃមិនដែលបាត់ទេ។ ចំពោះឈ្មោះ [redacted] បញ្ញាសុជាតា ខ្លួនធ្លាប់ស្គាល់ ពីព្រោះគាត់ធ្លាប់ធ្វើការនៅទីនោះ ហើយក្រោយពេលគាត់ឈប់ធ្វើការនៅធនាគារកាណាឌីយ៉ា អ.ក ខ្លួនមិនដែលឃើញគាត់មកធនាគារនោះទេ។ ថ្ងៃទី១៨ ខែមករា ឆ្នាំ២០២០ គាត់មកធនាគារ ឬអត់ក៏មិនដឹង។ ចំពោះសន្តិសុខវិញការងារគាត់ធ្វើអ្វីខ្លះខ្លួនមិនដឹង តែពេលយកប្រាក់បិទបញ្ជី គឺសន្តិសុខធនាគារគ្នាក៏ជួយយកប្រាក់ទៅទុក។ នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២០ ខ្លួនមិនបានឃើញឈ្មោះ [redacted] ស៊ីមន្ថា មកធនាគារកាណាឌីយ៉ា អ.ក ទេ។ នៅពេលមានប្រតិបត្តិការណ៍មិនប្រក្រតីខ្លួនអាចអនុញ្ញាតឱ្យបេឡាលុប ហើយធ្វើប្រតិបត្តិការណ៍ថ្មី និងត្រូវមានការអនុញ្ញាតពីអនុប្រធានសាខា និងប្រធានសាខា។ ខ្លួនធ្លាប់ទិញកញ្ចប់ទេសចរណ៍ទៅលេងប្រទេសម៉ាឡេស៊ីជាមួយប្ដីខ្លួន និងប្ដីប្រពន្ធឈ្មោះ [redacted] វណ្ណនារីរតន៍។ នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២០ ខ្លួនមិនដឹងថាឈ្មោះ [redacted] វណ្ណនារីរតន៍ ទៅជួបអតិថិជននោះទេ ហើយក៏មិនដឹងថាមានក្រុមហ៊ុន គ័ន ហ្គ័ង ខនស្ត្រាក់សិន (ខេមបូឌា) ឯ.ក មកបង់ពន្ធ និងមិនដឹងថាគាត់ព្រីនបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធលេខ ០០៤០៤៥៨៣៨ និងលេខ ០០៤០៤៥៨៣៩ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០២០ ដែរ។ តាំងពីខ្លួនចូលធ្វើការមកមិនដែលជួបក្រុមហ៊ុនដែលបង់ពន្ធរហូតដល់ ២៤ពាន់លានរៀលនោះទេ ខ្លួនធ្លាប់ទទួលអស់ច្រើនត្រឹម ១៤ពាន់លានរៀល។ ថ្ងៃទី១៨ ខែមករា ឆ្នាំ២០២០ ខ្លួនមិនធ្លាប់ឃើញប្រាក់ ២៤ពាន់លានរៀលជាងចូលការិយាល័យខ្លួន និងក្នុងប្រព័ន្ធធនាគារឱ្យខ្លួនអនុញ្ញាត (Authorize) ទេ ខ្លួនក៏មិនធ្លាប់ត្រួតពិនិត្យបង្កាន់ដៃ២ ខាងលើដែរ។ ថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០ ខ្លួនសុំច្បាប់ធម្មតាត្រូវមានអ្នកជំនួសខ្លួន តែមិនដឹងអ្នកណា។ ចំពោះប្រតិបត្តិការបញ្ចូលទឹកប្រាក់សងធនាគារពាក់ព័ន្ធនឹងបង្កាន់ដៃទាំង២ ខាងលើរហូតដល់ ០៦លើក ខ្លួនមិនដែលឃើញ និងមិនបានអនុញ្ញាត (Authorize) ទេ។ ប្រសិនបើមានការបង់ពន្ធមិនប្រក្រតី ហើយធ្វើប្រតិបត្តិការខ្វះប្រាក់ ខ្លួនអាចធ្វើការចូលក្នុងប្រតិបត្តិការមួយទៀត ធ្វើប័ណ្ណដាក់ប្រាក់មួយទៀតដើម្បីបង្គ្រប់ប្រាក់វិញ។ ប្រសិនបើខុសទឹកប្រាក់ច្រើន ត្រូវធ្វើត្រឡប់ក្រោយវិញទៅលើប្រតិបត្តិការចាស់ តែត្រូវទទួលការអនុញ្ញាតពីខ្លួនប្រធានសាខាសិន។ ខ្លួនមិនអាចលុបប្រតិបត្តិការមិនប្រក្រតីបានទេ តែបេឡាអាចលុបបាន តែត្រូវមានការអនុញ្ញាតពីខ្លួន និងការអនុញ្ញាតបន្ថែមពីប្រធានសាខាសិន។ ខ្លួនធ្លាប់ទទួលប្រាក់ពីឈ្មោះ [redacted] វណ្ណនារីរតន៍ នៅការិយាល័យបង់ពន្ធ ជាប្រាក់ការប្រាក់ ទើបខ្លួនអាចទទួលនៅមុខកាមេរ៉ាសុវត្ថិភាព។ ខ្លួនមិនធ្លាប់ទទួលប្រាក់ពីឈ្មោះ ទៀង វណ្ណនារីរតន៍ ចំនួន ១០,០០០$ (មួយម៉ឺនដុល្លារអាមេរិក) ទេ។ ឈ្មោះ [redacted] ហៀង ជាសន្តិសុខ ហើយនៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២០ ខ្លួនមិនបានឃើញឈ្មោះ [redacted] ហៀង មកការិយាល័យខ្លួនទេ ហើយខ្លួនក៏មិនដឹងថាឈ្មោះ [redacted] ហៀង បានទទួលប្រាក់ពីឈ្មោះ [redacted] វណ្ណនារីរតន៍ ចំនួន ៥លានរៀលដែរ និងមិនដែលឃើញគាត់ទទួលប្រាក់ពីឈ្មោះ [redacted] វណ្ណនារីរតន៍ ចំនួន ២៨០$ ដែរ។ ថ្ងៃទី៧ និងថ្ងៃ១៥ ខែកុម្ភៈ ឆ្នាំ២០២០ ខ្លួនធ្វើការអ្នកត្រួតពិនិត្យ ហើយមិនមាននរណាផ្សេងមកធ្វើការអនុញ្ញាត (Authorize) ទេ អ្នកត្រួតពិនិត្យការងារបេឡាមានតែខ្លួនម្នាក់។ តែថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២០ នោះខ្លួនមិន



Scanned with CamScanner

បានអនុញ្ញាត (Authorize) លើបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធដែលមានទឹកប្រាក់ ៣ពាន់លានរៀលជាង និង ៨រយលានរៀលជាងទេ ឬមិនបានធ្វើការអនុញ្ញាត (Authorize) ទៅលើមូលប្បទានប័ត្រចំនួន ២នោះទេ បើមានការអនុញ្ញាត (Authorize) ប្រាកដជាមានហត្ថលេខាខ្លួននៅលើប័ណ្ណដាក់ប្រាក់ធនាគារនោះហើយ ម្យ៉ាងទៀតប្រសិនបើមានការអនុញ្ញាត (Authorize) ប្រាកដជាឃើញមានឈ្មោះរបស់ខ្លួនចូលទៅក្នុងប្រព័ន្ធដើម្បីអនុញ្ញាតហើយ។ ខ្លួនមិនធ្លាប់អនុញ្ញាត (Authorize) លើប្រតិបត្តិការដែលពុំមានបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធជាមួយនឹងប័ណ្ណដាក់ប្រាក់ធនាគារទេ។ ហត្ថលេខានៅលើប័ណ្ណដាក់ប្រាក់ធនាគារដែលយកមកដាក់ចូលថ្ងៃទី២៨ ខែមករា ឆ្នាំ២០២០ មិនមែនជាហត្ថលេខារបស់ខ្លួនទេ គឺជាហត្ថលេខារបស់ឈ្មោះ [redacted]សុធារី។ នៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០ ខ្លួនសុំច្បាប់រហូតដល់ថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០។ នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២០ ខ្លួនមិនចាំថាឈ្មោះ [redacted]រចនា មកធ្វើការ ឬអត់ទេ តែខ្លួនមកធ្វើការ។ ខ្លួនមិនដឹងថាប្រាក់គេបានដាក់ចូលគ្រប់វិញហើយ ឬនៅទេ ដោយសារគេមិនបានប្រាប់ខ្លួន។ ខ្លួនមិនអាចចូលទៅផែកប្រព័ន្ធពន្ធដារ ដើម្បីមើលរបាយការណ៍ពន្ធដារបានទេ។

-ជនជាប់ចោទឈ្មោះ[redacted]រចនា បានឆ្លើយថា៖ ខ្លួនធ្វើការនៅធនាគារកាណាឌីយ៉ា អ.ក តាំងពីឆ្នាំ២០០៥ ដល់បច្ចុប្បន្ន ដំបូងខ្លួនធ្វើខាងផ្នែកគណនេយ្យ បន្ទាប់មកខ្លួនធ្វើការក្នុងផ្នែកលេខាឱ្យលោកឧកញ៉ា ពុង ឃាងសែ បន្ទាប់ធ្វើការផ្នែកគម្រោងសាងសង់ផ្ទះរបស់ធនាគារ ក្រោយមកខ្លួនធ្វើជា Deposit manager ទីតាំងនៅសង្កាត់អូឡាំពិច បន្ទាប់មកធ្វើជា Supervisor នៅទីស្នាក់ការកណ្ដាល បន្ទាប់មកទៀតធ្វើការជាអនុប្រធានសាខាផ្នែកបង់ពន្ធនៅទីស្នាក់ការកណ្ដាល ខ្លួនធ្វើការជាអនុប្រធានសាខាផ្នែកបង់ពន្ធនេះក្នុងអំឡុងពេលប្រហែលជា ០៧ឆ្នាំ ទៅ ០៨ឆ្នាំហើយ ហើយបានឡើងជាអនុប្រធាន ០៤ឆ្នាំ ទៅ ០៥ឆ្នាំ ពីឆ្នាំ២០១៦ ដល់ថ្ងៃចាប់ខ្លួន មានតួនាទីមើលការងារទូទៅនៅផ្នែកបង់ពន្ធពេលមានបញ្ហាអ្វីខ្លួនជាអ្នកដោះស្រាយ។ ខ្លួនមើលលើប្រតិបត្តិការទូទៅរបស់ Checker (ឈ្មោះ [redacted]សុវណ្ណចរិយា) និងមើលផ្ទៀងផ្ទាត់ពីលើបេឡា។ ពេលមានបញ្ហា បេឡាត្រូវជួប checker សិន បានជួបខ្លួន។ ផ្នែកបង់ពន្ធខ្លួនមានតួនាទីមើលលើប្រតិបត្តិការទូទៅថាតើទឹកប្រាក់ និងឯកសារចេញទៅត្រឹមត្រូវដែល ឬទេ ចំពោះផ្នែករបាយការណ៍ទាំងទៅពន្ធដារ និងធនាគារជាតិគឺខ្លួនអ្នកទទួលខុសត្រូវ។ ពេលអតិថិជនចូលមកត្រូវរង់ចាំលេខ ហើយអតិថិជនទៅជួបបេឡាមិនឆ្លងកាត់ខ្លួនទេ បេឡាទទួលប្រាក់ផ្ទាល់ពីអតិថិជន និងរាប់ប្រាក់ត្រឹមត្រូវ រួចបញ្ចូលទៅក្នុងប្រព័ន្ធពន្ធដារ រួចព្រីនចេញនូវបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធ រួចបញ្ជូនទឹកប្រាក់ពន្ធនោះទៅក្នុងប្រព័ន្ធធនាគារ។ ករណីប្រាក់ពន្ធលើសពី ៨,០០០,០០០៛ (ប្រាំបីលានរៀល) រហូតដល់ក្រោម ៤០,០០០,០០០៛ (សែសិបលានរៀល) ត្រូវឆ្លងកាត់ឈ្មោះ[redacted]សុវណ្ណចរិយា ត្រួតពិនិត្យ ហើយបើប្រាក់ពន្ធលើសពី ៤០,០០០,០០០៛ (សែសិបលានរៀល) ត្រូវឆ្លងកាត់ខ្លួនពិនិត្យ ដោយខ្លួនពិនិត្យទៅលើឯកសារប័ណ្ណដាក់ប្រាក់ធនាគារ និងបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធ បើត្រឹមត្រូវហើយខ្លួនចុះហត្ថលេខាអនុញ្ញាត តែបើអតិថិជនបង់ជាមូលប្បទានប័ត្រ ខ្លួនយកមូលប្បទានប័ត្រនោះមកមើលដែរ។ នៅពេលគេយកមកឱ្យខ្លួនពិនិត្យនោះ គឺបេឡាគាត់បញ្ចូលប្រាក់ និងទិន្នន័យទៅក្នុងប្រព័ន្ធអស់ហើយ ខ្លួនគ្រាន់តែពិនិត្យតាមក្រោយ តែជាក់ស្ដែងទឹកប្រាក់ចូលទៅអស់ហើយ។ បើបេឡាអត់បញ្ចូលទឹកប្រាក់ក្នុងប្រព័ន្ធធនាគារទេ គឺខាងខ្លួនមិនដឹងទេ ហើយក្នុងមួយថ្ងៃៗខាងខ្លួនព្រីនតែរបាយការណ៍ធនាគារមកមើល មិនមានព្រីនរបាយការណ៍ពន្ធដារមើលទេ។ រៀងរាល់ល្ងាច គឺមានការផ្ទៀងផ្ទាត់របាយការណ៍

របស់ធនាគារដែលត្រូវចេញពីប្រព័ន្ធធនាគារយកមកផ្ទៀងផ្ទាត់ជាមួយប័ណ្ណដាក់ប្រាក់ធនាគារ ដោយប្អូនគ្នាផ្ទៀងផ្ទាត់ជាមួយប្រាក់ទទួលជាក់ស្តែង។ ឈ្មោះ [redacted] **វណ្ណនារីរតន៍** គឺជាបុគ្គលិកបេឡាហើយជាកូនចៅខ្លួន ពីឆ្នាំណាដល់ឆ្នាំណាខ្លួនមិនចាំទេ ចំណែកឈ្មោះ [redacted] សុវណ្ណចរិយា គាត់ជាអ្នកត្រួតពិនិត្យលើឈ្មោះ [redacted] **វណ្ណនារីរតន៍** ហើយក៏ជាកូនចៅខ្លួនដែរ។ ថ្ងៃទី១៨ ខែមករា ឆ្នាំ២០២០ ខ្លួនសុំច្បាប់ឈប់សម្រាក ដោយខ្លួនគ្រាន់តែផ្ញើសារឱ្យមេ ថ្ងៃបន្ទាប់ទើបខ្លួនបានដាក់ច្បាប់ត្រឹមត្រូវ។ ខ្លួនមិនបានកិបកេងប្រាក់របស់ធនាគារថ្លៃបង់ពន្ធនោះទេ។ ខ្លួនមិនបានចូលរួមយកប្រាក់របស់ធនាគារទេ។ ខ្លួនដឹងរឿងឈ្មោះ [redacted] **វណ្ណនារីរតន៍** លួចប្រាក់ធនាគារពេលចូលឆ្នាំចិនហើយ ខ្លួនដឹងដោយសារតែមានខាងអគ្គនាយដ្ឋានពន្ធដារទាក់ទងមកខ្លួនថា មានក្រុមហ៊ុន គ័ន ហ្វ័ង ខនស្ត្រាក់សិន (ខេមបូឌា) ឯ.ក មកបង់ពន្ធអត់ឱ្យជួយឆែកមើលក្នុងប្រព័ន្ធ ហើយពន្ធដារគេដឹងដោយសារតែយើងផ្ញើរបាយការណ៍ទៅពន្ធដាររាល់ថ្ងៃ ចំណែកប័ណ្ណបង់ប្រាក់ធនាគារមិនផ្ញើឱ្យពន្ធដារទេ។ មូលហេតុដែលខ្លួនឆែកអត់ដឹងថាបាត់ប្រាក់ ដោយសារតែឈ្មោះ [redacted] **វណ្ណនារីរតន៍** គាត់បញ្ចូលទឹកប្រាក់តែទៅក្នុងប្រព័ន្ធពន្ធដារ មិនបញ្ចូលទៅក្នុងប្រព័ន្ធធនាគារទេ ពេលដឹងថាបាត់ប្រាក់ខ្លួនទាក់ទងទៅឈ្មោះ [redacted] **វណ្ណនារីរតន៍** ខ្លួនឯង ខាងធនាគារមិនបានប្រាប់ឱ្យខ្លួនទាក់ទងទៅទេ។ ពេលទទួលព័ត៌មានពីអគ្គនាយកដ្ឋានពន្ធដារថាបាត់ប្រាក់ពន្ធ ខ្លួនក៏បានឆែកមើល ឃើញថា ជាលេខកូដរបស់ឈ្មោះ [redacted] **វណ្ណនារីរតន៍** ដែលចូលទៅក្នុងប្រព័ន្ធពន្ធដារ ទើបដឹងថាជាគាត់ជាអ្នកចូលក្នុងប្រព័ន្ធរបស់ពន្ធដារពាក់ព័ន្ធប្រាក់ដែលបាត់។ នៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០២០ ខាងអគ្គនាយកដ្ឋានពន្ធដារបានទូរស័ព្ទមកខ្លួនសួរថា អត់ឃើញទឹកប្រាក់ចំនួន ៦,១៦០,០០០$ (ប្រាំមួយលានដប់ប្រាំមួយម៉ឺនដុល្លារអាមេរិក) ដែលជាប្រាក់ពន្ធរបស់ក្រុមហ៊ុន គ័ន ហ្វ័ង ខនស្ត្រាក់សិន (ខេមបូឌា) ឯ.ក ចូលក្នុងប្រព័ន្ធគណនីរបស់ពន្ធដារ។ ក្រោយពីបានដឹងរឿងបាត់ប្រាក់ពន្ធនេះ នៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០២០ ដដែល ខ្លួនទាក់ទងទៅឈ្មោះ [redacted] **វណ្ណនារីរតន៍** តាមរយៈផ្ញើសារតាមហ្វេសប៊ុក ពីព្រោះគាត់នៅក្រៅប្រទេស ហើយសួរឈ្មោះ [redacted] **វណ្ណនារីរតន៍** ថា "មានបានទទួលប្រាក់បង់ពន្ធជូនក្រុមហ៊ុនមួយនេះ ឬអត់" ដែលខ្លួនបានបញ្ជាក់ឈ្មោះ និងទឹកប្រាក់របស់ក្រុមហ៊ុននោះ គាត់ឆ្លើយវិញថា "គាត់គិតមើលសិន" ហើយក្នុងថ្ងៃដដែលនោះឈ្មោះ [redacted] **វណ្ណនារីរតន៍** បានប្រាប់មកវិញថា "គាត់បានយកប្រាក់នោះមិនទាន់បានបញ្ចូលប្រាក់ទៅទេ" ហើយខ្លួនក៏បានបញ្ចុះបញ្ចូលឱ្យឈ្មោះ [redacted] **វណ្ណនារីរតន៍** ដាក់ប្រាក់ឱ្យ។ នៅពេលខ្លួនទាក់ទងទៅឈ្មោះ [redacted] **វណ្ណនារីរតន៍** ខាងធនាគារអត់ទាន់ដឹងទេ ហើយមូលហេតុដែលខ្លួនមិនទាន់រាយការណ៍ប្រាប់ធនាគារ ពីព្រោះដើម្បីលួងលោមគាត់ឱ្យដាក់ប្រាក់វិញ ដើម្បីកុំឱ្យបាត់បង់ផលប្រយោជន៍ធនាគារ ពីព្រោះខ្លាចបើមានការរាយការណ៍ទៅធនាគារ ឈ្មោះ [redacted] **វណ្ណនារីរតន៍** អាចគេចវេសមិនយកប្រាក់មកបង់ពន្ធ ខ្លួនគិតតថានឹងលួងលោមឱ្យឈ្មោះ [redacted] **វណ្ណនារីរតន៍** យកប្រាក់មកដាក់នៅធនាគារវិញគ្រប់អស់ ទើបខ្លួនរាយការណ៍ជូនធនាគារ។ ក្រោយពេលឈ្មោះ [redacted] **វណ្ណនារីរតន៍** បញ្ចូលប្រាក់សងបានមួយដងហើយ ទើបខ្លួនប្រាប់ធនាគារថាឈ្មោះ **ទៀង វណ្ណនារីរតន៍** ជាអ្នកយក ដោយសារឈ្មោះ [redacted] **វណ្ណនារីរតន៍** អង្វរខ្លួនមិនឱ្យប្រាប់ធនាគារ។ ឈ្មោះ [redacted] **វណ្ណនារីរតន៍** យកប្រាក់មកដាក់សងធនាគារតាមមូលប្បទានប័ត្រចំនួន ០៣ដង ដោយដាក់ចូលទៅក្នុងប្រព័ន្ធពន្ធដារ មានបុគ្គលិកផ្សេងជាអ្នកដាក់តែខ្លួនមិនដឹងថាអ្នកណាជាអ្នកយកមកដាក់នោះ មូលប្បទានប័ត្រទាំង០៣ នេះ ឈ្មោះ [redacted] **វណ្ណនារីរតន៍** ឱ្យអ្នកផ្សេងយកមកដាក់ ដាក់នៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០ ដោយសារគាត់នៅប្រទេសក្រៅ ខ្លួនដឹងដោយសារឈ្មោះ [redacted] **វណ្ណនារីរតន៍** ប្រាប់ខ្លួនថា បានបញ្ចូលប្រាក់សងវិញហើយ។ ប្រាក់ជាង ៦លានដុល្លារអាមេរិកនោះ ពេលទទួលពីអតិថិជន



Scanned with CamScanner

ឈ្មោះ [redacted] វឌ្ឍននារីរតន៍ មិនបានបញ្ចូលទឹកប្រាក់ទៅក្នុងប្រព័ន្ធធនាគារទេ គាត់បញ្ចូលតែក្នុងប្រព័ន្ធពន្ធដារ។ ខ្លួនធ្លាប់ឱ្យឈ្មោះ [redacted] វឌ្ឍននារីរតន៍ ខ្ចីចាប់ពី ២០០$ (ពីររយដុល្លារអាមេរិក) ដល់ម៉ឺនដុល្លារអាមេរិក ខ្ចីចាប់ពីឆ្នាំ ២០១៨ មក។ ខ្លួនស្គាល់ឈ្មោះ [redacted] ស៊ីមន្ថា គាត់ជាប្តីរបស់ឈ្មោះ [redacted] វឌ្ឍននារីរតន៍។ ឈ្មោះ [redacted] បញ្ញាសុជាតា ខ្លួនស្គាល់គាត់ គាត់ជាអតីតបុគ្គលិកធនាគារកាណាឌីយ៉ា អ.ក។ ចំណែកឈ្មោះ [redacted] សុវណ្ណចរិយា និងឈ្មោះ [redacted] សុអាយ ជាប្តីប្រពន្ធ។ ឈ្មោះ [redacted] សុអាយ គាត់ធ្លាប់ចេញចូលក្នុងបន្ទប់ធ្វើការខ្លួនញឹកញាប់ដែរ ពេលមកហូបបាយ និងពេលរវល់ផ្សេងៗ។ ថ្ងៃទី២៨ ខែមករា ឆ្នាំ២០២០ ខ្លួនទៅធ្វើការ តែថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០ ខ្លួនមិនចាំថាខ្លួនធ្វើការ ឬអត់ទេ។ ខ្លួនសុំច្បាប់ពីថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០។ ថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២០ ខ្លួនទៅធ្វើការ ហើយឈ្មោះ [redacted] សុវណ្ណចរិយា ក៏មកធ្វើការដែរ ដោយថ្ងៃនោះ គឺមានការបញ្ចូលទឹកប្រាក់ពន្ធលើមូលប្បទានប័ត្រចំនួន ០២ ដែលឈ្មោះ [redacted] វឌ្ឍននារីរតន៍ បង្វិលសងវិញទៅក្នុងប្រព័ន្ធធនាគារ តែមិនមានការបញ្ចូលទឹកប្រាក់ទៅក្នុងប្រព័ន្ធពន្ធដារ និងមិនមានចេញបង្កាន់ដៃបញ្ជាក់ប្រាក់ពន្ធទេ ដោយសារមានការបញ្ជាពីអគ្គនាយករងឈ្មោះ ឈ្នួន ធារ៉ាវ៉ាន់ ឱ្យឈ្មោះ [redacted] សុវណ្ណចរិយា និងឱ្យខ្លួនអនុញ្ញាតដាក់ទឹកប្រាក់នោះចូលក្នុងប្រព័ន្ធធនាគារឱ្យហើយនៅក្នុងថ្ងៃហ្នឹង ហើយខ្លួនក៏បានបញ្ចូលរួចរាល់ហើយដែរ។ ទឹកប្រាក់ដែលឈ្មោះ [redacted] វឌ្ឍននារីរតន៍ បង្វិលសងក្នុងថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២០ គឺមានខ្លួន និងឈ្មោះ [redacted] សុវណ្ណចរិយា ជាអ្នកអនុញ្ញាត (Authorize)។ ខ្លួនមិនបានដឹងថាថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២០ មានប្រតិបត្តិការ ០៣ទៀត ដែលឈ្មោះ [redacted] វឌ្ឍននារីរតន៍ បានយកប្រាក់ដែលគេយកមកបញ្ចូលក្នុងប្រព័ន្ធធនាគារវិញទេ ខ្លួនមិនបានអនុញ្ញាត (Authorize) ឱ្យដាក់ចូលទៅលើប្រតិបត្តិការ ០៣នេះទេ ឈ្មោះ [redacted] សុវណ្ណចរិយា គាត់អនុញ្ញាតឬអត់ ខ្លួនមិនដឹង ដោយសារថ្ងៃនោះមានអតិថិជនមកដាក់ប្រាក់ច្រើន អ៊ីចឹងហើយខ្លួនគ្រាន់តែមើលប័ណ្ណដាក់ប្រាក់ធនាគារ ហើយផ្ទៀងផ្ទាត់ក្នុងប្រព័ន្ធធនាគារ ឃើញថាទឹកប្រាក់ចូលក្នុងប្រព័ន្ធត្រឹមត្រូវអត់ ហើយក៏ខ្លួនអនុញ្ញាតឱ្យ ហេតុនេះខ្លួនមិនចាំបាច់សួរថាអតិថិជនណាមកបង់ទេ។ ពេលកូនចៅខ្លួនទទួលប្រាក់ពន្ធពីអតិថិជន គាត់មិនចាំបាច់យកប្រាក់មកឱ្យខ្លួនពិនិត្យផ្ទាល់ទេ ពីព្រោះបេឡាមានសិទ្ធិទទួល តែបើប្រាក់ច្រើនជាង ៨,០០០,០០០៛ (ប្រាំបីលានរៀល) ទើបត្រូវការឱ្យ checker ត្រួតពិនិត្យពីលើ។ ពេល checker មិននៅទើបខ្លួនមានសិទ្ធិចូលក្នុងប្រព័ន្ធធនាគារ ដើម្បីអនុញ្ញាតឱ្យទឹកប្រាក់ចូលក្នុងប្រព័ន្ធធនាគារ ប្រសិនបើឈ្មោះ [redacted] វឌ្ឍននារីរតន៍ មិនបញ្ចូលប្រាក់ក្នុងប្រព័ន្ធធនាគារទេ ខ្លួនមិនអាចដឹងទេ។ ថ្ងៃដែលខ្លួនដឹងថាឈ្មោះ [redacted] វឌ្ឍននារីរតន៍ មិនបញ្ចូលប្រាក់ក្នុងប្រព័ន្ធធនាគារ និងបាត់ប្រាក់ឈ្មោះ [redacted] សុវណ្ណចរិយា ក៏បានដឹងដែរ។ ហើយពេលឈ្មោះ [redacted] វឌ្ឍននារីរតន៍ បញ្ចូលប្រាក់ពន្ធសងវិញឈ្មោះ [redacted] សុវណ្ណចរិយា ក៏បានដឹង។ តែពេលដែលខ្លួនផ្ញើសារទៅសួរឈ្មោះ [redacted] វឌ្ឍននារីរតន៍ រឿងបាត់ប្រាក់ ឈ្មោះ [redacted] សុវណ្ណចរិយា មិនដឹងទេ។ លើកទី១ ដែលឈ្មោះ [redacted] វឌ្ឍននារីរតន៍ ដាក់ទឹកប្រាក់ពន្ធសងវិញប្រហែលជា ៥លានរៀល នៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០ គឺធ្វើនីតិវិធីធម្មតា បេឡាណាជាអ្នកទទួលប្រាក់នោះខ្លួនមិនដឹង អ្នកណាជាអ្នកអនុញ្ញាតឱ្យដាក់ក៏ខ្លួនមិនដឹងដោយសារថ្ងៃនោះខ្លួនសុំច្បាប់។ តែតាមធម្មតាពេលខ្លួនសុំច្បាប់ក៏មានឈ្មោះ [redacted] សុវណ្ណចរិយា ជាអ្នកអនុញ្ញាត បើឈ្មោះ [redacted] សុវណ្ណចរិយា សុំច្បាប់ គឺមាន senior teller មួយទៀតជាអ្នកអនុញ្ញាត នៅថ្ងៃនោះឈ្មោះ [redacted] សុវណ្ណចរិយា សុំច្បាប់ ឬអត់ខ្លួនមិនដឹង។ តែបើខ្លួន និងឈ្មោះ [redacted] សុវណ្ណចរិយា សុំច្បាប់ផ្ទួនគ្នា គឺមានឈ្មោះ [redacted] សុធារី ម្នាក់ទៀតអ្នកជំនួស។ ខ្លួនមិនបានធ្វើការអនុញ្ញាតទៅលើមូលប្បទានប័ត្រចំនួន០២ ដែលដាក់កាលពីថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២០ នោះទេ បើមានការ

អនុញ្ញាតប្រាកដជាមានហត្ថលេខាខ្លួននៅលើប័ណ្ណដាក់ប្រាក់ធនាគារនោះហើយ ម្យ៉ាងទៀតប្រសិនបើមានការអនុញ្ញាត ប្រាកដជាឃើញមានឈ្មោះរបស់ខ្លួនចូលទៅក្នុងប្រព័ន្ធធនាគារ ដើម្បីអនុញ្ញាតហើយ។ ខ្លួនមិនធ្លាប់អនុញ្ញាតលើប្រតិបត្តិ ការដោយពុំមានបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធជាមួយនឹងប័ណ្ណដាក់ប្រាក់ធនាគារទេ។ ខ្លួនមិនដឹងថា ប្រាក់គេបានដាក់ ចូលគ្រប់វិញហើយ ឬនៅទេ ដោយសារគេមិនបានប្រាប់ខ្លួនទេ។ ខ្លួនធ្លាប់ឆ្លើយថា ថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២០ ថ្នាក់លើ ឱ្យខ្លួនបញ្ចូលមូលប្បទានប័ត្រចំនួន ០២ នោះ គឺច្រឡំ តាមពិតថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២០ ចំណែកថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ ២០២០ ខ្លួនមិនចាំថា ខ្លួនបានអនុញ្ញាត ឬអត់ទេ។ សូមបញ្ជាក់ថាបើប្រាក់លើសពី ៨,០០០,០០០៛ (ប្រាំបីលានរៀល) ទៅត្រូវយកទៅឱ្យ Checker (ឈ្មោះ[redacted] សុវណ្ណចរិយា) គាត់អនុញ្ញាត (Authorize) សិន (អនុញ្ញាតនៅលើប្រព័ន្ធ ធនាគារក្នុងកុំព្យូទ័រ) ពេលគាត់អនុញ្ញាតរួចហើយ ទើបបេឡាអាចចេញបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធនោះឱ្យទៅអតិថិ ជន។ បើប្រាក់ចាប់ពី ៤០,០០០,០០០៛ (សែសិបលានរៀល) ឡើងទៅពេល Checker ពិនិត្យ និងអនុញ្ញាតហើយ គឺត្រូវ ឱ្យខ្លួនត្រួតពិនិត្យម្តងទៀត តែមិនមែនឱ្យខ្លួនចូលក្នុងប្រព័ន្ធកុំព្យូទ័រទៅអនុញ្ញាតម្តងទៀតទេ គឺគ្រាន់តែចូលទៅមើលថា Checker បានចូលទៅក្នុងប្រព័ន្ធធនាគារ និងអនុញ្ញាត (Authorize) រួចហើយ ឬនៅ និងខ្លួនពិនិត្យទៅលើប័ណ្ណដាក់ ប្រាក់ធនាគារជាមួយបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធ បើពិនិត្យឃើញត្រឹមត្រូវហើយ ខ្លួនចុះហត្ថលេខា និងអនុញ្ញាត (Authorize) នៅលើប័ណ្ណដាក់ប្រាក់របស់ធនាគារ ទើបបេឡាអាចចេញបង្កាន់ដៃបង់ប្រាក់ពន្ធនោះឱ្យទៅអតិថិជន។ ពេលយកមកឱ្យខ្លួនត្រួតពិនិត្យនោះ គឺទឹកប្រាក់បានចូលក្នុងប្រព័ន្ធធនាគារអស់ហើយ ដោយសារ Checker បានពិនិត្យ និងអនុញ្ញាតរួចអស់ហើយ។ នៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០ និងនៅថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២០ មានការដាក់ប្រាក់ពន្ធ ចូលក្នុងប្រព័ន្ធធនាគារ ដោយឈ្មោ[redacted] **វណ្ណនារីរតន៍** មែន ប៉ុន្តែក្រោយមកមានការលុបប្រតិបត្តិការនោះចោលវិញ គឺ ខ្លួនជាអ្នកលុប។ ប្រតិបត្តិការដែលឈ្មោះ [redacted] **វណ្ណនារីរតន៍** ដាក់ប្រាក់ពន្ធសងវិញនៅលើកទី១ គឺថ្ងៃទី២៩ ខែមករា ឆ្នាំ ២០២០ ខ្លួនបានលុបនៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០ ហើយនៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០ ខ្លួនបានលុបប្រតិបត្តិការដែល ឈ្មោះ [redacted] **វណ្ណនារីរតន៍** ដាក់ប្រាក់ពន្ធសងវិញកាលពីថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២០ ចោលទៀត ដោយសារថាបង្កាន់ដៃ បញ្ជាក់ការបង់ប្រាក់ពន្ធចំនួន ០២សន្លឹកដែលឈ្មោះ [redacted] **វណ្ណនារីរតន៍** យកប្រាក់ទៅនៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២០ នោះបានចុះចូលក្នុងប្រព័ន្ធពន្ធដារហើយ តែប្រាក់មិនបានចូលក្នុងប្រព័ន្ធធនាគារទេ ហេតុនេះយើងមិនអាចទុកបង្កាន់ដៃ ទាំង ០២សន្លឹកនោះបានទៀតទេ ត្រូវលុបចេញ ដើម្បីកុំឱ្យមានប្រតិបត្តិការជាន់គ្នា ០២ដង កាលពីថ្ងៃទី១៨ ខែមករា ឆ្នាំ ២០២០ ដែលឈ្មោះ [redacted] **វណ្ណនារីរតន៍** បានចេញបង្កាន់ដៃបញ្ជាក់ការបង់ពន្ធឱ្យគេហើយ។ ជាទូទៅខ្លួន និងឈ្មោះ [redacted] **សុវណ្ណចរិយា** មានសិទ្ធិលុបប្រតិបត្តិការដោយឯករាជ្យ ហើយប្រត្តិការទឹកប្រាក់ដែលខ្លួនលុបនេះ ខ្លួនដឹងថាជាប្រាក់ដែលេ ឈ្មោះ[redacted] **វណ្ណនារីរតន៍** យកប្រាក់អតិថិជនហើយមិនទាន់បញ្ចូលទៅក្នុងប្រព័ន្ធធនាគារ។ ពេលលុបប្រតិបត្តិការនោះ ខ្លួនក៏បានស្នើសុំបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធពីក្រុមហ៊ុន គ័ន ហ៊្គង ខនស្រ្តាក់សិន (ខេមបូឌា) ឯ.ក ដែរ។ ខ្លួនមានសិទ្ធិ លុបដោយមិនចាំបាច់ឆ្លងកាត់ការអនុញ្ញាតពីថ្នាក់លើរបស់ខ្លួនទេ។ កន្លងមកខ្លួនតែងតែលុបប្រសិនបើការមានការធ្វើខុស។ ប្រតិបត្តិការចំនួន ០២ដង ដែលខ្លួនលុប គឺខ្លួនដឹងថាជាប្រតិបត្តិការពាក់ព័ន្ធប្រាក់ចំនួន ៦លានដុល្លាអាមេរិកជាង គឺដោយសារ ឈ្មោះ [redacted] វណ្ណនារីរតន៍ បានដាក់ប្រាក់បង់ពន្ធចូល រួចផ្ញើសារប្រាប់ខ្លួនថា បានដាក់ចូលឱ្យខ្លួនមើលមានជាបង្កាន់ដៃ និងអ្នកធ្វើប្រតិបត្តិការផងដែរ។ ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២០ ទើបមានការបញ្ជាពីថ្នាក់លើមកឱ្យដាក់ប្រាក់បញ្ចូល។



Scanned with CamScanner

-ជនជាប់ចោទឈ្មោះ [redacted] ហៀង បានឆ្លើយថា៖ ខ្លួនជាសន្តិសុខទៅធនាគារកាណាឌីយ៉ា អ.ក តាំងពីឆ្នាំ២០០២ រហូតដល់បច្ចុប្បន្ន មានតួនាទីបើកបររថយន្ត លីស៊េង ចែកឯកសារគ្រប់ទាំង ២៨ជាន់ កន្លែងដែលគេឱ្យខ្លួនទៅ គឺនៅជាន់ទី១ (ជាន់ផ្ទាល់ដី) ជាមួយអ្នកបើកឡានផ្សេងទៀត គឺវាលគ្មានបន្ទប់ទេ។ ខ្លួនមានសិទ្ធិឡើងចុះគ្រប់ជាន់រាល់ថ្ងៃ ពីព្រោះខ្លួនជាអ្នកយកឯកសារចែកឱ្យគេតាមជាន់។ ខ្លួនស្គាល់ឈ្មោះ [redacted] **វណ្ណនារីរតន៍** ពីព្រោះគាត់ជាបុគ្គលិកធនាគារកាណាឌីយ៉ា អ.ក គាត់ធ្វើការនៅជាន់ទី៥។ បន្ទប់ធ្វើការរបស់ឈ្មោះ [redacted] **វណ្ណនារីរតន៍** ខ្លួនអាចចេញចូលបាន ពេលខ្លួនយកឯកសារឱ្យគាត់។ ឈ្មោះ [redacted] **ស៊ីមន្ថា** ខ្លួនធ្លាប់ឃើញគាត់អង្គុយចាំយកប្រពន្ធគាត់ ហើយគាត់ជាប្ដីរបស់ឈ្មោះ [redacted] **វណ្ណនារីរតន៍** តែខ្លួនមិនស្គាល់គាត់ទេ។ ឈ្មោះ [redacted] **សុវណ្ណចរិយា**, ឈ្មោះ [redacted] **រចនា** និងឈ្មោះ **ឃោង សុផាយ** ខ្លួនស្គាល់ពួកគាត់។ ឈ្មោះ [redacted] **បញ្ញាសុជាតា** ខ្លួនក៏ស្គាល់ គាត់ធ្លាប់ជាអតីតបុគ្គលិកធនាគារកាណាឌីយ៉ា អ.ក។ ថ្ងៃទី១៨ ខែមករា ឆ្នាំ២០២០ ខ្លួនធ្លាប់ជួយជញ្ជូនអីវ៉ាន់របស់អតិថិជនទៅដាក់ជាន់ទី៥ បន្ទប់ទទួលភ្ញៀវ រួចក៏ចុះមកវិញដោយអីវ៉ាន់នោះគាត់ដាក់ក្នុងថង់ខ្មៅចំនួន ៣ថង់ ហើយអតិថិជននោះជាមនុស្សស្រីក្មេងៗមិនចាំមុខ ក៏មិនដែលស្គាល់ដែរ។ ខ្លួនជញ្ជូនអីវ៉ាន់ថង់ខ្មៅនោះទៅជាមួយអតិថិជន និងសន្តិសុខ ០២នាក់ទៀត ខ្លួនមិនចាំថាមាននរណាទៀតទៅជាមួយទេ។ ខ្លួនមិនដឹងថាក្នុងថង់ខ្មៅនោះជាអ្វីទេ ហើយការជួយជញ្ជូននេះ ខ្លួនក៏មិនបានអ្វីពីឈ្មោះ [redacted] **វណ្ណនារីរតន៍** ដែរ គាត់ជាអ្នកពឹងខ្លួនឱ្យជួយជញ្ជូន។ កន្លងមកឈ្មោះ [redacted] **វណ្ណនារីរតន៍** ធ្លាប់ឱ្យខ្លួនយកអីវ៉ាន់ទៅឱ្យបុគ្គលិកគ្នាគាត់ តែមិនដឹងថាជាអ្វីនោះទេ។ ហើយខ្លួនមិនចាំថា ឈ្មោះ [redacted] **វណ្ណនារីរតន៍** ធ្លាប់ឱ្យខ្លួនយកប្រាក់ទៅប្ដូរឱ្យ ឬអត់នោះទេ។ មនុស្សស្រីក្នុងកាមេរ៉ាសុវត្ថិភាពដែលដើរកាត់ខ្លួនពេលជញ្ជូនថង់ខ្មៅមិនដឹងអ្នកណាទេ។ ថង់ខ្មៅចំនួន ០៣នោះ គេទុកនៅជាន់ផ្ទាល់ដី ហើយឈ្មោះ [redacted] **វណ្ណនារីរតន៍** ឱ្យខ្លួនយកទៅជាន់ទី៥។ អ្នកណាមកយកថង់ខ្មៅ ០៣នោះខ្លួនមិនដឹង។ អ្នកដែលចាប់មកជាមួយខ្លួនទាំងអស់មិនដែលឱ្យអ្វីមកខ្លួនទេ។ ខ្លួនធ្លាប់តែទទួលប្រាក់ថ្លៃជួយទិញបាយទឹកឱ្យឈ្មោះ [redacted] **វណ្ណនារីរតន៍** ប្រហែល ១សប្ដាហ៍ ឬ ១ខែម្ដង ដើម្បីយកសងអ្នកលក់បាយ មិនដែលទទួលប្រាក់ផ្សេងទេ។ ថ្ងៃទី១៨ ខែមករា ឆ្នាំ២០២០ ក្រោយពីជញ្ជូនថង់ខ្មៅទាំង ០៣ទៅជាន់ទី៥ ហើយឈ្មោះ [redacted] **វណ្ណនារីរតន៍** ក៏បានហៅខ្លួនទៅយកថង់ខ្មៅមួយទៀតនៅកន្លែងធ្វើការគាត់ គាត់ឱ្យខ្លួនជួយយកមកទុកនៅខាងក្រោម ចាំគាត់ចេញទៅផ្ទះ ចាំគាត់មកយក គាត់មិនបានប្រាប់ថាជាអ្វីទេ ហើយពេលទៅយកថង់ខ្មៅនោះ ខ្លួនមិនចាំថាគាត់បានឱ្យប្រាក់ ២២៥$ (ពីរយម្ភៃប្រាំដុល្លារអាមេរិក) មកខ្លួន ឬអត់ទេ។ ខ្លួនមានប្រពន្ធ និងកូន ០២នាក់ ប្រពន្ធខ្លួនជាមន្ត្រីនៅក្នុងសាលាសង្កាត់ ហើយចំណូលខ្លួនទទួលបានប្រាក់ខែពីការងារសន្តិសុខចន្លោះ ៣០០$ (បីរយដុល្លារអាមេរិក) ជាងជិត ៤០០$ (បួនរយដុល្លារអាមេរិក)។ ខ្លួនឆ្លៀតជួយទិញបាយទឹកឱ្យគេ ដើម្បីដោះស្រាយជីវភាព។ ខ្លួនធ្លាប់ជួយជូនឈ្មោះ [redacted] **បញ្ញាសុជាតា** ទៅក្រុមហ៊ុន លី ហួរ ប្ដូរប្រាក់ ពេលនោះខ្លួនជួបគាត់ដោយចៃដន្យ ហើយពេលនោះខ្លួនជិះម៉ូតូម៉ាកឌ្រីម ពណ៌ក្រហម គាត់ក៏ពឹងឱ្យជូនគាត់ទៅប្ដូរប្រាក់ ពេលដាក់គាត់ចុះនៅក្រុមហ៊ុន លី ហួរ ប្ដូរប្រាក់ ហើយខ្លួនក៏ទៅផ្ទះវិញ ដោយខ្លួនមិនបានទទួលអ្វីពីឈ្មោះ [redacted] **បញ្ញាសុជាតា** ទេ។ មុនពេលខ្លួនជញ្ជូនថង់ខ្មៅទៅជាន់ទី៥ ខ្លួនមិនចាំថាបានជួបឈ្មោះ [redacted] **បញ្ញាសុជាតា** ឬអត់ទេ ហើយ



Scanned with CamScanner

ឈ្មោះ [redacted] បញ្ញាសុជាតា ក៏មិនបានទាក់ទងមកខ្លួនមុនដែរ។ គ្មានអ្នកណាពឹងខ្លួនឱ្យជួយជញ្ជូនទេ ពេលនោះខ្លួនឃើញអតិថិជនដាក់អីវ៉ាន់ខ្លួនក៏ជួយជញ្ជូន។ ពេលជញ្ជូនថង់ខ្មៅទៅជាន់ទី៥ នោះ ខ្លួនមិនចាំថាបានជួបឈ្មោះ [redacted] បញ្ញាសុជាតានៅកន្លែងណាទេ ហើយថង់ខ្មៅនោះក៏ខ្លួនមិនចាំថាយកទៅទុកបន្ទប់ណានៃជាន់ទី៥ ដែរ។ ពេលខ្លួនយកអីវ៉ាន់ទៅទុកនៅជាន់ទី៥ ហើយ ខ្លួនមិនចាំថាខ្លួនចុះមកវិញជាមួយសន្តិសុខ ០២នាក់ទៀត ឬអត់ទេ។ ពេលទុកថង់ខ្មៅក្នុងបន្ទប់ជាន់ទី៥នោះហើយ ខ្លួនក៏បានយកថង់ខ្មៅនោះទៅទុកនៅបន្ទប់មួយទៀត មាននារីម្នាក់នៅក្នុងបន្ទប់នោះ តែមិនចាំថាជាអ្នកណាទេ។ ខ្លួនធ្លាប់ទិញដីបង់រំលោះមិនចាំទិញឆ្នាំណាទេ។ នៅក្នុងធនាគារខ្លួនធ្វើទាំងអស់ឱ្យតែគេប្រាប់ ហើយខ្លួនធ្លាប់លីប្រាក់ ឡើងទៅលើដែរ ពេលជួយលើកអីវ៉ាន់គេ គេមិនដែលប្រាប់ថាជាអ្វីនោះទេ គឺគេគ្រាន់តែឱ្យលើក។ នៅថ្ងៃកើតហេតុឈ្មោះ [redacted] ស៊ីមន្ថា មិនដែលបានមកយកថង់ខ្មៅពីខ្លួនទេ ហើយក៏មិនបានដឹងថាឈ្មោះ [redacted] ស៊ីមន្ថា យកថង់ខ្មៅចេញពីធនាគារដែរ។

-លោកមេធាវី [redacted] មុនី ជាមេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណីបានឆ្លើយថា៖ តួនាទីក្នុងធនាគារកាណាឌីយ៉ា អ.ក ដែលជនជាប់ចោទទាំងអស់ឆ្លើយ គឺត្រឹមត្រូវ។ ឈ្មោះ [redacted] សុរាយ គឺជាអ្នកគ្រប់គ្រងប្រព័ន្ធស្នូលរបស់ធនាគារទាំងមូលតែម្តង គឺគាត់កាន់ផ្នែកព័ត៌មានវិទ្យា (IT) ទាំងមូលក្នុងធនាគារគ្រប់ផ្នែក ហើយគាត់អាចកែកបាននៅពេលដែលគាត់ត្រូវបានមេអនុញ្ញាត គាត់នៅក្រោមតែ Head of IT ម្នាក់ទេ។ ឈ្មោះ [redacted] សុវណ្ណចរិយា មានតួនាទីត្រួតពិនិត្យ និងអនុម័តក្នុងប្រព័ន្ធ រាល់ថ្ងៃចុងម៉ោង គឺគាត់មានព្រឹនរបាយការណ៍ឱ្យបេឡា។ នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២០ ពិតជាមិនបានបញ្ចូលប្រាក់ពន្ធដែលទទួលពីក្រុមហ៊ុន ត័ន ហ្គ័ង ខនស្រ្តាក់សិន (ខេមបូឌា) ឯ.ក ទៅក្នុងប្រព័ន្ធធនាគារមែន ទើបមិនមានប្រាក់ចូលក្នុងធនាគារទេ។ ជាគោលការណ៍រាល់ប្រតិបត្តិការទាំងអស់របស់ប្រព័ន្ធទាំង០២ ទាំងពន្ធដារ និងធនាគារ អ្នកគ្រប់គ្រងត្រូវតែដឹង ពីព្រោះពេលទឹកប្រាក់ចូលក្នុងប្រព័ន្ធរបស់ពន្ធដារ ត្រូវការអ្នកអនុញ្ញាតដែលជាអ្នកពាក់ព័ន្ធផ្សេងទៀត ដូចបានជម្រាបពីខាងដើមមុនពេលចេញបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធ ហើយពេលចេញរួចហើយ អ្នកគ្រប់គ្រងត្រូវផ្ទៀងផ្ទាត់ចុងម៉ោងលើបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធ។ នៅក្រៅពីដើមខែមករា ឆ្នាំ២០២០ គាត់បានយកប្រាក់ផ្សេងទៀត មិនមែនត្រឹមតែ ៦លានដុល្លារអាមេរិកទេ។ ចំពោះប្រាក់ ៥៣០,០០០$ (ហាសិបបីម៉ឺនដុល្លារអាមេរិក) នោះមិនមែនជាប្រាក់នៅក្នុងប្រាក់ ៦លានដុល្លារអាមេរិកនោះទេ គឺជាប្រាក់ដែលធនាគាររកឃើញដំបូងថាមានការយកប្រាក់ចេញពីធនាគារនៅពេលដាក់ពាក្យបណ្តឹង។ នៅក្នុងរឿងនេះធនាគារប្តឹងពាក់ព័ន្ធនឹងប្រាក់ចំនួន ៦,១៦០,០០០$ (ប្រាំមួយលានដប់ប្រាំមួយម៉ឺនដុល្លារអាមេរិក) ដែលជនជាប់ចោទបានយកនៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២០ ប៉ុណ្ណោះ។ ក្នុងរឿងនេះខាងធនាគារសុំទាមទារជម្ងឺចិត្តពីជនជាប់ចោទទាំងអស់គ្នាចំនួន ៥០០,០០០$ (ហាសិបម៉ឺនដុល្លារអាមេរិក) ហើយខាងធនាគារមិនទាមទារប្រាក់ចំនួន ៦,១៦០,០០០$ (ប្រាំមួយលានដប់ប្រាំមួយម៉ឺនដុល្លារអាមេរិក) ដែលជនជាប់ចោទទាំងអស់គ្នាបានយកចេញទេ ដោយសារជនជាប់ចោទបានសងត្រឡប់មកធនាគារអស់ហើយ។ ដោយសងចំនួន ០៣លើក លើកទី០១ ថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០, លើកទី២ ថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២០ និងលើកទី៣ ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២០។ ពេលគាត់ដាក់ប្រាក់សងលើកទី១ និងលើកទី២ ខាងធនាគារមិនទាន់ដឹងរឿងបាត់ប្រាក់ទេ ទាល់តែគាត់ដាក់លើកទី៣ ទើប



Scanned with CamScanner

ខាងធនាគារដឹង និងបង្គាប់ឱ្យខាងជនជាប់ចោទដាក់ប្រាក់ឱ្យចូលសងឱ្យគ្រប់ចំនួនវិញ។ ពេលដាក់ប្រាក់សងលើកទី១ គឺ មានឈ្មោះ[redacted]សំណាង ជាអ្នកយកមកដាក់នៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០ ដាក់នៅធនាគារកាណាឌីយ៉ា អ.ក ដាក់ជា មូលប្បទានប័ត្រមានទឹកប្រាក់ ២៥០,៥៣៩,៤៣៩៛ (ពីររយហាសិបលានប្រាំរយសាមសិបប្រាំបួនពាន់បួនរយសាមសិប ប្រាំបួនរៀល) ហើយទឹកប្រាក់ដែលដាក់នេះ គឺជាប្រាក់ដើម្បីបង់ពន្ធឱ្យក្រុមហ៊ុន ត័ន ហ៊្វុង ខនស្រ្តាក់សិន ឯ.ក ដោយមាន ប្រតិបត្តិការបញ្ចូលតាមនីតិវិធីធម្មតា និងមានបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធ ០០៤៦១៧៨៤ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ ២០២០ មានឈ្មោះ [redacted] ធារី ជាបេឡាជាអ្នកទទួល និងមានឈ្មោះ [redacted] សុវណ្ណចរិយា ជាអ្នកត្រួតពិនិត្យ អនុញ្ញាត និងចុះ ហត្ថលេខា ថ្ងៃនោះឈ្មោះ [redacted]រចនា សុំច្បាប់។ សូមបញ្ជាក់ថាមានប្រតិបត្តិការដាក់ប្រាក់សងនៅថ្ងៃទី២៩ ខែមករា ឆ្នាំ ២០២០ ត្រូវបានលុបវិញនៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០ ហើយអ្នកដែលអាចលុបបានមានតែឈ្មោះ[redacted] រចនា ទេ សំដៅប្រតិបត្តិការដែលឈ្មោះ[redacted]សំណាង យកមកដាក់។ លើកទី២ ថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២០ អ្នកយកមកប្រាក់ដាក់ សង គឺឈ្មោះ[redacted] បញ្ញាសុជាតា ដោយមានឈ្មោះ [redacted]ផ្សនទាវីរតន៍ ជាអ្នកចេញបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធ ០០៤០៤៥៧៦០ ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២០ និងចុះហត្ថលេខាតែឯងភ្ជាប់ជាមួយមូលប្បទានប័ត្រ ២សន្លឹក ប្រតិបត្តិ ការនេះជាប្រតិបត្តិការប្រក្រតី តែមិនដឹងអ្នកអនុញ្ញាត។ បន្ទាប់មកថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០ ប្រតិបត្តិការថ្ងៃទី០៧ ខែ កុម្ភៈ ឆ្នាំ២០២០ នេះត្រូវបានលុប ហើយអ្នកមានសិទ្ធិលុប គឺមានតែឈ្មោះ[redacted]រចនា ទេ។ ចំពោះប្រតិបត្តិការលើកចុង ក្រោយ ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២០ គឺខាងធនាគារអ្នកអនុញ្ញាតិឱ្យដាក់។ ការសងនៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០ និង ថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២០ ខាងធនាគារមិនទាន់បានដឹងរឿងថាមានការយកប្រាក់បង់ពន្ធចេញទៅខាងក្រៅនោះទេ អីចឹង ហើយការធ្វើប្រតិបត្តិការដាក់ប្រាក់ចូលវិញនេះគឺ ជនជាប់ចោទទាំងអស់ដែលពាក់ព័ន្ធជាអ្នកប្រតិបត្តិការ។ រហូតនៅថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ២០២០ ដែលមានប្រតិបត្តិការចំនួន ៣លើក នៅថ្ងៃនោះដោយសារមានការដាក់ ២លើកមុនមិនទាន់គ្រប់ចំនួន ទើបថ្នាក់ដឹកនាំជាន់ខ្ពស់របស់ធនាគារបានបង្គាប់ឱ្យផ្នែកពន្ធដាក់ប្រាក់ចូលឱ្យគ្រប់ចំនួន។ ធនាគារកាណាឌីយ៉ា អ.ក ដឹងរឿង បាត់ប្រាក់នៅថ្ងៃទី១០ដាង ខែកុម្ភៈ ឆ្នាំ២០២០ ហើយខាងធនាគារបានហៅបុគ្គលិកផ្នែកបង់ពន្ធទៅសាកសួរម្តងម្នាក់ៗ ពេល សួររួច គឺមិនបានឱ្យត្រឡប់មកធ្វើការនៅការិយាល័យបង់ពន្ធទៀតទេ។ សូមបញ្ជាក់ថាការលុបប្រតិបត្តិការនៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០ ធនាគារពិនិត្យឃើញថា មានការលុបប្រតិបត្តិការដែលបានធ្វើនៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០ តាមរយៈបង្កាន់ ដៃមួយសន្លឹកដែលបានសរសេរថាបញ្ជាក់ថា Cancel និងបានសរសេរថា wrong company name ហើយអ្នកដែលអាច លុប និងមានគណនីសម្រាប់ប្រើប្រាស់លុប គឺមានតែឈ្មោះ [redacted]ចនា ទេ។ ប្រសិនបើមានការចូលក្នុងប្រព័ន្ធរបស់ពន្ធ ដារដោយមិនបានដាក់ប្រាក់ចូលក្នុងប្រព័ន្ធធនាគារទេ ឈ្មោះ [redacted]សុវណ្ណចរិយា និងឈ្មោះ [redacted]ចនា អាចមិនដឹងទេ។

## សេចក្តីសន្និដ្ឋានការពាររបស់មេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី

-លោកមេធាវី [redacted]នុទី ជាមេធាវីការពារតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើសេចក្តីសន្និដ្ឋានថា៖ ឆ្លងតាម ការសួរដេញដោលនាពេលសវនាការ និងការពិនិត្យឯកសារភស្តុតាងដែលបានដាក់ជូនតុលាការ ឃើញថា ជនជាប់ចោទ

ទាំងអស់ពិតជាបានប្រព្រឹត្តបទល្មើសរំលោភលើទំនុកចិត្តក្នុងការចោទប្រកាន់របស់តំណាងអយ្យការពិតប្រាកដមែន។ អំពើនេះធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ធនាគារកាណាឌីយ៉ា អ.ក យ៉ាងធ្ងន់ធ្ងរ ដោយសារជនជាប់ចោទទាំងអស់នេះបានកិបកេងប្រាក់បង់ពន្ធរបស់អតិថិជនដែលយកមកបង់តាមរយៈធនាគារកាណាឌីយ៉ា អ.ក ហើយប្រសិនបើធនាគារមិនបានដឹងព័ត៌មានអំពីរឿងប្រាក់ពន្ធនេះទេ ជនជាប់ចោទទាំងអស់នេះនឹងមិនយកប្រាក់នោះមកឱ្យធនាគារវិញឡើយ ហើយម្យ៉ាងទៀតជនជាប់ចោទទាំងអស់នេះបានយកប្រាក់ពន្ធនេះទៅបែងចែកជាចំណែកជាច្រើន ទោះបីជាបានដាក់ចូលក្នុងធនាគារកាណាឌីយ៉ា អ.ក វិញគ្រប់ចំនួន ក៏ប៉ុន្តែសកម្មភាពរបស់ជនជាប់ចោទទាំងអស់ពិតជាបានធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ផលប្រយោជន៍របស់ធនាគារ។ អំពើរបស់ជនជាប់ចោទទាំងអស់នេះ គឺជាអំពើរំលោភទំនុកចិត្តពិសេសដោយអភិបាល ឬបុគ្គលផ្សេងទៀត ដូចចែងក្នុងមាត្រា ៣៩៣ នៃក្រមព្រហ្មទណ្ឌ ក៏ដូចជាមាត្រា២៩ នៃក្រមព្រហ្មទណ្ឌ ដែលចែងពីនិយមន័យនៃការសមគំនិត។ ដូច្នេះក្នុងនាមខ្លួនជាមេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី ស្នើសុំឱ្យលោកស្រីចៅក្រមមេត្តាផ្តន្ទាទោសទៅលើជនជាប់ចោទទាំងអស់ឱ្យបានធ្ងន់ធ្ងរទៅតាមនីតិវិធីច្បាប់ និងសុំឱ្យតុលាការបង្គាប់ជនជាប់ចោទទាំងនេះរួមគ្នាសងសំណងជម្ងឺចិត្តមកដើមបណ្តឹងរដ្ឋប្បវេណីជាប្រាក់សរុបចំនួន ៥០០,០០០$ (ហាសិបម៉ឺនដុល្លារអាមេរិក)។

## សេចក្តីសន្និដ្ឋានថ្លែងសុំរបស់តំណាងអយ្យការ

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា៖ ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានមេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី តំណាងអយ្យការស្នើសុំធ្វើការសន្និដ្ឋានពាក់ព័ន្ធនឹងអង្គហេតុ ដោយផ្តើមចេញពីឈ្មោះ [redacted] **វឌ្ឍនធារីរតន៍** ដែលបានកិបកេងប្រាក់របស់ធនាគារកាណាឌីយ៉ា អ.ក ដោយបានយកប្រាក់ពន្ធដែលអតិថិជនមកបង់ពន្ធគេចវេសយកចេញទៅខាងក្រៅធនាគារ ហើយនៅក្នុងសកម្មភាពនេះ គឺមានប្តីរបស់ជនជាប់ចោទឈ្មោះ [redacted] **ស៊ីមន្ថា** បានចូលរួមយកប្រាក់ពន្ធនោះចេញពីអគារធនាគារកាណាឌីយ៉ា អ.ក ហើយសកម្មភាពនេះផងដែរក៏មានការចូលរួមពីឈ្មោះ [redacted] **ហៀង** ដែលបានសម្រួលយកប្រាក់ទៅប្តូរ ក៏ដូចជាការដឹកជញ្ជូនប្រាក់ ហើយពាក់ព័ន្ធនឹងសកម្មភាពនៅក្នុងប្រព័ន្ធអេឡិចត្រូនិច គឺមានឈ្មោះ [redacted] **សុវណ្ណចរិយា**, ឈ្មោះ [redacted] **សុភាយ** និងឈ្មោះ [redacted] **រចនា** ដែលបានបញ្ចូលក៏ដូចជាការលុបទិន្នន័យនៅក្នុងប្រព័ន្ធអេឡិចត្រូនិច។ សកម្មភាពនេះផងដែរក៏មានការចូលរួមពីឈ្មោះ [redacted] **បញ្ញាសុជាតា** ដោយជនជាប់ចោទនេះបានធ្វើកម្មសភាពយកប្រាក់ពន្ធទៅប្តូរ។ យើងឃើញថា សកម្មភាពនេះ គឺទទួលបានលាភសក្ការៈទាំងអស់គ្នា ដែលបញ្ជាក់បានថា ជនជាប់ចោទទាំងអស់គ្នាមានចេតនាទុច្ចរិតក្នុងការប្រព្រឹត្តបទល្មើសរំលោភលើទំនុកចិត្តក្នុងការចោទប្រកាន់ ហេតុដូច្នេះដោយសារមានភស្តុតាង និងធាតុផ្សំគ្រប់គ្រាន់ដាក់បន្ទុកទៅលើជនជាប់ចោទទាំងអស់ តំណាងអយ្យការស្នើសុំតម្កល់បទចោទប្រកាន់ និងស្នើសុំឱ្យតុលាការសម្រេចវិនិច្ឆ័យលើជនជាប់ចោទតាមកំណត់ច្បាប់។

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-លោកមេធាវី [redacted] **សុគន្ធ** ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **វឌ្ឍនធារីរតន៍** និងឈ្មោះ [redacted] **ស៊ីមន្ថា** បានធ្វើសេចក្តីសន្និដ្ឋានការពារថា៖ ទី១. ចំពោះជនជាប់ចោទឈ្មោះ [redacted] **ស៊ីមន្ថា** នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២០ វេលាម៉ោងប្រហែលជា ១០ជាង ទៅ ១១នាទីនោះ គាត់បានទៅយកប្រពន្ធរបស់គាត់ឈ្មោះ [redacted] **វឌ្ឍនធារីរតន៍** នៅស្នាក់



Scanned with CamScanner

ការកណ្តាលធនាគារកាណាឌីយ៉ា អ.ក នៅពេលទៅដល់ប្រពន្ធរបស់គាត់បានឱ្យគាត់ឡើងទៅលើជួយយកអីវ៉ាន់ ហើយពេលឡើងទៅដល់ប្រពន្ធគាត់បានឱ្យគាត់ឡើងទៅយកថង់ខ្មៅចំនួន ០៣ថង់ចុះមកក្រោម ដោយគាត់យកម្តង ០១ថង់ៗមកដល់ឡានហើយទើបប្រពន្ធរបស់គាត់ចុះមកដល់តាមក្រោយ។ ពេលចូលក្នុងឡានហើយទើបប្រពន្ធរបស់គាត់ប្រាប់ថានៅក្នុងថង់ខ្មៅនោះជាប្រាក់យកទៅប្តូរ មានន័យថានៅពេលដំបូងគាត់មិនដឹងថាជាប្រាក់ទេ នៅពេលចូលដល់ក្នុងឡានហើយទើបប្រពន្ធគាត់ប្រាប់ថាប្រាក់យកទៅប្តូរសម្រាប់បង់ពន្ធ ហើយគាត់ក៏មិនបានសួរនាំអ្វីទៀតដែរ និងបានដឹកប្រពន្ធទៅផ្ទះ និងបានយកឡានទៅទុកចោលដោយមិនបានប្រើប្រាស់ទេ ហើយដោយសាររវល់ចុះមូលដ្ឋានក៏បានប្រើប្រាស់ឡានផ្សេងទៀត។ នៅក្នុងនេះឈ្មោះ[redacted]ស៊ីមន្តា មិនមានចេតនាក្នុងការកិបកេងបំបាត់ប្រាក់របស់ធនាគារកាណាឌីយ៉ា អ.ក ទេ ក៏មិនបានសមគំនិតជួយសម្រួលជាមធ្យោបាយដឹកជញ្ជូនទាំងដឹងរឿងហើយដើម្បីជាប្រយោជន៍របស់គាត់ដែរ។ នៅក្នុងរឿងនេះដូចគាត់បានបញ្ជាក់ហើយ ជនជាប់ចោទផ្សេងទៀតក៏មិនបានស្គាល់គាត់ច្បាស់ដែរ ដូចលោកស្រីចៅក្រម និងលោកព្រះរាជអាជ្ញារងបានសួររួចហើយ ហើយការឆ្លើយរបស់គាត់ខុសបន្តិចត្រង់ថា មិនបាននិយាយពាក្យ "សួស្តី"។ ម្យ៉ាងទៀតគាត់ធ្វើការនៅក្រសួងផ្សេងមិនមានការពាក់ព័ន្ធអ្វីទៅនឹងធនាគារកាណាឌីយ៉ា អ.ក ទេ តែប្រពន្ធគាត់ធ្វើការនៅធនាគារកាណាឌីយ៉ា អ.ក បានប្រាប់ឱ្យជួយដឹកអីវ៉ាន់មិនបានដឹងថាជាប្រាក់ទេ ពេលដឹងថាប្រាក់បង់ពន្ធ ក៏មិនបានសួរថាយកទៅបង់ពន្ធនៅកន្លែងណាអីនោះទេ។ គាត់ធ្លាប់បានប្តឹងនឹងដីកាសម្រេចឃុំខ្លួនរបស់គាត់ទៅដល់តុលាការកំពូល ហើយតុលាការកំពូលបានឱ្យគាត់នៅក្រៅឃុំ ដោយយល់ឃើញថាព្យសនកម្មដែលគាត់ធ្វើមកយកប្រាក់ធនាគារកាណាឌីយ៉ា អ.ក ចេញទៅខាងក្រៅនេះ គឺបានយកមកសងមកធនាគារកាណាឌីយ៉ា អ.ក វិញអស់ហើយ គឺមិនមានព្យសនកម្មអ្វីទៀតទេ។ គាត់ ០២នាក់ប្តីប្រពន្ធត្រូវជាប់គុកទាំង ០២នាក់ ពុំមានអ្នកណាមើលកូនតូច មានតែម្តាយចាស់ជរាមើល ហេតុនេះតុលាការកំពូលក៏បានសម្រេចឱ្យគាត់នៅក្រៅឃុំ ដោយបានយល់ឃើញថា ឈ្មោះ [redacted]ស៊ីមន្តា មិនមានគំនិតទុច្ចរិតទៅលើការសមគំនិតដូចការចោទប្រកាន់របស់តំណាងអយ្យការចោទនោះទេ។ ខ្ញុំសូមសំណូមពរសុំឱ្យលោកស្រីចៅក្រមសម្រេចឱ្យឈ្មោះ [redacted] ស៊ីមន្តា រួចខ្លួនពីបទចោទ បទសមគំនិតក្នុងអំពើរំលោភទំនុកចិត្តពិសេសដោយអភិបាល និងបុគ្គលផ្សេងទៀត។ ទី២. ចំពោះជនជាប់ចោទឈ្មោះ [redacted]វណ្ណនារីរតន៍ គាត់ជាបុគ្គលិករបស់ធនាគារកាណាឌីយ៉ា អ.ក។ គាត់បានទទួលស្គាល់ថា គាត់ពិតជាបានចង់ចំណេញក្បាលកាក់ ដើម្បីយកប្រាក់ទៅប្តូរ តែប្រាក់នៅក្នុងធនាគារមិនមែនគ្មានកន្លែងប្តូរទេ ប៉ុន្តែការប្តូរនៅក្នុងធនាគារបានអត្រាទាបជាងនៅខាងក្រៅធនាគារ ដែលធ្វើឱ្យគាត់មានគំនិតថា បើប្តូរនៅខាងក្រៅចំណេញបានច្រើនជាង ទើបគាត់យកប្រាក់នោះទេប្តូរនៅខាងក្រៅ ដើម្បីបានក្បាលកាក់ នៅពេលដែលគាត់យកប្រាក់ចេញទៅហើយហេតុអ្វីបានជាប្រាក់នោះទុកយូរ គឺដោយសារនៅពេលដែលគាត់យកប្រាក់ចេញទៅថ្ងៃសៅរ៍ ហើយអត្រាប្តូរប្រាក់មានការឡើង និងចុះ នៅពេលដែលយកប្រាក់ទៅដល់ផ្ទះ គាត់សួរហាងឆេងទៅប្រាក់ធ្លាក់ថ្លៃ ធ្វើឱ្យគាត់ខាត ធ្វើឱ្យគាត់មានគំនិតមួយទុកឱ្យឡើងថ្លៃវិញសិនទើបយកទៅប្តូរ តែទុកៗទៅហាងឆេងឡើងមិនទាន់ដល់គ្រប់ផង ក៏មានកម្មវិធីដើរលេងនៅអឺរ៉ុប គាត់ក៏បានទៅដើរលេងធ្វើឱ្យមានការខកក្នុងការបង់ប្រាក់នោះ។ ខ្ញុំសុំសួរថា តើគាត់មានគំនិតទុច្ចរិតថាយកប្រាក់នោះជារបស់ខ្លួន ឬអត់? គាត់មិនមានគំនិតនេះទេ ដូចខាងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងថា នៅថ្ងៃទី១០ជាង ខែកុម្ភៈ ឆ្នាំ២០២០ អ៊ីចឹងសួរថា តើឈ្មោះ [redacted] វណ្ណនារីរតន៍ ប្តូរប្រាក់ពីថ្ងៃណាមក អ៊ីចឹងគ្រាន់តែឈ្មោះ [redacted] រចនា សួរទៅគាត់នៅក្រៅប្រទេស គាត់ក៏បានឱ្យឈ្មោះ[redacted]បញ្ញាសុជាតា ទៅប្តូរប្រាក់តាំងពីថ្ងៃទី

២៨, ២៩ ខែមករា ឆ្នាំ២០២០ ដើម្បីយកមកដាក់ចូលធនាគារកាណាឌីយ៉ា អ.ក វិញជាង ៤លានដុល្លារអាមេរិក ទៅ ៥លានដុល្លារអាមេរិក រួចហើយ បើគាត់មានគំនិតទុច្ចរិតយកប្រាក់នោះ គាត់មានអីត្រូវឱ្យយកប្រាក់ទៅប្ដូរ ពីព្រោះធនាគារអត់ទាន់ដឹងផង ទើបតែឈ្មោះ [redacted] វឌ្ឍនា ទូរស័ព្ទទៅប្រាប់គាត់ នេះជាចំណុចមួយ។ ចំណុចមួយទៀត គាត់នៅតែព្យាយាមប្ដូរដោយសារប្រាក់នោះមិនទាន់គ្រប់ចំនួន ប្រាក់រៀលច្រើនពេក ក្រុមហ៊ុន លី ហួរ ប្ដូរប្រាក់ មានមិនគ្រប់ គាត់បានព្យាយាមប្ដូរប្រាក់នេះរហូតដល់ ០៣លើក ហើយប្រាក់ដែលបានយកចេញនេះបានយកបង់ចូលធនាគារកាណាឌីយ៉ា អ.ក វិញអស់ហើយ គាត់មិនបានគៃបំបាត់ទេ ប៉ុន្តែអ្វីដែលគាត់ខុស គឺគាត់ខុសបទបញ្ជាផ្ទៃក្នុង និងលក្ខន្តិកៈរបស់ធនាគារដោយហាមមិនឱ្យយកប្រាក់ចេញទៅខាងក្រៅ ប៉ុន្តែមិនខុសនឹងក្រមព្រហ្មទណ្ឌទេ ពីព្រោះក្នុងក្រមព្រហ្មទណ្ឌ មិនបានចែងថា អ្នកដែលយកប្រាក់ចេញពីធនាគារត្រូវជាប់គុកដែរទេ ហើយកូនក្ដីខ្លួននេះគាត់ក៏ស្ដាយក្រោយដែរ ដោយសារធ្វើឱ្យប្ដីគាត់ដែលមិនដឹងអីជាប់គុក ហើយម្ដាយក្មេកគាត់ក៏ខឹងនឹងគាត់ដែរ ពីព្រោះកូនគាត់ធ្វើការដល់ក្រសួងមុខងារសាធារណៈតែបែរជាមកជាប់គុកដោយសារតែប្រពន្ធចង់បានប្រាក់ចំណេញប៉ុណ្ណឹង។ ហេតុនេះខ្លួនស្នើសុំឱ្យលោកស្រីចៅក្រមសម្រេចឱ្យកូនក្ដីខ្លួនឈ្មោះ [redacted] វឌ្ឍនានារីរតន៍ រួចខ្លួនពីបទចោទ។

-លោកមេធាវី [redacted] វិបុល ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ស៊ីមន្ថា និងឈ្មោះ [redacted] វឌ្ឍនានារីរតន៍ បានធ្វើសេចក្ដីសន្និដ្ឋានការពារថា៖ ខ្លួនសុំឯកភាពតាមការសន្និដ្ឋានរបស់មេធាវីសហភាគាឈ្មោះ [redacted] សុគន្ធ។ ខ្លួនបន្ថែមចំណុចមួយចំនួនទៀត កូនក្ដីខ្លួនបានបញ្ជាក់រួចហើយថា ជាទម្លាប់របស់គាត់ គាត់មានភារកិច្ចទៅយកប្រពន្ធពីកន្លែងធ្វើការ និងចេញពីធ្វើការនៅពេលគាត់ទំនេរ ដោយសារប្រពន្ធមិនចេះបើកម៉ូតូ និងឡានទេ។ ហើយពាក់ព័ន្ធនឹងអង្គហេតុនេះ ក្នុងពាក្យបណ្ដឹងដើមខែមករា ឆ្នាំ២០២០ គឺសំដៅទៅលើថ្ងៃទី១៨ ខែមករា ឆ្នាំ២០២០ នេះឯង ពាក់ព័ន្ធនឹងការជញ្ជូនថង់ខ្មៅទៅខាងក្រៅម្ដងមួយៗទៅខាងក្រោមនោះ ឈ្មោះ [redacted] ស៊ីមន្ថា គឺចេតនាគាត់មិនដឹងថានៅក្នុងថង់ខ្មៅនោះគឺជារបស់អ្វីទេ នៅពេលជញ្ជូនគ្រប់ហើយ ទើបប្រពន្ធរបស់គាត់បញ្ជាក់ថា នៅក្នុងថង់ខ្មៅនោះ គឺជាប្រាក់យកទៅប្ដូរបង់ពន្ធ គាត់ក៏មិនបានបញ្ជាក់អ្វីទៀតដែរ ដោយសារមិនមែនជាការងាររបស់គាត់។ នៅក្នុងនេះខ្លួនចាប់អារម្មណ៍ការសួររបស់តំណាងអយ្យការថា ហេតុអ្វីការងាររបស់ប្ដីប្រពន្ធមិនត្រូវដឹងការងាររបស់គ្នាទៅវិញទៅមក ពាក់ព័ន្ធនឹងការងារនេះមិនមែនប្ដីប្រពន្ធត្រូវតែដឹងការងាររវាងគ្នាទៅវិញទៅមកទេ។ ពាក់ព័ន្ធនឹងអង្គហេតុថ្ងៃទី១៨ ខែមករា ឆ្នាំ២០២០ របស់ឈ្មោះ [redacted] ស៊ីមន្ថា ក្នុងការលើកថង់ខ្មៅនោះ ខ្លួនបានដាក់ភស្ដុតាងដែលជាការយល់ឃើញរបស់តុលាការកំពូលដែលបានសម្រេចឱ្យកូនក្ដីខ្លួននៅក្រៅឃុំក្នុងសំណុំរឿងនេះ ដោយតុលាការកំពូលបញ្ជាក់ច្បាស់ថា បើពិនិត្យទៅលើអង្គហេតុនៃការចោទប្រកាន់ លទ្ធផលនៃកិច្ចពិភាក្សាដេញដោលនាពេលសវនាការ ភស្ដុតាងនានាក្នុងសំណុំរឿង ឃើញថាជនជាប់ចោទឈ្មោះ[redacted] ស៊ីមន្ថា ពុំមានចេតនាទុច្ចរិត និងគៃបំបាត់ក្នុងអង្គហេតុចោទប្រកាន់អំពីបទ សមគំនិតក្នុងអំពើរំលោភលើទំនុកចិត្តពិសេសដោយអភិបាល ឬបុគ្គលផ្សេងទៀតនោះទេ នេះគឺជាការយល់ឃើញរបស់តុលាការកំពូលដែលគាត់គិតថាកូនក្ដីខ្លួនមិនមានចេតនាទុច្ចរិតទេ អីចឹងអង្គហេតុនេះកូនក្ដីខ្លួនមិនដឹងទេ ហើយគាត់គ្មានចេតនាប្រព្រឹត្តទេ។ តាមមាត្រា៤ នៃក្រមព្រហ្មទណ្ឌ បានចែងច្បាស់អំពីចេតនានៃការប្រព្រឹត្តបទល្មើស អីចឹងកូនក្ដីខ្លួនឈ្មោះ [redacted] ស៊ីមន្ថា មិនមានទោសទេ ហេតុនេះសុំលោកស្រីចៅក្រមសម្រេចឱ្យកូនក្ដីខ្លួនឈ្មោះ [redacted] ស៊ីមន្ថា រួចខ្លួនពីបទចោទ បទសមគំនិតក្នុងអំពើរំលោភលើទំនុកចិត្តពិសេសដោយអភិបាល ឬបុគ្គលផ្សេងទៀត។ ទី២. ពាក់ព័ន្ធនឹងឈ្មោះ [redacted] វឌ្ឍនានារីរតន៍



Scanned with CamScanner

គាត់បានបញ្ជាក់ហើយថា ដោយសារតែគាត់ចង់ចំណេញក្បាលកាក់ គឺគាត់បានយកប្រាក់ចេញពីធនាគារកាណាឌីយ៉ា អ.ក ដោយមិនមានការអនុញ្ញាត ដោយហេតុថាជាគោលការណ៍គេទទួលប្រាក់ពន្ធជាប្រាក់រៀល អ៊ីចឹងដោយចង់បានប្រាក់ចំណេញ គាត់បានប្រៀបធៀបអត្រាប្តូរប្រាក់ដែលប្តូរនៅខាងក្រៅមានលក្ខណៈខ្ពស់ជាង គាត់ក៏បានយកប្រាក់នោះទៅប្តូរនៅខាងក្រៅមកបង់ឱ្យធនាគារកាណាឌីយ៉ា អ.ក វិញ។ អំពើរបស់កូនក្តីខ្លួនឈ្មោះ [redacted]វណ្ណនារីរតន៍ ក្នុងសំណុំរឿងនេះខាងធនាគារកាណាឌីយ៉ា អ.ក ដែលមានលោកមេធាវី [redacted]ហេង បានបញ្ជាក់ថា ប្រាក់នោះមានចំនួន ៦,១៦០,០០០$ (ប្រាំមួយលានដប់ប្រាំមួយម៉ឺនដុល្លារអាមេរិក) នោះ បានបង្វិលចូលធនាគារកាណាឌីយ៉ា អ.ក គ្រប់អស់ហើយ គឺមិនមានពាក់ព័ន្ធអ្វីទៀតនៅក្នុងអង្គហេតុថ្ងៃទី១៨ ខែមករា ឆ្នាំ២០២០ នេះទេ អ៊ីចឹងខ្លួនសំណូមពរលោកស្រីចៅក្រមសម្រេចឱ្យកូនក្តីខ្លួនឈ្មោះ[redacted]វណ្ណនារីរតន៍ បានរួចខ្លួនពីបទចោទ បទរំលោភទំនុកចិត្តពិសេសដោយអភិបាល ឬបុគ្គលផ្សេងទៀត។

-លោកមេធាវី [redacted]សម្បត្តិ ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ[redacted]ហៀង បានធ្វើសេចក្តីសន្និដ្ឋានថា៖ ក្រោយពីបានសួរដេញដោលរយៈពេល ០២ថ្ងៃនេះ ឃើញថា ដើមហេតុដែលកើតឡើងនូវបទល្មើសនេះ គឺមានឈ្មោះ [redacted] វណ្ណនារីរតន៍ ដែលជាអ្នកប្រមូលប្រាក់ពន្ធ ហើយគាត់មានបំណងចង់បានប្រាក់ចំណេញបន្តិចបន្តួច ក៏កើតមាននូវការប្រព្រឹត្តឡើងយកប្រាក់ចេញទៅប្តូរនៅខាងក្រៅ។ ក្នុងរឿងនេះកូនក្តីខ្លួនឈ្មោះ[redacted] ហៀង មិនមែនធ្វើការងារទើបតែថ្មីៗនេះទេ គឺធ្វើតាំងពីឆ្នាំ២០០២ មកម្ល៉េះ អ៊ីចឹងបុគ្គលិកភាគីច្រើន គឺស្គាល់គាត់ រួមទាំងគាត់ជាមនុស្សចំណាស់មានភាពឧស្សាហ៍ព្យាយាមធ្វើឱ្យបុគ្គលិកទូទៅស្រលាញ់ចូលចិត្តគាត់ ហើយប្រើឱ្យគាត់ទិញបាយទិញទឹក។ ខ្លួនបានសង្កេតឃើញថា តួនាទីរបស់គាត់ជាអ្នកសន្តិសុខ និងជាអ្នកបើកបរ តំណាងអយ្យការបានសួរហើយ តួនាទីរបស់យើងជាសន្តិសុខទៅទិញបាយទិញទឹកឱ្យគេ ខ្លួនសង្កេតឃើញអនុរក្សពន្ធនាគារវិញ នៅពេលដែលជនជាប់ចោទម្នាក់ ឬក៏ ០២នាក់ ស្រេកទឹក គឺគាត់ប្រាប់គ្នា អ៊ីចឹងហេតុអ្វីអនុរក្សពន្ធនាគារគាត់ធ្វើខុសពីតួនាទីគាត់ទេ។ នេះជាទឹកចិត្តរបស់ឈ្មោះ[redacted]ហៀង ក្នុងការជួយបម្រើ ជួយសម្រួលទៅដល់បុគ្គលិកទាំងអស់ មិនថាបុគ្គលិកតូចតាច ឬអ្នកធំទេ ឱ្យតែប្រើ គឺគាត់ធ្វើទាំងអស់ ណាមួយគាត់ជាអ្នកក្រប្រាក់ខែតិច បើមិនខំឆ្លៀតបន្តិចបន្តួចបម្រើគេគ្រាន់តែគេឱ្យចាយបន្តិចបន្តួចយកទៅផ្គត់ផ្គង់ជីវភាពនោះ ថាតើគ្រប់គ្រាន់ទេ មានកូនមានអីផងនោះ។ ហើយបើសិនប្រាក់ខែមិនគ្រប់គ្រាន់ចាយផង តើគាត់មានប្រាក់ទៅទិញដីទេ បើគាត់ធ្វើការ ២០ឆ្នាំហើយ គាត់ឆ្លៀតបន្តិចបន្តួចនេះបង់គេក្នុងមួយខែ១០០$ មិនមានអ្វីច្រើនទេ ហេតុនេះខ្លួនគិតថា មិនមានអ្វីដែលមិនអាចទៅរួចទេ សព្វថ្ងៃបង់ដីតម្លៃ ២,០០០$ (ពីរពាន់ដុល្លារអាមេរិក) ទៅ ៣,០០០$ (បីពាន់ដុល្លារអាមេរិក) នោះក៏មានដែរ។ ចំណែកទំនាក់ទំនងរវាងគាត់នឹងឈ្មោះ[redacted] វណ្ណនារីរតន៍ នោះ គឺស្គាល់គ្នាក្នុងនាមជាបុគ្គលិក គាត់បញ្ជាក់ហើយថា គាត់ជួយសម្រួលទាំងអស់មិនថាតែបុគ្គលិកណា ឬអតិថិជនទេ ឱ្យតែមានការ គឺគាត់ជួយ អ៊ីចឹងគាត់នៅក្នុងបរិវេណរបស់ស្នាក់ការកណ្តាលធនាគារកាណាឌីយ៉ា អ.ក គឺគាត់ជួយសម្រួលបុគ្គលិកទាំងអស់ ឱ្យតែពឹងគាត់ធ្វើ។ បើការធ្វើរបស់គាត់ខុស ហេតុអីក៏ថ្នាក់ដឹកនាំធនាគារមិនដាក់វិន័យគាត់ ២០ឆ្នាំហើយ អ៊ីចឹងទង្វើនេះមិនមែនជាចេតនាក្នុងការចូលរួមប្រព្រឹត្តជាមួយនឹងឈ្មោះ [redacted] វណ្ណនារីរតន៍ ទេ ហើយការជញ្ជូនអីវ៉ាន់ពីជាន់ទី១ ដល់ជាន់ទី៥ គ្រាន់តែជាវិជ្ជាជីវៈនៃសកម្មភាពរបស់គាត់ទេ មិនមែនបង្ហាញពីចេតនាណាមួយរបស់គាត់ក្នុងការប្រព្រឹត្តទេ យើងពិចារណាមើលគាត់ធ្វើឱ្យដោយសុទ្ធចិត្តរបស់គាត់ ការងារប្រចាំថ្ងៃរបស់គាត់ គឺចឹង។ មួយទៀតការជូនឈ្មោះ[redacted]បញ្ញាសុជាតា ទៅក្រុម



Scanned with CamScanner

ហ៊ុន លី ហួរ ប្តូរប្រាក់ គឺក្រៅម៉ោងធ្វើការ គាត់ចេញម៉ូតូពីកន្លែងផ្ញើមកក៏បានជួបឈ្មោះ [redacted] បញ្ញាសុជាតា ហើយឈ្មោះ ហ៊ុន លី ហួរ ប្តូរប្រាក់ រួច [redacted] បញ្ញាសុជាតា ក៏បានឆ្លើយហើយថា ជួបគ្នាដោយចៃដន្យហើយគាត់ក៏បានជូនទៅដល់ក្រុមហ៊ុន លី ហួរ ប្តូរប្រាក់ រួច គាត់ក៏ទៅផ្ទះ។ កូនក្តីរបស់ខ្លួនពុំមានចេតនាណាមួយក្នុងការប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់ទេ យើងពិនិត្យទៅលើអង្គច្បាប់វិញ គឺពាក់ព័ន្ធជាមួយនឹងការចោទប្រកាន់បទល្មើសរំលោភលើទំនុកចិត្តពិសេសដោយអភិបាល ឬបុគ្គលផ្សេងទៀត កូនក្តីខ្លួនមិនចូលជាតុផ្សំនេះទេ គឺគាត់គួរឱ្យអាណិតណាស់។ ការដេញដោលកន្លងមកនេះ ពុំឃើញមានកន្លែងណាបង្ហាញថាកូនក្តីរបស់ខ្លួនមានចេតនាប្រព្រឹត្ត ដូច្នេះខ្លួនសំណូមពរឱ្យលោកស្រីចៅក្រមមេត្តាពិចារណាឱ្យកូនក្តីខ្លួនរួចខ្លួនពីបទចោទ ដើម្បីកុំឱ្យមានការចោទប្រកាន់ទៅលើមនុស្សខុស។

-លោកមេធាវី [redacted] ចន្ថុល ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] បញ្ញាសុជាតា បានធ្វើសេចក្តីសន្និដ្ឋានការពារថា៖ ចំពោះអង្គហេតុដែលបានកើតឡើង ឆ្លងតាមការសួរដេញដោល ការត្រួតពិនិត្យលើភស្តុតាងឯកសារផ្សេងៗបង្ហាញយ៉ាងច្បាស់ហើយថា កូនក្តីរបស់ខ្លួនគ្រាន់តែជាបុគ្គលិករបស់ធនាគារ វឌ្ឍនៈ អាស៊ីចំកាត់ ដែលធ្វើការនៅធនាគារផ្សេងមិនមែនជាបុគ្គលិករបស់ធនាគារកាណាឌីយ៉ា អ.ក ទេ ដោយគាត់បានលាឈប់ពីធនាគារកាណាឌីយ៉ា អ.ក កាលពីឆ្នាំ២០១៨ ហើយដូច្នេះពាក់ព័ន្ធនឹងការចោទប្រកាន់បទរំលោភលើទំនុកពិសេសដោយអភិបាល ឬបុគ្គលផ្សេងទៀត តាមបញ្ញត្តិមាត្រា ៣៩៣ នៃក្រមព្រហ្មទណ្ឌនោះ គឺមិនត្រឹមត្រូវទេ។ មួយទៀតចំពោះសកម្មភាពដែលពាក់ព័ន្ធនឹងឈ្មោះ [redacted] វឌ្ឍនានារីរតន៍ យើងឃើញហើយថា ឈ្មោះ [redacted] វឌ្ឍនានារីរតន៍ ជាអ្នកយកប្រាក់ពន្ធនោះដោយខ្លួនឯង ហើយបានទូរស័ព្ទមកកូនក្តីខ្លួនឱ្យជួយមើលប្រាក់ឱ្យគាត់ ប៉ុន្តែការដែលយកនេះសហភាតាបានបញ្ជាក់ហើយថា ចូលជាបទល្មើសបានលុះត្រាតែយកដើម្បីធ្វើជាកម្មសិទ្ធិ ប៉ុន្តែក្នុងអង្គហេតុនេះ យើងឃើញហើយថាយកទៅក្នុងគោលបំណងអ្វី គឺដើម្បីចំណេញក្បាលកាក់ ដូចលោកមេធាវី [redacted] សុគន្ធ បានបញ្ជាក់ហើយថា ការយកមកគែបំបាត់យកមកធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួន ហើយខាងមេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណីគាត់បាននិយាយថា បើសិនជាមិនតាមឱ្យទាន់ទេ គឺអាចយកប្រាក់នោះទៅបាត់ហើយ ស្តែងឱ្យឃើញថាមានលក្ខណៈផ្ទុយពីចេតនាដើមរបស់ឈ្មោះ [redacted] វឌ្ឍនានារីរតន៍ និងកូនក្តីខ្លួន គឺគាត់បានចាប់ផ្តើមប្តូរប្រាក់ ដោយសារឈ្មោះ [redacted] វឌ្ឍនានារីរតន៍ នៅក្រៅប្រទេស ហើយបានពឹងកូនក្តីខ្លួនឱ្យជួយប្តូរឱ្យទៅជាមូលប្បទានប័ត្រ និងបានដាក់ចូលគណនីរបស់អគ្គនាយកដ្ឋានពន្ធដារទៀត គឺតាំងពីថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០ ចំនួន ០៣លើក យកមកដាក់រហូតគ្រប់ចំនួនឱ្យអគ្គនាយកដ្ឋានពន្ធដារវិញ។ ពាក់ព័ន្ធនឹងអត្រាប្តូរប្រាក់ ខ្លួនស្នើសុំឱ្យលោកស្រីចៅក្រមពិចារណាថា តើបទបញ្ជាផ្ទៃក្នុង ឬក៏លក្ខន្តិកៈរបស់ធនាគារកាណាឌីយ៉ា អ.ក ការប្តូរប្រាក់នៅខាងក្រៅខុសពីបទបញ្ជាផ្ទៃក្នុង ឬលក្ខន្តិកៈរបស់ធនាគារ ឬយ៉ាងណា អីចឹងសូមឱ្យលោកមេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណីបង្ហាញត្រង់ចំណុចនេះដែរ ហើយម្យ៉ាងទៀតពាក់ព័ន្ធនឹងផ្លូវច្បាប់ កូនក្តីរបស់ខ្លួន បើតាមនិយមន័យនៃបទល្មើសរំលោភលើទំនុកចិត្តពិសេសដោយអភិបាល ឬបុគ្គលផ្សេងទៀត ឃើញថា កូនក្តីរបស់ខ្លួនពុំមានចូលនូវលក្ខខណ្ឌណាមួយដែលបានកំណត់ទេ ហើយកូនក្តីខ្លួនមិនបានទទួលសិទ្ធិ ឬក៏ធ្វើការនៅក្នុងធនាគារកាណាឌីយ៉ា អ.ក នោះទេ។ ការដែលគាត់ជួយឈ្មោះ [redacted] វឌ្ឍនានារីរតន៍ នោះ គឺជួយដោយទឹកចិត្តមិនមានការតបស្នងអ្វីទេ ជាលក្ខណៈស្គាល់គ្នាប៉ុណ្ណោះ ដូច្នេះខ្លួនស្នើសុំលោកស្រីចៅក្រមមេត្តាពិចារណាលើធាតុផ្សំនៃបទល្មើស ពីព្រោះប្រាក់ដែលបានយកចេញទៅនេះក៏បានយកមកសងធនាគារកាណាឌីយ៉ា អ.ក វិញអស់ហើយ សុំឱ្យកូនក្តីខ្លួនរួចខ្លួនពីបទចោទ។ ៚



Scanned with CamScanner

-លោកមេធាវី [redacted] ប៊ុនរ៉ា ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] វចនា បានធ្វើសេចក្ដីសន្និដ្ឋានការពារថា៖ ឆ្លងតាមការស៊ើបដេញដោលកន្លងមកនេះ ខ្លួនសូមបញ្ជាក់ថា ចំពោះកូនក្ដីខ្លួនឈ្មោះ [redacted] វចនា ដែលជាប់ពាក់ព័ន្ធនេះ គឺគាត់ជាថ្នាក់លើរបស់អ្នកដែលបានយកប្រាក់ទៅប្ដូរ។ មួយទៀតក្រោយពីបានសិក្សាសំណុំរឿង និងភស្តុតាងជាវីដេអូដែលខាងធនាគារកាណាឌីយ៉ា អ.ក ដាក់មកតុលាការ គឺមិនមានពាក់ព័ន្ធទឹងកូនក្ដីខ្លួនឈ្មោះ សាធ វចនា ទេ។ ថ្ងៃទី១៨ ខែមករា ឆ្នាំ២០២០ ដែលមានការយកប្រាក់ចេញពីធនាគារកាណាឌីយ៉ា អ.ក ទៅប្ដូរនោះ គឺកូនក្ដីខ្លួនឈឺ មានសុំច្បាប់ ដោយបានទំនាក់ទំនងទៅថ្នាក់លើរបស់គាត់។ កូនក្ដីខ្លួនមិនបានរំលោភលើកទំនុកចិត្តពិសេសដោយអភិបាល ឬបុគ្គលផ្សេងទេ ដោយសារនៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០២០ កូនក្ដីខ្លួនបានទទួលព័ត៌មានពីខាងអគ្គនាយកដ្ឋានពន្ធដារថា ប្រាក់មានតែតួលេខចូលក្នុងគណនីពន្ធដារ តែមិនឃើញប្រាក់ចូលទៅទេ ទើបគាត់ឆែកមើលថាតើកូនចៅគាត់អ្នកណាជាអ្នកទទួលនៅថ្ងៃហ្នឹង ហើយក៏បានឃើញថាឈ្មោះ [redacted] វណ្ណនារីរតន៍ ជាអ្នកទទួល ហេតុនេះក៏បានទាក់ទងទៅតាមរយៈប្រព័ន្ធអ៊ីនធឺណែត ហើយឈ្មោះ [redacted] វណ្ណនារីរតន៍ ក៏បានឆ្លើយថា ដោយសារប្រព័ន្ធអ៊ីនធឺណែតមិនសូវល្អ គាត់ស្ដាប់គ្នាមិនសូវបាន តែក្រោយមកឈ្មោះ [redacted] វណ្ណនារីរតន៍ ក៏បានបញ្ជាក់ថា គាត់ពិតជាបានទទួលប្រាក់ពីអតិថិជន តែដោយសារតែគាត់មិនទាន់បានប្ដូរប្រាក់ អីចឹងមិនទាន់បានយកប្រាក់ទៅដាក់ទេ។ កូនក្ដីខ្លួនក្នុងនាមគាត់ធ្វើការ ១៥ឆ្នាំ ហើយគាត់មានការបារម្ភខ្លាចបាត់ប្រាក់ក៏បានអង្វរឱ្យឈ្មោះ [redacted] វណ្ណនារីរតន៍ យកប្រាក់មកបង់ឱ្យធនាគារវិញ ហើយឈ្មោះ [redacted] វណ្ណនារីរតន៍ ក៏បានព្យាយាមទាក់ទងទៅឈ្មោះ [redacted] បញ្ញាសុជាតា ដើម្បីទៅជួយប្ដូរប្រាក់យកទៅបញ្ចូលក្នុងធនាគារវិញ ក្រោយពីបានដាក់បញ្ចូលហើយ ក៏បានប្រាប់កូនក្ដីខ្លួនថា បានដាក់បញ្ចូលហើយ។ ពាក់ព័ន្ធនឹងការលុបប្រតិបត្តិដាក់ប្រាក់បញ្ចូលនោះ កូនក្ដីខ្លួនមានសិទ្ធិលុបនៅពេលដែលចរន្តប្រាក់ និងវិក្កយប័ត្រខុសគ្នា គាត់បានបញ្ជាក់ថា គាត់មានសិទ្ធិលុប អីចឹងអង្គហេតុនេះមានន័យថា កូនក្ដីខ្លួនមិនបានប្រព្រឹត្តបទល្មើសពាក់ព័ន្ធនឹងបទរំលោភលើទំនុកចិត្តពិសេសដោយអភិបាល ឬបុគ្គលផ្សេងទេ ទី១. គាត់មិនបានទទួលផលប្រយោជន៍នៅក្នុងរឿងនេះ ទី២.គាត់បានព្យាយាមដើម្បីឱ្យកូនចៅគាត់យកប្រាក់មកដាក់ ហើយកូនចៅគាត់ក៏បានឆ្លើយសារភាពដែរថា គាត់យកប្រាក់នេះដើម្បីប្ដូរយកចំណេញក្បាលកាក់។ ការចោទប្រកាន់របស់តំណាងអយ្យការតាមមាត្រា ៣៩៣ នៃក្រមព្រហ្មទណ្ឌ នោះ កូនក្ដីខ្លួនមិនបានចូលលក្ខខណ្ឌមាត្រានេះទេ ដោយសារគាត់មិនបានទទួលផលប្រយោជន៍ពាក់ព័ន្ធនឹងបណ្ដឹង មិនដែលមានបណ្ដឹងចំឈ្មោះកូនក្ដីខ្លួនទេ ហើយបទល្មើសដែលបានអះអាងនៅក្នុងពាក្យបណ្ដឹងនៅក្នុងដីកាសន្និដ្ឋានស្ថាពរ គឺកូនក្ដីខ្លួនមិនបានប្រព្រឹត្តអ្វីទាំងអស់ ហេតុនេះក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] វចនា សំណូមពរឱ្យលោកស្រីចៅក្រមសម្រេចឱ្យកូនក្ដីខ្លួនរួចខ្លួនពីបទចោទ។

-លោកមេធាវី [redacted] ប៊ុនកែវ ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សុផាយ និងឈ្មោះ [redacted] សុវណ្ណចរិយា បានធ្វើសេចក្ដីសន្និដ្ឋានការពារថា៖ ឆ្លងតាមការពិភាក្សាដេញដោលនាពេលសវនាការរួចមក នៅពេលនេះខ្លួនបានសង្កេតឃើញថា មេធាវីសហភាគាបានលើកឡើងហើយថា នៅក្នុងរឿងនេះពិតជាមានអំពើយកប្រាក់ចេញទៅខាងក្រៅហើយបានយកប្រាក់ដាក់ចូលវិញចំនួន ៦,១៦០,០០០$ (ប្រាំមួយលានដប់ប្រាំមួយម៉ឺនដុល្លាអាមេរិក) មែន។ ប៉ុន្តែបើខ្លួនពិនិត្យមើលទៅឃើញថា រឿងហេតុនៅក្នុងសំណុំរឿងនេះអត់មានពាក់ព័ន្ធអ្វីជាមួយកូនក្ដីខ្លួនបន្តិចសោះ សូម្បីតែនៅពេលសវនាការនេះ មេធាវីតំណាងឱ្យដើមបណ្ដឹងរដ្ឋប្បវេណីគ្រាន់តែសួរទំនាក់ទំនងការងាររបស់កូនក្ដីខ្លួន ដោយ



Scanned with CamScanner

វៀកកូនក្តីខ្លួនឈ្មោះ[redacted] សុវណ្ណចរិយា ខ្លួនបានសាកសួរថា កន្លងមកធនាគារកាណាឌីយ៉ា អ.ក មានគោលការណ៍ហាមឃាត់មិនឱ្យធ្វើអ្វីមួយទេនៅក្នុងការិយាល័យពន្ធដារនោះ គាត់ថាមិនមានទេ។ ខ្លួនគិតថារឿងនេះ ពេលឈ្មោះ[redacted] វណ្ណនារីរតន៍ យកប្រាក់ទៅដាក់សងវិញនោះ បុគ្គលិកនៅក្នុងការិយាល័យបង់ពន្ធក៏មិនមានអ្នកដឹងដែរ ដោយសារតែឈ្មោះធន សំណាង ជាអ្នកយកទៅដាក់។ តាមដែលមេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណីអះអាង ធម្មតាតាមគោលការណ៍របស់ធនាគារកាណាឌីយ៉ា អ.ក ក្នុងការទទួលប្រាក់ពីការបង់ពន្ធ បើមានគេយកមកបង់បេឡាករត្រូវទទួល អត់មានគោលការណ៍ណាហាមទទួលទេ នេះជាចំណុចពិសេស ដែលបានបង្ហាញថា បុគ្គលិកក្នុងការិយាល័យបង់ពន្ធទាំងមូលគ្មានបទល្មើសទេ គឺគេដំណើរការប្រតិបត្តិការគេធម្មតា ទោះបីមេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងថាពេលធនាគារដឹងហើយទើបជនជាប់ចោទយកប្រាក់នោះមកដាក់សងវិញ បើទោះជាអីចឹងក៏ដោយ ចុះធនាគារគាត់ដឹងហើយ បើកំណត់ថាឃើញប្រាក់របស់ក្រុមហ៊ុន ឥន ហ្គ័ង ខនស្ត្រាក់សិន ខេមបូឌា ឯ.ក ហ្នឹងមកកុំទទួល តែបែរជាអត់មានហាមទេ ដូច្នេះប្រតិបត្តិការរបស់មន្ត្រីការិយាល័យបង់ពន្ធនេះ គឺខ្លួនគិតថាមានការដំណើរការប្រក្រតីធម្មតា ដូចមេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណីបានលើកបង្ហាញវិក្កយប័ត្រ និងបានលើកហើយថា ប្រតិបត្តិការហ្នឹងមានបញ្ហា មានភាពមិនប្រក្រតីទេ គឺអត់មានទេ គឺមានដំណើរការធម្មតាតែម្តង ដូច្នេះខ្លួនយល់ឃើញថា កូនក្តីខ្លួនទាំងឈ្មោះ [redacted] សុគាយ និងឈ្មោះ[redacted] សុវណ្ណចរិយា ដែលបានបំពេញការងារនៅក្នុងធនាគារកាណាឌីយ៉ា អ.ក នោះ មិនមានបទល្មើសទេ ដូច្នេះខ្លួនស្នើសុំឱ្យលោកស្រីចៅក្រមសម្រេចឱ្យកូនក្តីខ្លួនទាំង ០២នាក់រួចខ្លួនពីបទចោទ។

## សំដីចុងក្រោយរបស់ជនជាប់ចោទ

-ជនជាប់ចោទឈ្មោះ [redacted] វណ្ណនារីរតន៍ បាននិយាយសំដីចុងក្រោយបង្អស់ថា៖ ខ្លួនស្នើសុំឱ្យតុលាការជួយរកយុត្តិធម៌ឱ្យខ្លួនផង។

-ជនជាប់ចោទឈ្មោះ [redacted] ស៊ីមន្ថា បាននិយាយសំដីចុងក្រោយបង្អស់ថា៖ ខ្លួនស្នើសុំឱ្យតុលាការលើកលែងការចោទប្រកាន់ឱ្យខ្លួនមានសេរីភាពវិញផង។

-ជនជាប់ចោទឈ្មោះ [redacted] សុគាយ បាននិយាយសំដីចុងក្រោយបង្អស់ថា៖ ខ្លួនសុំឱ្យតុលាការលើកលែងការចោទប្រកាន់ឱ្យខ្លួនផង ព្រោះរឿងនេះអយុត្តិធម៌ចំពោះខ្លួនណាស់។

-ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណចរិយា បាននិយាយសំដីចុងក្រោយបង្អស់ថា៖ ខ្លួនសុំឱ្យតុលាការផ្តល់យុត្តិធម៌ដល់រូបខ្លួន និងដោះលែងខ្លួនផង។

-ជនជាប់ចោទឈ្មោះ [redacted] រចនា បាននិយាយសំដីចុងក្រោយបង្អស់ថា៖ ខ្លួនសុំឱ្យតុលាការលើកលែងការចោទប្រកាន់ឱ្យខ្លួនផង។

-ជនជាប់ចោទឈ្មោះ [redacted] បញ្ញាសុជាតា បាននិយាយសំដីចុងក្រោយបង្អស់ថា៖ ខ្លួនសុំឱ្យតុលាការរកយុត្តិធម៌ឱ្យខ្លួនផង។

-ជនជាប់ចោទឈ្មោះ[redacted] ហៀង បាននិយាយសំដីចុងក្រោយបង្អស់ថា៖ ខ្លួនសុំឱ្យតុលាការរកយុត្តិធម៌ឱ្យខ្លួន និងដោះលែងខ្លួនឱ្យមានសេរីភាពវិញផង។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទទាំង ០៧នាក់។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី



Scanned with CamScanner

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានក្លួញរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទទាំង ០៧នាក់

-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទទាំង ០៧នាក់

-ក្រោយពីបានពិនិត្យលើឯកសារភស្តុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

## សំអាងហេតុ

១-ជនជាប់ចោទឈ្មោះ [redacted] វឌ្ឍនទារីរតន៍, ឈ្មោះ [redacted] បញ្ញាសុជាតា, ឈ្មោះ [redacted] សុវណ្ណចរិយា, ឈ្មោះ [redacted] រចនា និងឈ្មោះ [redacted] សុឆាយ ត្រូវបានចៅក្រមស៊ើបសួរសម្រេចបញ្ជូនមកជំនុំជម្រះពីបទ រំលោភលើទំនុកចិត្តពិសេសដោយអភិបាល ឬបុគ្គលផ្សេងទៀត ប្រព្រឹត្តនៅស្នាក់ការកណ្តាលធនាគារកាណាឌីយ៉ា អ.ក ផ្លូវព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីដើមខែមករា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩៣ នៃក្រមព្រហ្មទណ្ឌ។

២-ជនជាប់ចោទឈ្មោះ [redacted] ស៊ីមន្ថា និងឈ្មោះ [redacted] ហៀង ត្រូវបានចៅក្រមស៊ើបសួរសម្រេចបញ្ជូនមកជំនុំជម្រះពីបទ សមគំនិតក្នុងអំពើរំលោភលើទំនុកចិត្តពិសេសដោយអភិបាល ឬបុគ្គលផ្សេងទៀត ប្រព្រឹត្តនៅស្នាក់ការកណ្តាលធនាគារកាណាឌីយ៉ា អ.ក ផ្លូវព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីដើមខែមករា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៩ និងមាត្រា ៣៩៣ នៃក្រមព្រហ្មទណ្ឌ។

៣-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] វឌ្ឍនទារីរតន៍, ឈ្មោះ [redacted] បញ្ញាសុជាតា, ឈ្មោះ [redacted] សុវណ្ណចរិយា, ឈ្មោះ [redacted] រចនា, ឈ្មោះ [redacted] សុឆាយ, ឈ្មោះ [redacted] ស៊ីមន្ថា និងឈ្មោះ [redacted] ហៀង និងចម្លើយរបស់មេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី ព្រមទាំងភស្តុតាងនៅក្នុងសំណុំរឿង បញ្ជាក់ឱ្យឃើញថា៖

ក-ជនជាប់ចោទឈ្មោះ [redacted] វឌ្ឍនទារីរតន៍ ជាប្រពន្ធរបស់ជនជាប់ចោទឈ្មោះ [redacted] ស៊ីមន្ថា។ មានតួនាទីជាបេឡាករផ្នែកទទួលប្រាក់ពន្ធនៅស្នាក់ការកណ្តាលធនាគារកាណាឌីយ៉ា អ.ក តាំងពីឆ្នាំ ២០១៥ រហូតដល់ថ្ងៃឃាត់ខ្លួន។ ក្នុងតួនាទីនេះពេលអតិថិជនយកប្រាក់មកបង់ពន្ធជនជាប់ចោទជាអ្នកទទួលប្រាក់ពន្ធ រាប់ប្រាក់ បញ្ចូលទឹកប្រាក់ទៅក្នុងប្រព័ន្ធធនាគារ រួចបំពេញទឹកប្រាក់នៅលើប័ណ្ណដាក់ប្រាក់របស់ធនាគារ និងបន្តបញ្ចូលទឹកប្រាក់ទៅក្នុងប្រព័ន្ធពន្ធដារ រួចព្រីនបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធឱ្យអតិថិជន។

ខ-ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណចរិយា ជាប្រពន្ធរបស់ជនជាប់ចោទឈ្មោះ [redacted] សុឆាយ។ មានតួនាទីជាមន្ត្រីជាន់ខ្ពស់ត្រួតពិនិត្យផ្នែកទទួលប្រាក់ពន្ធនៅស្នាក់ការកណ្តាលធនាគារកាណាឌីយ៉ា អ.ក តាំងពីឆ្នាំ២០១៧ រហូតដល់ថ្ងៃឃាត់ខ្លួន។ ក្នុងតួនាទីនេះជនជាប់ចោទជាអ្នកត្រួតពិនិត្យផ្ទាល់លើការងាររបស់បេឡាករទាំងអស់នៅផ្នែកទទួលប្រាក់ពន្ធ។

គ-ជនជាប់ចោទឈ្មោះ [redacted] រចនា មានតួនាទីជាអនុប្រធានប្រតិបត្តិការស្នាក់ការកណ្តាលទទួលបន្ទុកផ្នែកទទួលប្រាក់ពន្ធ និងគម្រោងរដ្ឋាភិបាល នៅស្នាក់ការកណ្តាលធនាគារកាណាឌីយ៉ា អ.ក តាំងពីឆ្នាំ២០១៦ រហូតដល់ថ្ងៃឃាត់ខ្លួន។ ក្នុងតួនាទីនេះជនជាប់ចោទជាអ្នកមើលការទូទៅនៅផ្នែកបង់ពន្ធ, មើលលើប្រតិបត្តិការទូទៅរបស់មន្ត្រីជាន់ខ្ពស់ឈ្មោះ [redacted] សុវណ្ណចរិយា និងមើលផ្ទៀងផ្ទាត់ពីលើប្រតិបត្តិការរបស់បេឡាករទាំងអស់នៅផ្នែកទទួលប្រាក់ពន្ធ។

ឃ-ជនជាប់ចោទឈ្មោះ [redacted] សុឆាយ ជាប្តីរបស់ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណចរិយា។ មានតួនាទីជាមន្ត្រីជាន់ខ្ពស់ផ្នែកព័ត៌មានវិទ្យា (IT) និងជាប្រធានក្រុមប្រព័ន្ធស្នូលធនាគារ នៅស្នាក់ការកណ្តាលធនាគារកាណាឌីយ៉ា អ.ក



Scanned with CamScanner

តាំងពីឆ្នាំ២០១២ រហូតដល់ថ្ងៃឃាត់ខ្លួន។ ក្នុងតួនាទីនេះជនជាប់ចោទជាអ្នកជួយសម្របសម្រួលឱ្យបុគ្គលិកដែលមានបញ្ហាផ្នែកព័ត៌មានវិទ្យា និងផ្តល់យោបល់ជូនធនាគារទៅលើផ្នែកព័ត៌មានវិទ្យា។

ង-ជនជាប់ចោទឈ្មោះ [redacted] ហៀង មានតួនាទីជាបុគ្គលិកផ្នែកសន្តិសុខ និងបើកបររថយន្តនៅស្នាក់ការកណ្តាលធនាគារកាណាឌីយ៉ា អ.ក តាំងពីឆ្នាំ២០០២ រហូតដល់ថ្ងៃឃាត់ខ្លួន។

ច-ជនជាប់ចោទឈ្មោះ [redacted] បញ្ញាសុជាតា ជាអតីតបេឡាករផ្នែកទទួលប្រាក់ពន្ធនៅធនាគារកាណាឌីយ៉ា អ.ក បានចូលធ្វើការនៅធនាគារកាឌីយ៉ា អ.ក កាលពីឆ្នាំ២០១០ រហូតដល់ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨ ក៏បានលាឈប់។

ឆ-ជនជាប់ចោទឈ្មោះ [redacted] ស៊ីមន្ថា ជាប្តីរបស់ជនជាប់ចោទឈ្មោះ [redacted] វឌ្ឍនានារីរតន៍។ មានតួនាទីជានាយកត្រួតពិនិត្យ និងវាយតម្លៃ នៅក្រសួងមុខងារសាធារណៈ។

៤-ដើមបណ្តឹងរដ្ឋប្បវេណីបានឆ្លើយថា នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២០ វេលាម៉ោង ៩ និង ១០នាទី ជនជាប់ចោទឈ្មោះ [redacted] វឌ្ឍនានារីរតន៍ ដែលមានតួនាទីជាមន្ត្រីផ្នែកទទួលប្រាក់ពន្ធ បានទទួលប្រាក់ពន្ធចំនួន ៦,១៦០,០០០$ (ប្រាំមួយលានដប់ប្រាំមួយម៉ឺនដុល្លាអាមេរិក) ពីអតិថិជនក្រុមហ៊ុន គ័ន ហ្គ័ង ខនស្រ្តាក់សិន ខេមបូឌា ឯ.ក នៅបន្ទប់ទទួលភ្ញៀវវីអាយភី ជាន់ផ្ទាល់ដី បន្ទាប់ពីទទួលប្រាក់ពន្ធនោះហើយជនជាប់ចោទមិនបានបញ្ចូលប្រាក់ពន្ធដែលទទួលពីអតិថិជននេះទៅក្នុងប្រព័ន្ធធនាគារទេ ទើបមិនមានប្រាក់ទាំងអស់នេះចូលក្នុងធនាគារកាណាឌីយ៉ា អ.ក។

៥-ជនជាប់ចោទឈ្មោះ [redacted] វឌ្ឍនានារីរតន៍ បានឆ្លើយសារភាពគ្រប់ដំណាក់កាលថា កាលពីថ្ងៃទី១៨ ខែមករា ឆ្នាំ២០២០ ខ្លួនពិតជាបានយកប្រាក់ចំនួន ៦,១៦០,០០០$ (ប្រាំមួយលានដប់ប្រាំមួយម៉ឺនដុល្លាអាមេរិក) ដែលជាប្រាក់របស់អតិថិជនក្រុមហ៊ុន គ័ន ហ្គ័ង ខនស្រ្តាក់សិន ខេមបូឌា ឯ.ក យកមកបង់ពន្ធតាមរយៈធនាគារកាណាឌីយ៉ា អ.ក ចេញទៅក្រៅធនាគារកាណាឌីយ៉ា អ.ក ពិតមែន។ ហើយពេលអតិថិជនយកប្រាក់នេះមកបង់ពន្ធ ខ្លួនបានបញ្ចូលសាច់ប្រាក់នោះទៅក្នុងប្រព័ន្ធពន្ធដាររួចហើយ និងបានចេញបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធចំនួន ០២សន្លឹក ឱ្យទៅអតិថិជនរួចហើយដែរ ប៉ុន្តែខ្លួនមិនបានបញ្ចូលសាច់ប្រាក់នោះចូលទៅប្រព័ន្ធធនាគារនោះទេ។

៦-តាមបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធលេខ ០០៤០៤៥៨៣៨ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០២០ មានទឹកប្រាក់ ២៤,៣៦៨,៦៣២,១៤៧៛ (ម្ភៃបួនពាន់បីរយហុកសិបប្រាំបីលានប្រាំមួយរយសាមសិបពីរពាន់មួយសែសិបប្រាំពីររៀល) (ឯកសារលេខ ៦៤/២) និងបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធលេខ ០០៤០៤៥៨៣៩ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០២០ មានទឹកប្រាក់ ៣៨៨,០៣៦,៥២៧៛ (បីរយប៉ែតសិបប្រាំបីលានសាមសិបប្រាំមួយពាន់ប្រាំរយម្ភៃប្រាំពីររៀល) (ឯកសារលេខ ៦៤/២) និងការទទួលស្គាល់របស់ជនជាប់ចោទឈ្មោះ [redacted] វឌ្ឍនានារីរតន៍ ដែលថាខ្លួនជាអ្នកចេញបង្កាន់ទាំង ០២ នេះជូនអតិថិជនក្រុមហ៊ុន គ័ន ហ្គ័ង ខនស្រ្តាក់សិន ខេមបូឌា ឯ.ក និងជាអ្នកចុះហត្ថលេខានោះ សបញ្ជាក់ឱ្យឃើញថាបង្កាន់ដៃទាំង ០២សន្លឹកនេះ គឺចុះហត្ថលេខាដោយឈ្មោះ [redacted] វឌ្ឍនានារីរតន៍ បើគិតជាប្រាក់ដុល្លារមានចំនួន ៦,១៦០,០០០$ (ប្រាំមួយលានដប់ប្រាំមួយម៉ឺនដុល្លារអាមេរិក)។

៧-តាមភស្តុតាងជារូបភាពដែលចាប់យកចេញពីកាមេរ៉ាសុវត្ថិភាពលេខ ៦៥/៥ ដល់ ៦៥/១៣ បង្ហាញឱ្យឃើញថា នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២០ វេលាម៉ោង០៩ និង ១៣នាទីព្រឹក ជនជាប់ចោទឈ្មោះ [redacted] បញ្ញាសុជាតា បានមកដល់ស្នាក់ការកណ្តាលនៃអគារធនាគារកាណាឌីយ៉ា អ.ក ខណៈពេលដែលជនជាប់ចោទឈ្មោះ [redacted] វឌ្ឍនានារីរតន៍ កំពុង



Scanned with CamScanner

ទទួលប្រាក់ពន្ធពីអតិថិជនក្រុមហ៊ុន គ័ន ហ្វ័ង ខនស្ត្រាក់សិន ខេមបូឌា ឯ.ក ជាប្រាក់ដុល្លារប្រាក់សុទ្ធចំនួន ៦,១៦០,០០០$ (ប្រាំមួយលានដប់ប្រាំមួយម៉ឺនដុល្លារអាមេរិក) នៅវេលាម៉ោង ០៩ និង ០៨នាទីព្រឹក នៅបន្ទប់ វីអាយភី នៃស្នាក់ការកណ្តាលធនាគារកាណាឌីយ៉ា អ.ក ហើយនៅវេលាម៉ោង ១០ និង ១០នាទីព្រឹក ថ្ងៃខែឆ្នាំដដែល ជនជាប់ចោទឈ្មោះ [redacted] ហៀង និងសន្តិសុខ ០២នាក់ ទៀតបានលីថង់ខ្មៅម្នាក់មួយៗដែលជាថង់ដាក់ប្រាក់សុទ្ធចំនួន ៦,១៦០,០០០$ (ប្រាំមួយលានដប់ប្រាំមួយម៉ឺនដុល្លារអាមេរិក) ដោយមានឈ្មោះ [redacted] បញ្ញាសុជាតា រួមដំណើរជាមួយយកទៅដាក់នៅបន្ទប់ ៥០២ ជាន់ទី០៥ នៃស្នាក់ការកណ្តាលអគារធនាគារកាណាឌីយ៉ា អ.ក រួចឈ្មោះ [redacted] បញ្ញាសុជាតា ជាអ្នកអង្គុយចាំមើលប្រាក់នោះ។ បន្ទាប់មកនៅវេលាម៉ោង ១១ព្រឹក ថ្ងៃខែឆ្នាំដដែល ជនជាប់ចោទឈ្មោះ [redacted] ស៊ីមន្ថា ដែលជាប្តីរបស់ជនជាប់ចោទឈ្មោះ [redacted] វណ្ណននារីរតន៍ បានមកដល់ស្នាក់ការកណ្តាលអគារធនាគារកាណាឌីយ៉ា អ.ក និងឡើងតាមជណ្តើរយន្តច្រកខាងក្រោយទៅជាន់ទី០៥ យកប្រាក់ដែលទុកក្នុងថង់ខ្មៅទាំង ០៣ ម្តងមួយៗតែម្នាក់ឯងចុះក្រោមតាមជណ្តើរយន្តច្រកខាងក្រោយរហូតអស់ដាក់ក្នុងឡានម៉ាក HIGHTLANDER របស់គេ ក្រោយពីជនជាប់ចោទឈ្មោះ [redacted] ស៊ីមន្ថា ជញ្ជូនថង់ខ្មៅទាំង ០៣ថង់នោះចេញអស់ នៅវេលាម៉ោង១១ និង ២០នាទីព្រឹក ជនជាប់ចោទឈ្មោះ [redacted] បញ្ញាសុជាតា ក៏បានចាកចេញពីស្នាក់ការកណ្តាលអគារធនាគារកាណាឌីយ៉ា អ.ក តាមជណ្តើរយន្តច្រកខាងក្រោយ។ តាមសកម្មភាពដែលជនជាប់ចោទឈ្មោះ [redacted] វណ្ណននារីរតន៍ កំពុងទទួលប្រាក់ពន្ធពីអតិថិជនក្រុមហ៊ុន គ័ន ហ្វ័ង ខនស្ត្រាក់សិន ខេមបូឌា ឯ.ក មិនទាន់រួចរាល់ផង ជនជាប់ចោទឈ្មោះ [redacted] បញ្ញាសុជាតា ក៏មកដល់ស្នាក់ការកណ្តាលអគារធនាគារកាណាឌីយ៉ា អ.ក ហើយពេលទទួលបានប្រាក់ពន្ធពីអតិថិជនភ្លាមបង្វែរដានយកទៅដាក់នៅបន្ទប់ទទួលភ្ញៀវ ជាន់ទី៥ ហើយភ្លាមៗជនជាប់ចោទឈ្មោះ [redacted] ស៊ីមន្ថា បានមកយកចុះក្រោមតាមជណ្តើរយន្តច្រកខាងក្រោយនៃអគារធនាគារកាណាឌីយ៉ា អ.ក នោះ បង្ហាញឱ្យឃើញថា ជនជាប់ចោទទាំងអស់បានរៀបគម្រោង និងត្រៀមរៀបចំជាមុនរួចជាស្រេចក្នុងការជម្លៀសប្រាក់ពន្ធទាំង ៦,១៦០,០០០$ (ប្រាំមួយលានដប់ប្រាំមួយម៉ឺនដុល្លារអាមេរិក) នោះចេញពីស្នាក់ការកណ្តាលអគារធនាគារកាណាឌីយ៉ា អ.ក។

៨-ជនជាប់ចោទឈ្មោះ [redacted] វណ្ណននារីរតន៍ បានឆ្លើយសារភាពថា ប្រាក់ពន្ធចំនួន ៦,១៦០,០០០$ (ប្រាំមួយលានដប់ប្រាំមួយម៉ឺនដុល្លារអាមេរិក) ដែលអតិថិជនយកមកបង់ពន្ធនោះ ខ្លួនមិនបានរាប់ប្រាក់នោះនៅការិយាល័យបង់ពន្ធនោះទេ គឺយកទៅរាប់នៅបន្ទប់ទទួលភ្ញៀវ វីអាយភី និងបានរក្សាទុកក្នុងថង់ខ្មៅចំនួន ០៣ថង់ បន្ទាប់ពីទទួលប្រាក់នេះ និងប្រគល់បង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធចំនួន ០២សន្លឹកខាងលើឱ្យអតិថិជនរួចហើយ ខ្លួនក៏ឱ្យសន្តិសុខឈ្មោះ [redacted] ហៀង ជញ្ជូនថង់ខ្មៅទាំង ០៣នោះជាមួយសន្តិសុខ ០២នាក់ទៀតឡើងទុកនៅបន្ទប់ទទួលភ្ញៀវជាន់ទី៥ រួមជាមួយឈ្មោះ [redacted] បញ្ញាសុជាតា ដោយឱ្យឈ្មោះ [redacted] បញ្ញាសុជាតា ជាអ្នកអង្គុយចាំមើលប្រាក់ពន្ធនោះរង់ចាំប្តីរបស់ខ្លួនឈ្មោះ [redacted] ស៊ីមន្ថា មកយកប្រាក់នោះដាក់ឡាន ដើម្បីយកទៅផ្ទះ។ ចម្លើយរបស់ជនជាប់ចោទនេះមានភាពស៊ីង្វាក់នឹងភស្តុតាងដែលមានរៀបរាប់នៅក្នុងសំអាងហេតុចំណុច ៧ និងស៊ីសង្វាក់នឹងចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] បញ្ញាសុជាតា ដែលបានឆ្លើយសារភាពថា កាលពីថ្ងៃទី១៨ ខែមករា ឆ្នាំ២០២០ វេលាម៉ោង ០៩ព្រឹក ឈ្មោះ [redacted] វណ្ណននារីរតន៍ បានទូរស័ព្ទប្រាប់ខ្លួនឱ្យមកជួយមើលប្រាក់ពន្ធប្រហែលជាជាង ៦លានដុល្លារអាមេរិក ពីព្រោះគាត់ចង់យកប្រាក់ទៅប្តូរនៅខាងក្រៅធនាគារ



Scanned with CamScanner

កាណាឌីយ៉ា អ.ក ហើយឈ្មោះ

កាណាឌីយ៉ា អ.ក។ តាមរយៈការពឹងនេះខ្លួនក៏មកដល់ស្នាក់ការកណ្តាលអគារធនាគារកាណាឌីយ៉ា អ.ក ហើយឈ្មោះ

[redacted] **វណ្ណនារីរតន៍** បានឱ្យខ្លួនយកប្រាក់ពីអតិថិជនដែលប្រាក់នោះដាក់ក្នុងថង់ខ្មៅចំនួន ០៣យកទៅទុកក្នុងបន្ទប់ វីអាយភី

ជាន់ទី៥ ដោយមានសន្តិសុខ ០៣នាក់ជួយលី ក្នុងនោះមានឈ្មោះ[redacted]**ហៀង** ផងដែរ ហើយឈ្មោះ [redacted] **វណ្ណនារីរតន៍**

ប្រាប់ឱ្យខ្លួនអង្គុយចាំមើលប្រាក់ពន្ធនោះរង់ចាំប្តីរបស់ឈ្មោះ [redacted]**វណ្ណនារីរតន៍** មកយក បន្ទាប់មកប្តីរបស់ឈ្មោះ[redacted]

**វណ្ណនារីរតន៍** បានមកយកប្រាក់ពន្ធនោះតែម្នាក់ឯង គាត់យកម្តង ០១ថង់ៗរហូតដល់អស់។ ខ្លួនដឹងថាប្រាក់នេះជាប្រាក់

ពន្ធដែលអតិថិជនយកមកបង់តាមរយៈធនាគារកាណាឌីយ៉ា អ.ក។ ឃើញថាសកម្មភាពទាំងអស់នេះជាទម្រង់នៃការជម្លៀស

ប្រាក់ចំនួន ៦,១៦០,០០០$ (ប្រាំមួយលានដប់ប្រាំមួយម៉ឺនដុល្លាអេមរិក) ចេញទៅក្រៅស្នាក់ការកណ្តាលធនាគារកាណាឌី

យ៉ា អ.ក។

៩-តាមកស្តុតាងដែលមានលើកឡើងក្នុងសំអាងហេតុចំណុច ៧ និងតាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីដូច មានលើកឡើងក្នុងសំអាងហេតុចំណុច ៤ គឺមានភាពស៊ីសង្វាក់នឹងចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] **វណ្ណនារីរតន៍** និងឈ្មោះ[redacted]**បញ្ញាសុជាតា** ដូចមានលើកឡើងក្នុងសំអាងហេតុចំណុច ៥, ៦ និង ៨ សបញ្ជាក់ឱ្យឃើញថា កាលពីថ្ងៃទី១៨ ខែមករា ឆ្នាំ២០២០ ជនជាប់ចោទឈ្មោះ [redacted]**វណ្ណនារីរតន៍** ពិតជាបានធ្វើសកម្មភាពយកប្រាក់ពន្ធ ចំនួន ៦,១៦០,០០០$ (ប្រាំមួយលានដប់ប្រាំមួយម៉ឺនដុល្លាអាមេរិក) ដែលជាប្រាក់របស់អតិថិជនក្រុមហ៊ុន គ័ន ហ្គ័ង ខនស្ត្រាក់សិន ខេមបូឌា ឯ.ក យកមកបង់ពន្ធតាមរយៈធនាគារកាណាឌីយ៉ា អ.ក ចេញទៅក្រៅធនាគារកាណាឌីយ៉ា អ.ក ដោយមិនឱ្យធនាគារកាណាឌីយ៉ា អ.ក ដឹងពិតមែន ហើយសកម្មភាពរបស់ជនជាប់ចោទនេះមានការជួយសម្រួលពីឈ្មោះ [redacted] **បញ្ញាសុជាតា**, ឈ្មោះ[redacted]**ហៀង** និងឈ្មោះ [redacted]**ស៊ីមន្តា**។

១០-ជនជាប់ចោទឈ្មោះ[redacted]**ចនា** បានឆ្លើយថា នៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០២០ ខាងអគ្គនាយកដ្ឋានពន្ធដារ បានទូរស័ព្ទមកខ្លួនសួរថា "អត់ឃើញទឹកប្រាក់ចំនួន ៦,១៦០,០០០$ (ប្រាំមួយលានដប់ប្រាំមួយម៉ឺនដុល្លាអាមេរិក) ដែលជាប្រាក់ពន្ធរបស់ក្រុមហ៊ុន គ័ន ហ្គ័ង ខនស្ត្រាក់សិន ខេមបូឌា ឯ.ក ចូលក្នុងប្រព័ន្ធគណនីរបស់ពន្ធដារ" ហើយនៅថ្ងៃនោះដដែលខ្លួនក៏បានទាក់ទងទៅឈ្មោះ [redacted] **វណ្ណនារីរតន៍** តាមរយៈផ្ញើសារតាមហ្វេសប៊ុកសួរនាំពីរឿងប្រាក់ពន្ធនេះ។ ចម្លើយរបស់ជនជាប់ចោទនេះមានភាពស៊ីសង្វាក់នឹងចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **វណ្ណនារីរតន៍** ដែលបានឆ្លើយថា រហូតដល់ថ្ងៃទី២៨ ខែមករា ឆ្នាំ២០២០ ទើបឈ្មោះ[redacted]**រចនា** បានទូរស័ព្ទមកប្រាប់ខ្លួនតាមប្រព័ន្ធហ្វេសបុកថា "ខាងអគ្គនាយកដ្ឋានពន្ធដារគេប្រាប់មកថាមានការបាត់ប្រាក់ពន្ធចំនួនជាង ៦លានដុល្លាអាមរិក" ហើយនៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០ ទើបខ្លួនចាប់ផ្តើមពឹងឈ្មោះ[redacted] **បញ្ញាសុជាតា** ឱ្យជួយយកប្រាក់ពន្ធនោះទៅប្តូរជាប្រាក់រៀល ដើម្បីយកមកដាក់បញ្ចូលក្នុងប្រព័ន្ធពន្ធដារសងពន្ធឱ្យអតិថិជនវិញ។

១១-តាមរបាយការណ៍បឋមផ្នែកសវនកម្មផ្ទៃក្នុង នៃធនាគារកាណាឌីយ៉ា អ.ក (ឯកសារលេខ ១៥/៥៩) បានបញ្ជាក់ថា ជនជាប់ចោទឈ្មោះ[redacted]**វណ្ណនារីរតន៍** បានយកប្រាក់មកបង់ពន្ធឱ្យក្រុមហ៊ុន គ័ន ហ្គ័ង ខនស្ត្រាក់សិន ខេមបូឌា ឯ.ក វិញ ចំនួន ០៣លើក៖



Scanned with CamScanner

-លើកទី១. ថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០ ចំនួន ២០,៩៣៨,៥៣៩,២៥៥៛ (ម្ភៃម៉ឺនប្អូនរយសាមសិបប្រាំបី លានប្រាំរយសាមសិបប្រាំបួនពាន់ពីររយហាសិបប្រាំរៀល) ស្មើនឹង ៥,១០៩,៦៣៤$ (ប្រាំលានមួយសែនប្រាំបួនពាន់ ប្រាំមួយរយសាមសិបបួនដុល្លារអាមេរិក)។

-លើកទី២. ថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២០ ចំនួន ៣,៩៣០,០៩២,៨៩២៛ (បីពាន់ប្រាំបួនរយសាមសិបលាន ប្រាំបួនម៉ឺនពីរពាន់ប្រាំបីរយកៅសិបពីររៀល) ស្មើនឹង ៩៨២,៥២៣$ (កៅសិបប្រាំបីម៉ឺនពីរពាន់ប្រាំរយម្ភៃបីដុល្លារអាមេរិក)។ និងមូលប្បទានប័ត្រដែលមានទឹកប្រាក់ ៣៨០,០០០,០០០៛ (បីរយប៉ែតសិបលានរៀល)។

-លើកទី៣. ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២០ ចំនួន ៣៨៨,០៣៦,៥២៧៛ (បីរយប៉ែតសិបប្រាំបីលានបីម៉ឺនប្រាំមួយពាន់ប្រាំរយម្ភៃប្រាំពីររៀល) ស្មើនឹង ៩៧,០០៩$ (ប្រាំបួនម៉ឺនប្រាំពីរពាន់ប្រាំបួនដុល្លារអាមេរិក)។

ដែលរបាយការណ៍នេះមានភាពស៊ីសង្វាក់នឹងចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] វណ្ណនារីរតន៍ ដែលបានឆ្លើយនៅមុខសមត្ថកិច្ច។

១២-តាមចម្លើយស៊ីសង្វាក់របស់ជនជាប់ចោទដូចមានក្នុងសំអាងហេតុចំណុច ១០ និងតាមរបាយការណ៍បឋម ផ្នែកសវនកម្មផ្ទៃក្នុង នៃធនាគារកាណាឌីយ៉ា អ.ក ដូចមានក្នុងសំអាងហេតុចំណុច ១១ ឃើញថា ជនជាប់ចោទ ឈ្មោះ [redacted] វណ្ណនារីរតន៍ បានយកប្រាក់ពន្ធនោះចេញពីធនាគារកាណាឌីយ៉ា អ.ក តាំងពីថ្ងៃទី១៨ ខែមករា ឆ្នាំ២០២០ ដល់ថ្ងៃទី ២៩ ខែមករា ឆ្នាំ២០២០ គិតទៅរយៈពេល ១១ថ្ងៃ ទើបជនជាប់ចោទបញ្ចូលប្រាក់ពន្ធនោះសងមកធនាគារវិញ ហើយការ សងនេះ គឺសងក្រោយថ្ងៃដែលខាងអគ្គនាយកដ្ឋានពន្ធដារសួរនាំពីការមិនបញ្ចូលប្រាក់ពន្ធនោះ។

១៣-ជនជាប់ចោទឈ្មោះ [redacted] វណ្ណនារីរតន៍ ទទួលស្គាល់ថា ខាងធនាគារកាណាឌីយ៉ា អ.ក មិនអនុញ្ញាតឱ្យ បុគ្គលិកយកប្រាក់ពន្ធដែលអតិថិជនយកមកបង់ចេញទៅខាងក្រៅធនាគារទេ ហើយអតិថិជនក៏មិនបានឱ្យខ្លួនយកប្រាក់ ពន្ធនោះចេញទៅខាងក្រៅធនាគារដែរ។ ណាមួយដើមបណ្តឹងរដ្ឋប្បវេណីក៏បានបញ្ជាក់ដែលថា ធនាគារមិនអនុញ្ញាតឱ្យ បុគ្គលិកយកប្រាក់ចេញទៅក្រៅធនាគារទេ។ ប៉ុន្តែជនជាប់ចោទនៅតែយកប្រាក់ដ៏ច្រើននោះចេញទៅក្រៅធនាគារទៀត។

១៤-ជនជាប់ចោទឈ្មោះ [redacted] បញ្ញាសុជាតា បានឆ្លើយថា ឈ្មោះ [redacted] វណ្ណនារីរតន៍ ធ្លាប់វេរប្រាក់ឱ្យខ្លួនចំនួន ០២លើក សរុប ២០០,០០០$ (ម្ភៃម៉ឺនដុល្លារអាមេរិក) លើកទី១ វេរថ្ងៃទី២៧ ខែមករា ឆ្នាំ២០២០ ចំនួន ១០០,០០០$ (ដប់ម៉ឺនដុល្លារអាមេរិក) លើកទី២ វេរថ្ងៃទី២៨ ខែមករា ឆ្នាំ២០២០ ចំនួន ១០០,០០០$ (ដប់ម៉ឺនដុល្លារអាមេរិក) ដោយ ប្រាក់នេះជាប្រាក់ ៦លានដុល្លារអាមេរិកជាង សម្រាប់យកទៅប្តូរជាប្រាក់រៀល ដើម្បីដាក់បញ្ចូលក្នុងប្រព័ន្ធពន្ធដារសងឱ្យ អតិថិជនឱ្យគ្រប់ចំនួន ៦លានដុល្លារអាមេរិកជាងវិញ។ ចម្លើយរបស់ជនជាប់ចោទនេះមានភាពស៊ីសង្វាក់នឹងចម្លើយរបស់ ជនជាប់ចោទឈ្មោះ [redacted] វណ្ណនារីរតន៍ ដែលបានឆ្លើយថា ខ្លួនបានវេរប្រាក់ឱ្យឈ្មោះ [redacted] បញ្ញាសុជាតា ទៅគណនី ABA របស់គាត់ចំនួន ២០០,០០០$ (ម្ភៃម៉ឺនដុល្លារអាមេរិក) ចំនួន ០២ដង ប្រាក់នេះគឺជាប្រាក់ដែលអតិថិជនក្រុមហ៊ុន គ័ន ហ្វ៊ុង ខនស្ត្រាក់សិន (ខេមបូឌា) ឯ.ក យកមកបង់ពន្ធ ដើម្បីឱ្យឈ្មោះ [redacted] បញ្ញាសុជាតា ប្តូរយកទៅបង់ពន្ធឱ្យអតិថិជន វិញ។ ចម្លើយស៊ីសង្វាក់របស់ជនជាប់ចោទទាំង ០២នាក់នេះ គឺបង្ហាញពីសកម្មភាពដែលជនជាប់ចោទបានព្យាយាមបង្វែរ រូបភាពដើមនៃប្រាក់ពន្ធដែលបានតែបំបាត់នោះ យកទៅប្រើប្រាស់តាមរូបភាពដាក់បញ្ចូលក្នុងគណនីធនាគាររបស់ជន



Scanned with CamScanner

ជាប់ចោទ ដោយមិនបានបង្ហាញជាសកម្មភាពនៃការយកប្រាក់នោះទៅប្ដូរជាប្រាក់រៀលដូចការលើកឡើងរបស់ជនជាប់ចោទទេ។

១៥-ជនជាប់ចោទឈ្មោះ [redacted] **វណ្ណនារីរតន៍** បានព្យាយាមឆ្លើយដោះសារថា ប្រាក់ពន្ធចំនួន ៦,១៦០,០០០$ (ប្រាំមួយលានដប់ប្រាំមួយម៉ឺនដុល្លារអាមេរិក) ដែលខ្លួនយកចេញកាលពីថ្ងៃទី១៨ ខែមករា ឆ្នាំ២០២០ នោះ ខ្លួនមិនមានបំណងកិបកេង ឬយកប្រាក់នេះទេ ការដែលខ្លួនយកចេញទៅក្រៅធនាគារ គ្រាន់តែចង់យកប្រាក់នោះទៅប្ដូរជាប្រាក់រៀលដើម្បីចំណេញក្បាលកាក់ ពេលប្ដូរជាប្រាក់រៀលរួចខ្លួននឹងយកមកដាក់បញ្ចូលឱ្យត្រឹមត្រូវក្នុងប្រព័ន្ធរបស់ធនាគារវិញ បើខ្លួនមានចេតនាកិបកេងយកប្រាក់នោះ ខ្លួនមិនបាច់ដាក់បញ្ចូលទឹកប្រាក់ទាំងអស់សងពន្ធឱ្យអតិថិជនវិញទេ។ ហើយជនជាប់ចោទបានលើកឡើងនូវលេសផ្សេងៗ ពីការដែលមិនបានបញ្ចូលប្រាក់ពន្ធនោះភ្លាមៗទៅក្នុងប្រព័ន្ធធនាគារផងដែរ។ តុលាការមិនជឿលើចម្លើយដោះសាររបស់ជនជាប់ចោទនេះទេ តុលាការយល់ថានេះគ្រាន់តែជាលេសដើម្បីឱ្យរូបគេបានរួចផុតពីការចោទប្រកាន់ប៉ុណ្ណោះ ដោយហេតុថាបើជនជាប់ចោទឈ្មោះ [redacted] **វណ្ណនារីរតន៍** មិនមានបំណងកែបំបាត់ប្រាក់ពន្ធនោះ ហើយគ្រាន់តែចង់យកទៅប្ដូរជាប្រាក់រៀល ដើម្បីចំណេញក្បាលកាក់ដូចការអះអាងមែន ហេតុអ្វីមិនយកប្រាក់ប្ដូរជាប្រាក់រៀលភ្លាមៗ ហើយយកប្រាក់នោះមកដាក់បញ្ចូលក្នុងប្រព័ន្ធពន្ធដារ និងធនាគារវិញឱ្យបានឆាប់ដើម្បីសងពន្ធឱ្យអតិថិជនវិញ បែរជាទុកជាយូរថ្ងៃ ទាល់តែដឹងថាខាងអគ្គនាយកដ្ឋានពន្ធដារសួរនាំពីរឿងមិនបញ្ចូលប្រាក់ពន្ធនោះមកខាងធនាគារកាណាឌីយ៉ា អ.ក ហើយដោយសារតែខ្លាចខាងធនាគារកាណាឌីយ៉ា អ.ក ដឹងរឿង ទើបចាប់ផ្ដើមស្វះស្វែងយកប្រាក់ដុល្លារនោះទៅប្ដូរជាប្រាក់រៀលយកមកបញ្ចូលក្នុងប្រព័ន្ធពន្ធដារ និងធនាគារវិញតាមក្រោយ។

១៦-តាមសកម្មភាពដែលជនជាប់ចោទឈ្មោះ [redacted] **វណ្ណនារីរតន៍** ដឹងច្បាស់ថា ធនាគារកាណាឌីយ៉ា អ.ក មិនអនុញ្ញាតឱ្យយកប្រាក់ពន្ធចេញទៅខាងក្រៅធនាគារ ហើយជនជាប់ចោទនៅតែយកចេញដោយមិនឱ្យធនាគារដឹង និងបានព្យាយាមបង្វែររូបភាពដើមនៃប្រាក់ពន្ធដែលបានកែបំបាត់នោះ យកទៅប្រើប្រាស់តាមរូបភាពដាក់បញ្ចូលក្នុងគណនីធនាគាររបស់គេ ដោយមិនយកប្រាក់ពន្ធនោះមកបញ្ចូលសងឱ្យអតិថិជនវិញតាមរយៈធនាគារភ្លាមៗ ទុករហូតដល់ខាងអគ្គនាយកដ្ឋានពន្ធដារសួរមកខាងធនាគារ ទើបស្វះស្វែងដាក់បញ្ចូលប្រាក់ពន្ធនោះចូលក្នុងប្រព័ន្ធពន្ធដារ និងធនាគារវិញនោះ សបញ្ជាក់ឱ្យឃើញថា ជនជាប់ចោទឈ្មោះ [redacted] **វណ្ណនារីរតន៍** ពិតជាមានចេតនាកែបំបាត់ប្រាក់ចំនួន ៦,១៦០,០០០$ (ប្រាំមួយលានដប់ប្រាំមួយម៉ឺនដុល្លារអាមេរិក) ដើម្បីយកទៅធ្វើជាប្រយោជន៍ផ្ទាល់ខ្លួនរបស់គេ និងបក្សពួកដូចការចោទប្រកាន់មែន។

១៧-ជនជាប់ចោទឈ្មោះ [redacted] បញ្ញាសុជាតា បានឆ្លើយថា ឈ្មោះ [redacted] **វណ្ណនារីរតន៍** បានពឹងរូបគេឱ្យជួយយកប្រាក់ទៅប្ដូរនៅក្រុមហ៊ុន លី ហួរ ប្ដូរប្រាក់ ចំនួន ០៣ដង គឺថ្ងៃទី២៨ ខែមករា ឆ្នាំ២០២០ ប្ដូរជិត ៥លានដុល្លារអាមេរិក ថ្ងៃទី០៤ ឬទី០៥ ខែកុម្ភៈ ឆ្នាំ២០២០ ប្ដូរប្រហែលជាជាង ១លានដុល្លារអាមេរិក ហើយថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២០ ប្ដូរ ១០០,០០០$ (ដប់ម៉ឺនដុល្លារអាមេរិក) ដោយប្រាក់ទាំងនោះប្ដូរចេញជាមូលប្បទានប័ត្រ ហើយយកទៅដាក់បញ្ចូលទៅក្នុងប្រព័ន្ធពន្ធដារ ដើម្បីសងពន្ធឱ្យអតិថិជនវិញ។ ចម្លើយរបស់ជនជាប់ចោទនេះមានភាពស៊ីសង្វាក់នឹងចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **វណ្ណនារីរតន៍** និងភស្តុតាងជារូបភាពដែលមាននៅក្នុងផ្លាស់ (ឯកសារលេខ ២៨/២) ដែលក្នុងផ្លាស់នេះ គឺជារូបភាពដែលជនជាប់ចោទឈ្មោះ [redacted] បញ្ញាសុជាតា បានយកប្រាក់ដុល្លារទៅប្ដូរនៅក្រុមហ៊ុន លី ហួរ ប្ដូរប្រាក់។ តាមចម្លើយស៊ីសង្វាក់គ្នានេះសបញ្ជាក់ឱ្យឃើញថា ជនជាប់ចោទឈ្មោះ [redacted] បញ្ញាសុជាតា ជាអ្នកសកម្មក្នុងការជួយចាត់



Scanned with CamScanner

ថែងប្តូរប្រាក់ចំនួន ៦,១៦០,០០០$ (ប្រាំមួយលានដប់ប្រាំមួយម៉ឺនដុល្លារអាមេរិក) ដើម្បីដាក់បញ្ចូលសងពន្ធឱ្យធនាគារកាណាឌីយ៉ា អ.ក វិញ។

១៨-ជនជាប់ចោទឈ្មោះ[redacted] **បញ្ញាសុជាតា** បានព្យាយាមឆ្លើយបដិសេធថា ខ្លួនមិនបានចូលរួមគិតគេងយកប្រាក់ពន្ធរបស់ធនាគារកាណាឌីយ៉ា អ.ក ទេ ហើយខ្លួនក៏មិនដឹងថាឈ្មោះ[redacted] **វណ្ណនារីរតន៍** យកប្រាក់ពន្ធទាំងអស់នោះទៅធ្វើអ្វីដែរ។ ការដែលខ្លួនជួយឈ្មោះ [redacted] **វណ្ណនារីរតន៍** យកប្រាក់ពន្ធនោះចេញទៅក្រៅធនាគារកាណាឌីយ៉ា អ.ក ដោយសារតែមនោសញ្ចេតនាការរាប់អានគ្នា ពីព្រោះគាត់ធ្លាប់មានគុណជួយខ្លួនឱ្យខ្ចីប្រាក់គាត់ ២០,០០០$ (ពីរម៉ឺនដុល្លារអាមេរិក) ដើម្បីសងគេកាលពីឆ្នាំ២០១៦។ មួយវិញទៀតការដែលខ្លួនជួយប្តូរប្រាក់ឱ្យឈ្មោះ [redacted] **វណ្ណនារីរតន៍** ដោយសារឈ្មោះ [redacted] **វណ្ណនារីរតន៍** នៅក្រៅប្រទេស ហើយឪពុកម្តាយគាត់ចាស់ៗ និងថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២០ ឈ្មោ[redacted] **វណ្ណនារីរតន៍** ត្រឡប់មកប្រទេសខ្មែរវិញ តែគាត់រវល់ជាមួយធនាគារកាណាឌីយ៉ា អ.ក ទើបខ្លួនទៅជួយប្តូរឱ្យទៀត។ ខ្លួនមិនបានអ្វីមកវិញពីការជួយនោះទេ។ តុលាការមិនជឿលើចម្លើយបដិសេធរបស់ជនជាប់ចោទនេះទេ តុលាការយល់ថានេះគ្រាន់តែជាលេសដើម្បីឱ្យរូបគេបានរួចផុតពីការចោទប្រកាន់ប៉ុណ្ណោះ ផ្ទុយទៅវិញតាមរយៈសកម្មភាពដែលជនជាប់ចោទបានជួយជនជាប់ចោទឈ្មោះ[redacted] **វណ្ណនារីរតន៍** ជម្លៀសប្រាក់ចំនួន ៦,១៦០,០០០$ (ប្រាំមួយលានដប់ប្រាំមួយម៉ឺនដុល្លារអាមេរិក) ដែលជាចំនួនដ៏ច្រើនចេញទៅក្រៅស្នាក់ការកណ្តាលធនាគារកាណាឌីយ៉ា អ.ក និងជួយប្តូរប្រាក់យកមកបញ្ចូលក្នុងប្រព័ន្ធពន្ធដារ និងធនាគារ **ដើម្បីបង់ពន្ធសងឱ្យអតិថិជនវិញរហូតដល់គ្រប់ចំនួន** និងច្រើនដងទាំងដែលជនជាប់ចោទបានដឹងច្បាស់ថា ប្រាក់នោះជាប្រាក់ពន្ធរបស់អតិថិជនដែលយកមកបង់ពន្ធតាមរយៈធនាគារកាណាឌីយ៉ា អ.ក តែនៅតែជួយជ្រោមជ្រែង និងជួយសម្រួលទៀតនោះ សបញ្ជាក់ឱ្យឃើញថា ជនជាប់ចោទបានដឹងពីចេតនាពិតប្រាកដរបស់ជនជាប់ចោទឈ្មោះ[redacted] **វណ្ណនារីរតន៍** ក្នុងការកែបំបាត់ប្រាក់ពន្ធចំនួន ៦,១៦០,០០០$ (ប្រាំមួយលានដប់ប្រាំមួយម៉ឺនដុល្លារអាមេរិក) ដើម្បីយកទៅធ្វើជាប្រយោជន៍ផ្ទាល់ខ្លួន ហើយជនជាប់ចោទនៅតែជួយជ្រោមជ្រែង និងជួយសម្រួលឱ្យការកែបំបាត់ប្រាក់ពន្ធរបស់ជនជាប់ចោទឈ្មោះ[redacted] **វណ្ណនារីរតន៍** រហូតបានសម្រេច។

១៩-តាមភស្តុតាងជារូបភាពដែលចាប់យកចេញពីកាមេរ៉ាសុវត្ថិភាពលេខ ៧៧/១ ដល់ ៧៧/៧ បង្ហាញឱ្យឃើញថា នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២០ វេលាម៉ោង១០ និង ១០នាទីព្រឹក ជនជាប់ចោទឈ្មោះ[redacted]ហៀង និងសន្តិសុខ ០២ នាក់ទៀតបានលីថង់ខ្មៅម្នាក់មួយៗដោយមានឈ្មោះ[redacted] **បញ្ញាសុជាតា** រួមដំណើរជាមួយយកទៅដាក់នៅបន្ទប់ ៥០២ ជាន់ទី០៥ នៃស្នាក់ការកណ្តាលអគារកាណាឌីយ៉ា អ.ក និងនៅវេលាម៉ោង ១១ និង ៣៩នាទីព្រឹក នាថ្ងៃខែឆ្នាំដដែល ឈ្មោះ[redacted] **វណ្ណនារីរតន៍** បានរៀបចំប្រាក់មួយចំនួនដាក់ក្នុងថង់ខ្មៅតូចមួយ ហើយនៅវេលាម៉ោង ១១ និង ៤៤នាទីព្រឹកនាថ្ងៃខែឆ្នាំដដែល ឈ្មោះ [redacted]ហៀង បានមកបន្ទប់បង់ពន្ធជួបឈ្មោ[redacted]**វណ្ណនារីរតន៍** នៅបញ្ជរបេឡាលេខ១ រួចឈ្មោះ [redacted] **វណ្ណនារីរតន៍** បានប្រគល់ប្រាក់ក្នុងថង់ខ្មៅតូចដែលរូបគេបានរៀបចំកាលពីវេលាម៉ោង ១១ និង ៣៩នាទីព្រឹកឱ្យទៅឈ្មោ[redacted]ហៀង ហើយឈ្មោះ [redacted]ហៀង ក៏បានយកប្រាក់ក្នុងថង់ខ្មៅតូចនោះចុះទៅក្រោម។

២០-ជនជាប់ចោទឈ្មោះ [redacted]**វណ្ណនារីរតន៍** បានឆ្លើយថា ភស្តុតាងជារូបភាពកាលពីថ្ងៃទី១៨ ខែមករា ឆ្នាំ២០២០ វេលាម៉ោង១១ និង ៣៩នាទីព្រឹក ដែលចាប់យកចេញពីកាមេរ៉ាសុវត្ថិភាពលេខ ៧៧/៣ ឃើញខ្លួនហុចប្រាក់ដាក់ក្នុងថង់ខ្មៅតូចឱ្យឈ្មោះ[redacted]ៀង គឺជាប្រាក់ផ្ទាល់ខ្លួនដែលខ្លួនឱ្យឈ្មោះ [redacted]ហៀង យកទៅប្តូរជាប្រាក់យ៉ូរ៉ូ ពីព្រោះខ្លួន

ត្រូវទៅដើរលេងនៅក្រៅប្រទេស។ ប្រាក់នេះជនជាប់ចោទឈ្មោះ [redacted] ហៀង បានឆ្លើយថា ថ្ងៃទី១៨ ខែមករា ឆ្នាំ២០២០ ក្រោយពីដឹកជញ្ជូនថង់ខ្មៅទាំង ០៣ទៅជាន់ទី៥ ហើយឈ្មោះ [redacted] **វណ្ណនារីរតន៍** ក៏បានហៅខ្លួនទៅយកថង់ខ្មៅមួយទៀតនៅកន្លែងធ្វើការគាត់ ហើយឈ្មោះ [redacted] **វណ្ណនារីរតន៍** ឱ្យខ្លួនជួយយកមកទុកនៅខាងក្រោម ចាំគាត់ចេញទៅផ្ទះ ចាំគាត់មកយក គាត់មិនបានប្រាប់ថាជាអ្វីទេ។ តាមចម្លើយដែលឆ្លើយមិនស៊ីសង្វាក់គ្នារបស់ជនជាប់ចោទទាំង ០២នាក់នេះ និងជនជាប់ចោទមិនមានភស្តុតាងណាមកបញ្ជាក់នោះ ធ្វើឱ្យតុលាការមិនជឿលើចម្លើយរបស់ពួកគេទាំង ០២នាក់នោះទេ តុលាការយល់ថានេះគ្រាន់តែជាលេសដោះសារ ដើម្បីឱ្យពួកគេរួចផុតពីការចោទប្រកាន់ប៉ុណ្ណោះ។

២១-ផ្ទុយទៅវិញតាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ហៀង ដែលឆ្លើយនៅមុខចៅក្រមស៊ើបសួរថា បន្ទាប់ពីជួយដឹកជញ្ជូនអីវ៉ាន់ថង់ខ្មៅឡើងទៅជាន់ទី០៥ រួច ជនជាប់ចោទឈ្មោះ [redacted] **វណ្ណនារីរតន៍** បានឱ្យប្រាក់ខ្លួនទុកទិញបាយហូប។ តាមចម្លើយនេះ, តាមសំអាងហេតុចំណុច ២០ និងតាមភស្តុតាងជារូបភាពដែលថតយកចេញពីកាមេរ៉ាសុវត្ថិភាពលេខ ៧៧/១ ដល់ ៧៧/៧ ដូចមានក្នុងសំអាងហេតុចំណុច ១៩ សបញ្ជាក់ឱ្យឃើញថា ប្រាក់ដែលដាក់ក្នុងថង់ខ្មៅតូចដែលជនជាប់ចោទឈ្មោះ [redacted] **វណ្ណនារីរតន៍** ប្រគល់ឱ្យទៅជនជាប់ចោទឈ្មោះ [redacted] ហៀង ដូចមានក្នុងភស្តុតាងជារូបភាពដែលថតយកចេញពីកាមេរ៉ាសុវត្ថិភាពលេខ ៧៧/៣ នោះ គឺជាប្រាក់ដែលឈ្មោះ [redacted] **វណ្ណនារីរតន៍** ប្រគល់ឱ្យទៅជនជាប់ចោទឈ្មោះ [redacted] ហៀង ជាថ្នូរនឹងការជួយដឹកជញ្ជូនថង់ខ្មៅចំនួន ០៣ខាងលើ។

២២-ជនជាប់ចោទឈ្មោះ [redacted] **បញ្ញាសុជាតា** បានឆ្លើយថា នៅល្ងាចថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២០ ពេលម៉ោងចេញធ្វើការខ្លួនបានពឹងឈ្មោះ [redacted] ហៀង ឱ្យជូនទៅប្តូរប្រាក់នៅក្រុមហ៊ុន លី ហួរ ប្តូរប្រាក់ ពីព្រោះថ្ងៃនោះខ្លួនទៅយកប្រាក់ពីឈ្មោះ [redacted] **វណ្ណនារីរតន៍** នៅស្នាក់ការកណ្តាលធនាគារការណាឌីយ៉ា អ.ក ដើម្បីយកទៅប្តូរប្រហែល ១០០,០០០$ (ដប់ម៉ឺនដុល្លាអាមេរិក) ប្រាក់នេះជាប្រាក់ដែលឈ្មោះ [redacted] **វណ្ណនារីរតន៍** ឱ្យជួយប្តូរដើម្បីយកទៅដាក់ចូលក្នុងប្រព័ន្ធពន្ធដារសងធនាគារវិញ។ ចម្លើយនេះស៊ីសង្វាក់នឹងចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ហៀង ដែលបានឆ្លើយថា ឈ្មោះ [redacted] **បញ្ញាសុជាតា** បានពឹងខ្លួនឱ្យជួយជូនទៅក្រុមហ៊ុន លី ហួរ ប្តូរប្រាក់ ហើយពេលនោះខ្លួនបានជិះម៉ូតូម៉ាកដេវឌុបជូនគាត់ទៅប្តូរប្រាក់។ តាមចម្លើយស៊ីសង្វាក់គ្នានេះសបញ្ជាក់ឱ្យឃើញថា កាលពីថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២០ ជនជាប់ចោទឈ្មោះ [redacted] ហៀង ពិតជាបានជូនជនជាប់ចោទឈ្មោះ [redacted] **បញ្ញាសុជាតា** ទៅប្តូរប្រាក់នៅក្រុមហ៊ុន លី ហួរ ប្តូរប្រាក់ ដើម្បីយកមកបង់ពន្ធសងឱ្យអតិថិជនក្រុមហ៊ុន គ័ន ហ្គ័ង ខនស្រ្តាក់ស៊ិន ខេមបូឌា ឯ.ក ពិតមែន។

២៣-ជនជាប់ចោទឈ្មោះ ទុត **បញ្ញាសុជាតា** និងជនជាប់ចោទឈ្មោះ [redacted] ហៀង បានលើកហេតុផលថា ការដែលខ្លួនឈ្មោះ [redacted] បញ្ញាសុជាតា ពឹងឈ្មោះ [redacted] ហៀង ឱ្យជូនទៅប្តូរប្រាក់នេះ ដោយសារតែថ្ងៃនោះពួកខ្លួនជួបគ្នាដោយចៃដន្យនៅស្នាក់ការកណ្តាលធនាគារកាណាឌីយ៉ា អ.ក ក៏បានសុំឱ្យខ្លួនឈ្មោះ [redacted] ហៀង ជូនទៅប្តូរប្រាក់តែម្តង និងលើកនូវហេតុផលផ្សេងៗទៀត និងបានបញ្ជាក់ថាខ្លួនឈ្មោះ [redacted] បញ្ញាសុជាតា គ្រាន់តែប្រាប់ខ្លួនឈ្មោះ [redacted] ហៀង ថាឱ្យជួយជូន



Scanned with CamScanner

ទៅប្តូរប្រាក់បន្តិច ដោយមិនបានប្រាប់ថាជាប្រាក់អ្វីទេ។ តុលាការយល់ថានេះគ្រាន់តែជាចម្លើយដោះសារដែលមិនសម
ហេតុផល និងមិនមានភស្តុតាង ដើម្បីជាលេសឱ្យរួចផុតពីការចោទប្រកាន់ប៉ុណ្ណោះ។

២៤-ជនជាប់ចោទឈ្មោះ [redacted] ហៀង បានព្យាយាមឆ្លើយបដិសេធថា ខ្លួនមិនដឹងថាក្នុងថង់ខ្មៅដែលខ្លួនបានជួយ
ជញ្ជូនឈ្មោះ [redacted] វណ្ណនារីរតន៍ ពីជាន់ផ្ទាល់ដីឡើងទៅជាន់ទី៥ កាលពីថ្ងៃទី១៨ ខែមករា ឆ្នាំ២០២០ ជាអ្វីនោះទេ ហើយ
ការជួយជញ្ជូននេះខ្លួនក៏មិនបានទទួលផលប្រយោជន៍អ្វីដែរ។ ហើយខ្លួនក៏មិនបានចូលរួមកិបកេងប្រាក់របស់ធនាគារកាណាឌី
យ៉ា អ.ក ដែរ។ តុលាការមិនជឿលើចម្លើយបដិសេធរបស់ជនជាប់ចោទរូបនេះទេ ផ្ទុយទៅវិញតាមសកម្មភាពដែលជនជាប់
ចោទឈ្មោះ [redacted] ហៀង ជួយជញ្ជូនថង់ខ្មៅដែលដាក់ប្រាក់ចំនួន ៦,៦១០,០០០$ (ប្រាំមួយលានដប់ប្រាំមួយម៉ឺនដុល្លាអាមេ
រិក) ទៅបន្ទប់ទទួលភ្ញៀវជាន់ទី៥ នៃស្នាក់ការកណ្តាលអគារធនាគារកាណាឌីយ៉ា អ.ក ដែលជាប្រាក់របស់ក្រុមហ៊ុន គ័ន
ហ៊្គែង ខនស្ត្រាក់សិន ខេមបូឌា ឯ.ក បានយកមកបង់ពន្ធជូនរដ្ឋតាមរយៈធនាគារកាណាឌីយ៉ា អ.ក, ជួយជូនឈ្មោះ [redacted]
បញ្ញាសុជាតា យកប្រាក់ទៅប្តូរនៅក្រុមហ៊ុន លី ហួរ ប្តូរប្រាក់ ដើម្បីយកប្រាក់នោះមកដាក់បង់ពន្ធឱ្យក្រុមហ៊ុន គ័ន ហ៊្គែង
ខនស្ត្រាក់សិន ខេមបូឌា ឯ.ក វិញ កាលពីថ្ងៃទី១៤ ខែមករា ឆ្នាំ២០២០ និងការដែលជនជាប់ចោទឈ្មោះ [redacted] ហៀង
ទទួលបានផលប្រយោជន៍ជាប្រាក់មួយចំនួនពីឈ្មោះ [redacted] វណ្ណនារីរតន៍ បន្ទាប់ពីរូបគេបានជួយជញ្ជូនថង់ខ្មៅទៅទុកនៅ
ជាន់ទី៥ នោះ សបញ្ជាក់ឱ្យឃើញថា ជនជាប់ចោទឈ្មោះ [redacted] ហៀង បានដឹងថាក្នុងថង់ខ្មៅទាំង ០៣ដែលរូបគេជួយ
ជញ្ជូនកាលពីថ្ងៃទី១៨ ខែមករា ឆ្នាំ២០២០ នោះ គឺជាប្រាក់ពន្ធដែលជនជាប់ចោទឈ្មោះ [redacted] វណ្ណនារីរតន៍ មានចេតនា
កែបំបាត់ពីធនាគារកាណាឌីយ៉ា អ.ក ហើយជនជាប់ចោទរូបនេះនៅតែជួយជញ្ជូនប្រាក់នោះ និងជួយជូនយកប្រាក់នោះ
ទៅប្តូរទៀតក្នុងចេតនាជួយសម្រួលដល់ការកែបំបាត់ប្រាក់ពន្ធចំនួន ៦,៦១០,០០០$ (ប្រាំមួយលានដប់ប្រាំមួយម៉ឺនដុល្លា
អាមេរិក) របស់ជនជាប់ចោទឈ្មោះ [redacted] វណ្ណនារីរតន៍ ឱ្យបានសម្រេច។

២៥-ជនជាប់ចោទឈ្មោះ [redacted] រចនា បានឆ្លើយបដិសេធថា នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២០ ខ្លួនមិនបានចូលរួម
កិបកេងប្រាក់ពន្ធរបស់ធនាគារកាណាឌីយ៉ា អ.ក ជាមួយឈ្មោះ [redacted] វណ្ណនារីរតន៍ នោះទេ ថ្ងៃនោះខ្លួនបានសុំច្បាប់ឈឺ
រាគ។ ណាមួយពេលទទួលប្រាក់ពន្ធពីអតិថិជន ឈ្មោះ [redacted] វណ្ណនារីរតន៍ មិនបានបញ្ចូលទឹកប្រាក់ទៅក្នុងប្រព័ន្ធធនាគារ
គាត់បញ្ចូលតែក្នុងប្រព័ន្ធពន្ធដារ បើអត់បញ្ចូលទឹកប្រាក់ក្នុងប្រព័ន្ធធនាគារទេ គឺខ្លួនមិនដឹងទេ។

២៦-ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណចរិយា បានឆ្លើយបដិសេធថា ខ្លួនមិនដឹងរឿងជនជាប់ចោទឈ្មោះ [redacted] វណ្ណន
នារីរតន៍ យកប្រាក់ពន្ធរបស់ធនាគារកាណាឌីយ៉ា អ.ក ហើយក៏មិនបានចូលរួមដែរ។ ខ្លួនដឹងថាធនាគារបាត់ប្រាក់នៅ
ពេលដែលគេចុះមកធ្វើសវនកម្ម តែមិនដឹងថាបាត់ប៉ុន្មាន អ្នកណាជាអ្នកយកនោះទេ។ ថ្ងៃទី១៨ ខែមករា ឆ្នាំ២០២០ ខ្លួន
មកធ្វើការធម្មតា តែមិនបានដឹងថាក្រុមហ៊ុន គ័ន ហ៊្គែង ខនស្ត្រាក់សិន ខេមបូឌា ឯ.ក យកប្រាក់មកបង់ពន្ធនោះទេ ហើយ
ក៏មិនដឹងថាឈ្មោះ [redacted] វណ្ណនារីរតន៍ បានព្រីនបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធលេខ ០០៤០៤៥៨៣៨ និងលេខ ០០៤០
៤៥៨៣៩ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០២០ ឱ្យទៅក្រុមហ៊ុននេះដែរ។ ការងារខ្លួនជាអ្នកផែកមើលប្រព័ន្ធធនាគារ មិនមែន



Scanned with CamScanner

ផែកមើលប្រព័ន្ធពន្ធដារទេ ដូចនេះបើបេឡាករបញ្ចូលទឹកប្រាក់ត្រឹមតែប្រព័ន្ធពន្ធដារ ហើយព្រីនតែបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធនោះ ខ្លួនមិនដឹងថាមានអតិថិជនយកប្រាក់ពន្ធមកបង់ទេ។

២៧-ជនជាប់ចោទឈ្មោះ[redacted]វណ្ណនារីរតន៍ បានឆ្លើយថា ប្រាក់ពន្ធចំនួន ៦,១៦០,០០០$ (ប្រាំមួយលានដប់ប្រាំមួយម៉ឺនដុល្លារអាមេរិក) ដែលខ្លួនយកកាលពីថ្ងៃទី១៨ ខែមករា ឆ្នាំ២០២០ នោះ ឈ្មោះ [redacted]រចនា និងឈ្មោះ សំ សុវណ្ណចរិយា មិនបានដឹង និងមិនបានសហការណ៍ជាមួយខ្លួនទេ ពួកគេអាចដឹងថាមានអតិថិជនយកសាច់ប្រាក់នេះមកបង់ពន្ធលុះត្រាតែខ្លួនយកទឹកប្រាក់នោះបញ្ចូលទៅក្នុងប្រព័ន្ធធនាគារ ពីព្រោះពួកគាត់ទាំង ២នាក់ត្រួតពិនិត្យតែលើប្រព័ន្ធធនាគារប៉ុណ្ណោះ។

២៨-ចម្លើយបដិសេធរបស់ជនជាប់ចោទឈ្មោះ[redacted] រចនា, ឈ្មោះ [redacted]សុវណ្ណចរិយា ដូចមានក្នុងសំអាងហេតុចំណុច ២៥, ២៦ នោះ តុលាការមិនជឿនោះទេ ការបដិសេធ និងមូលហេតុរបស់ជនជាប់ចោទទាំង ០២នាក់នេះគ្រាន់តែជាលេសដែលមិនមានមូលដ្ឋាន និងភស្តុតាងដែលអាចឱ្យតុលាការជឿបាន។ ចំណែកចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted]ណ្ណនារីរតន៍ ដូចមានក្នុងសំអាងហេតុចំណុច ២៧ តុលាការយល់ថា គ្រាន់តែជាចម្លើយមួយដែលជួយដោះសារឱ្យជនជាប់ចោទឈ្មោះ[redacted]រចនា, ឈ្មោះ[redacted] សុវណ្ណចរិយា ប៉ុណ្ណោះ តុលាការមិនជឿលើចម្លើយរបស់ជនជាប់ចោទនេះទេ។

២៩-ជនជាប់ចោទឈ្មោះ [redacted] រចនា, ឈ្មោះ[redacted]សុវណ្ណចរិយា និងឈ្មោះ [redacted] វណ្ណនារីរតន៍ បានឆ្លើយស៊ីសង្វាក់គ្នាថា នៅពេលបេឡាករទទួលបន្ទុកបង់ពន្ធបានទទួលប្រាក់បង់ពន្ធពីអថិតិជនចាប់ពី ៤០,០០០,០០០៛ (សែសិបលានរៀល) ឡើងទៅ បេឡាករនឹងបញ្ចូលទឹកប្រាក់ពន្ធនេះទៅក្នុងប្រព័ន្ធពន្ធដារ និងព្រីនបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធ ព្រមទាំងព្រីនប័ណ្ណដាក់ប្រាក់ធនាគារមួយទៀតយកមកឱ្យខ្លួនឈ្មោះ [redacted]សុវណ្ណចរិយា ត្រួតពិនិត្យ បើពិនិត្យឃើញថាទឹកប្រាក់ពន្ធ និងឯកសារត្រឹមត្រូវ ខ្លួនឈ្មោះ [redacted] សុវណ្ណចរិយា នឹងអនុញ្ញាត (Authorize) នៅលើកុំព្យូទ័រ និងចុះហត្ថលេខានៅលើប័ណ្ណដាក់ប្រាក់ធនាគារ រួចហើយត្រូវបញ្ជូនបន្តទៅខ្លួនឈ្មោះ[redacted]រចនា ដើម្បីផ្ទៀងផ្ទាត់បញ្ជាក់អនុញ្ញាត (Authorize) ពីលើម្នាក់ទៀតថាប្រាក់ពន្ធដែលទទួល និងឯកសារនោះត្រឹមត្រូវ ខ្លួនឈ្មោះ[redacted]រចនា និងចុះហត្ថលេខាបញ្ជាក់នៅលើប័ណ្ណដាក់ប្រាក់ធនាគារនោះ ទើបប្រាក់ពន្ធនោះអាចផ្ទាក់ចូលទៅក្នុងគណនីរបស់ពន្ធដារ និងធនាគារបាន។ ហើយជនជាប់ចោទឈ្មោះ [redacted] វណ្ណនារីរតន៍ ក៏បានបញ្ជាក់ផងដែរថា ខ្លួនត្រូវយកប្រាក់ពន្ធនោះទៅឱ្យឈ្មោះ [redacted] សុវណ្ណចរិយា និងឈ្មោះ [redacted] រចនា រាប់ និងពិនិត្យប្រាក់ជាក់ស្តែងខ្លាចក្រែងប្រាក់បាត់ ឬរហែក ហើយឈ្មោះ [redacted] សុវណ្ណចរិយា និងឈ្មោះ [redacted]រចនា និងផ្ទៀតផ្ទាត់ប្រាក់ពន្ធនោះជាមួយប្រព័ន្ធធនាគារ ប័ណ្ណដាក់ប្រាក់ធនាគារ និងបង្កាន់បញ្ជាក់ការបង់ប្រាក់ពន្ធ។

៣០-តាមចម្លើយរបស់មេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណីបញ្ជាក់ថា ជាគោលការណ៍រាល់ប្រតិបត្តិការទាំងអស់ដែលចុះក្នុងប្រព័ន្ធពន្ធដារ និងប្រព័ន្ធធនាគារ អ្នកគ្រប់គ្រងត្រូវតែដឹង ពីព្រោះពេលចុះទឹកប្រាក់ចូលក្នុងប្រព័ន្ធពន្ធដារត្រូវមានការអនុញ្ញាតពីអ្នកគ្រប់គ្រងមុននឹងព្រីនបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធឱ្យអតិថិជន។

៣១-តាមចម្លើយរបស់ជនជាប់ចោទទាំង ០៣នាក់ដូចមានក្នុងសំអាងហេតុចំណុច ២៩ និងតាមចម្លើយរបស់មេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណីដូចមានក្នុងសំអាងហេតុចំណុច ៣០ អាចកំណត់បានថា ប្រាក់ពន្ធចាប់ពី ៤០,០០០,០០០៛ (សែសិបលានរៀល) ឡើងទៅ ត្រូវតែឆ្លងកាត់ជនជាប់ចោទឈ្មោះ[redacted]សុវណ្ណចរិយា និងឈ្មោះ [redacted]



Scanned with CamScanner

រចនា ហើយបេឡាករក៏ត្រូវយកប្រាក់ជាក់ស្តែងទៅឱ្យជនជាប់ចោទឈ្មោះ សំ សុវណ្ណចរិយា និងឈ្មោះ សាធ រចនា រាប់និងពិនិត្យផងដែរ។

៣២-ជនជាប់ចោទឈ្ម[redacted]ចនា បានឆ្លើយថា ក្រោយពីខ្លួនបានដឹងរឿងបាត់ប្រាក់ពន្ធ នៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០២០ ខ្លួនបានទាក់ទងទៅឈ្មោះ [redacted] វឌ្ឍនៈនារីរតន៍ តាមរយៈផ្ញើសារតាមហ្វេសប៊ុកសួរឈ្មោះ [redacted] វឌ្ឍនៈនារីរតន៍ ថា "មានបានទទួលប្រាក់បង់ពន្ធជូនក្រុមហ៊ុនមួយនេះ ឬអត់" គាត់ឆ្លើយវិញថា "គាត់គិតមើលសិន" ហើយក្នុងថ្ងៃដដែលនោះ ឈ្មោ[redacted]វឌ្ឍនៈនារីរតន៍ បានប្រាប់មកវិញថា "គាត់បានយកប្រាក់នោះមិនទាន់បានបញ្ចូលទៅទេ" ហើយខ្លួនក៏បានបញ្ចុះបញ្ចូលឱ្យឈ្មោះ [redacted] វឌ្ឍនៈនារីរតន៍ ដាក់ប្រាក់សងវិញ។ ប៉ុន្តែចម្លើយរបស់ជនជាប់ចោទនេះត្រូវបានជនជាប់ចោទឈ្មោះ [redacted] វឌ្ឍនៈនារីរតន៍ បដិសេធថា ពេលឈ្មោះ [redacted]ចនា ទាក់ទងមកខ្លួននោះ ខ្លួនមិនបាននិយាយអ្វីតបវិញទេ គ្រាន់តែបាននិយាយថា "ចាំគិតមើលសិន" ពីព្រោះពេលនោះខ្លួននៅប្រទេសក្រៅ បាត់ទំនាក់ទំនង ណាមួយប្រាក់មិននៅជាប់នឹងខ្លួន ក្រោយមកខ្លួនមកជួបខាងធនាគារកាណាឌីយ៉ា អ.ក តែម្តង។ ហើយខ្លួនក៏មិនបាននិយាយអង្វរឈ្មោះ [redacted] រចនា។

៣៣-ជនជាប់ចោទឈ្មោះ [redacted] រចនា បានឆ្លើយថា នៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០២០ ខាងអគ្គនាយកដ្ឋានពន្ធដារបានតេទាក់ទងខ្លួនថា "មានក្រុមហ៊ុន គីន ហ្គ័ង ខនស្ត្រាក់សិន ខេមបូឌា ឯ.ក មកបង់ពន្ធនៅធនាគារអត់ជួយឆែកមើលផង"។ ថ្ងៃនោះដដែលខ្លួនក៏បានទាក់ទងទៅឈ្មោះ [redacted] វឌ្ឍនៈនារីរតន៍ ខ្លួនឯង ដោយមិនបានប្រាប់ខាងធនាគារកាណាឌីយ៉ា អ.ក ទេ ហើយខាងធនាគារក៏អត់ទាន់ដឹងរឿងបាត់ប្រាក់នេះដែរ ហើយមូលហេតុដែលខ្លួនមិនទាន់រាយការណ៍ប្រាប់ធនាគារ ពីព្រោះដើម្បីលួងលោមឈ្មោះ [redacted] វឌ្ឍនៈនារីរតន៍ ឱ្យដាក់ប្រាក់សងវិញ ដើម្បីកុំឱ្យបាត់បង់ផលប្រយោជន៍ធនាគារ និងខ្លាចបើមានការរាយការណ៍ទៅធនាគារ ឈ្មោះ [redacted] វឌ្ឍនៈនារីរតន៍ អាចគេចវេះមិនយកប្រាក់មកបង់ពន្ធ និងដោយសារឈ្មោះ [redacted] វឌ្ឍនៈនារីរតន៍ អង្វរខ្លួនមិនឱ្យប្រាប់ធនាគារ។ ខ្លួនគិតថាពេលលួងលោមឱ្យឈ្មោះ [redacted] វឌ្ឍនៈនារីរតន៍ យកប្រាក់មកដាក់សងធនាគារវិញគ្រប់អស់ ទើបខ្លួនរាយការណ៍ជូនធនាគារ។ នេះជាហេតុផលមួយដែលមិនអាចឱ្យតុលាការជឿ និងទទួលយកបានឡើយ។

៣៤-តាមចម្លើយដែលមិនមានភាពស៊ីសង្វាក់របស់ជនជាប់ចោទទាំង ០២នាក់ដូចមានក្នុងសំអាងហេតុចំណុច ៣២ និងតាមចម្លើយដែលមិនសមហេតុផលរបស់ជនជាប់ចោទឈ្មោះ [redacted] រចនា ដូចមានក្នុងសំអាងហេតុចំណុច ៣៣ សបញ្ជាក់ឱ្យឃើញថា ទី១. ជនជាប់ចោទឈ្មោះ [redacted] រចនា កំពុងព្យាយាមរកលេសដែលមិនសមហេតុផល ដើម្បីបញ្ជាក់ថា រូបគេមិនពាក់ព័ន្ធនឹងសកម្មភាពកែបំបាត់ប្រាក់ពន្ធចំនួន ៦,១៦០,០០០$ (ប្រាំមួយលានដប់ប្រាំមួយម៉ឺនដុល្លារអាមេរិក) របស់ជនជាប់ចោទឈ្មោះ [redacted] វឌ្ឍនៈនារីរតន៍ និងទី២ ជនជាប់ចោទឈ្មោះ [redacted] រចនា បានចូលរួមលាក់បាំងបំបាត់ដានមិនឱ្យធនាគារកាណាឌីយ៉ា អ.ក ដឹងថាពួកគេបានកែបំបាត់ប្រាក់ពន្ធរបស់អតិថិជនដែលយកមកបង់តាមរយៈធនាគារកាណា ឌីយ៉ា អ.ក។



Scanned with CamScanner

៣៥-ជនជាប់ចោទឈ្មោះ [redacted] វណ្ណនារីរតន៍ បានឆ្លើយថា នៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២០ ខ្លួនបានផ្ញើសារប្រាប់
ឈ្មោះ [redacted] រចនា ថាខ្លួនបានយកប្រាក់ពន្ធដាក់សងឱ្យអតិថិជនវិញហើយ។ ចម្លើយរបស់ជនជាប់ចោទនេះមានភាពស៊ី
សង្វាក់នឹងចម្លើយជនជាប់ចោទឈ្មោះ [redacted] រចនា ដែលបានឆ្លើយថា នៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០២០ ឈ្មោះ [redacted]
វណ្ណនារីរតន៍ ប្រាប់ខ្លួនថា គាត់បានបញ្ចូលប្រាក់ទៅក្នុងប្រព័ន្ធពន្ធដារសងធនាគារតាមមូលប្បទានប័ត្រចំនួន ០៣វិញ
ហើយ។ ចម្លើយស៊ីង្វាក់គ្នានេះសបញ្ជាក់ឱ្យឃើញថា ជនជាប់ចោទឈ្មោះ [redacted] រចនា បានដឹងច្បាស់ពីពេលវេលា និង
សកម្មភាពដាក់ប្រាក់ពន្ធសងចូលមកធនាគារកាណាឌីយ៉ា អ.ក វិញរបស់ជនជាប់ចោទឈ្មោះ [redacted] វណ្ណនារីរតន៍។

៣៦-ដើមបណ្តឹងរដ្ឋប្បវេណីបានឆ្លើយថា ប្រតិបត្តិការដែលដាក់ប្រាក់សងលើកទី១ នៅថ្ងៃទី២៨ ខែមករា ឆ្នាំ
២០២០ ត្រូវបានឈ្មោះ [redacted] រចនា លុបវិញនៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០ និងប្រតិបត្តិការដាក់ប្រាក់សងលើកទី២
នៅថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២០ ត្រូវបានឈ្មោះ [redacted] រចនា លុបវិញនៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ ២០២០។ ប្រតិបត្តិការដែល
ដាក់ប្រាក់សងលើកទី១ និងទី ២នេះ ខាងធនាគារកាណាឌីយ៉ា អ.ក មិនទាន់ដឹងរឿងមានការកិបកេងប្រាក់ពន្ធនោះទេ អ៊ីចឹង
ហើយការធ្វើប្រតិបត្តិការដាក់ប្រាក់ចូលវិញនេះ គឺជនជាប់ចោទទាំងអស់ដែលពាក់ព័ន្ធជាអ្នកប្រតិបត្តិការ លុះដល់ថ្ងៃទី១០
ជាង ខែមករា ឆ្នាំ២០២០ ទើបខាងធនាគារដឹងរឿងបាត់ប្រាក់ពន្ធ។ ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីនេះត្រូវបានជន
ជាប់ចោទឈ្មោះ [redacted] រចនា ទទួលស្គាល់ថា ប្រតិបត្តិការដែលឈ្មោះ [redacted] វណ្ណនារីរតន៍ ដាក់ប្រាក់ពន្ធសងវិញនៅ
លើកទី១ គឺថ្ងៃទី២៨ ខែមករា ឆ្នាំ២០២០ ខ្លួនបានលុបប្រតិបត្តិការនេះវិញនៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០ និងប្រតិបត្តិ
ការដែលឈ្មោះ [redacted] វណ្ណនារីរតន៍ ដាក់ប្រាក់ពន្ធសងវិញកាលពីថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២០ ខ្លួនបានលុបចោលទៀតនៅ
ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០។ តែការលុបនេះ គឺកុំឱ្យជាន់គ្នា ០២ដងជាមួយប្រតិបត្តិការលើកមុនដែលឈ្មោះ [redacted] វណ្ណន
នារីរតន៍ បានចេញបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០២០ ឱ្យអតិថិជន និងបានចុះចូលក្នុងប្រព័ន្ធ
ពន្ធដាររួចហើយ។ ការលុបប្រតិបត្តិការទាំង ០២នេះ ខ្លួនបានដឹងថាជាប្រតិបត្តិការពាក់ព័ន្ធប្រាក់ពន្ធចំនួន ៦លានដុល្លារអា
មេរិកជាងរបស់ក្រុមហ៊ុន គ័ន ហ្គ័ង ខនស្ត្រាក់សិន ខេមបូឌា ឯ.ក ហើយការលុបនេះខាងធនាគារអត់ដឹងនោះទេ។ ក្រោយ
ពេលបញ្ចូលប្រាក់សងបានមួយដងហើយ ទើបខ្លួនប្រាប់ធនាគារកាណាឌីយ៉ា អ.ក។

៣៧-តាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងការទទួលស្គាល់របស់ជនជាប់ចោទ ដូចមានក្នុងសំអាងហេតុ
ចំណុច ៣៦ សបញ្ជាក់ឱ្យឃើញថា ពិតជាមានការលុបប្រតិបត្តិការដាក់ប្រាក់ពន្ធសងវិញចំនួន ០២ដង ដោយឈ្មោះ
[redacted] រចនា ហើយខាងធនាគារកាណាឌីយ៉ា អ.ក មិនបានដឹងពិតមែន លុះក្រោយមានការលុបប្រតិបត្តិការទាំង ០២នេះ
ហើយទើបខាងធនាគារកាណាឌីយ៉ា អ.ក ដឹងរឿងបាត់ប្រាក់ពន្ធរបស់អតិថិជនចំនួន ៦,១៦០,០០០$ (ប្រាំមួយលានដប់
ប្រាំមួយម៉ឺនដុល្លារអាមេរិក) ដែលការលុបប្រតិបត្តិការទាំង ០២លើករបស់ជនជាប់ចោទឈ្មោះ [redacted] រចនា នេះ បង្ហាញពី
ចេតនាទុច្ចរិតរបស់ជនជាប់ចោទក្នុងការចូលរួមជាមួយជនជាប់ចោទឈ្មោះ [redacted] វណ្ណនារីរតន៍ កិបកេងប្រាក់របស់
ធនាគារកាណាឌីយ៉ា អ.ក បិទបាំង បំបាត់ដាន មិនឱ្យធនាគារដឹងថាពួកគេបានយកប្រាក់ពន្ធនោះ ការដែលតុលាការយល់



Scanned with CamScanner

ឃើញដូចនេះដោយហេតុថា បើជនជាប់ចោទឈ្មោះ [redacted]ចនា មិនបានចូលរួមជាមួយជនជាប់ចោទឈ្មោះ ទៀង វណ្ណនារីរតន៍ ទេ ហេតុអ្វីពេលដឹងរឿងជនជាប់ចោទឈ្មោះ [redacted] **វណ្ណនារីរតន៍** យកប្រាក់ពន្ធរបស់អតិថិជន ម៉េចក៏មិនប្រាប់ទៅធនាគារភ្លាម បែរជាចូលរួមជួយសម្រួលជនជាប់ចោទឈ្មោះ [redacted] **វណ្ណនារីរតន៍** បញ្ចូលប្រាក់ពន្ធនោះទៅក្នុងប្រព័ន្ធពន្ធដារ និងធនាគារ ហើយថែមទាំងជួយលុបប្រតិបត្តិដែលជនជាប់ចោទឈ្មោះ [redacted] **វណ្ណនារីរតន៍** យកប្រាក់មកដាក់សង ដើម្បីកុំឱ្យធនាគារកាណាឌីយ៉ា អ.ក មានការសង្ស័យថាហេតុអ្វីក៏មានប្រតិបត្តិការដាក់ប្រាក់ពន្ធដល់ទៅ ០២ដងជាន់គ្នា។

៣៨-ការដែលប្រាក់ពន្ធចាប់ពី ៤០,០០០,០០០៛ (សែសិបលានរៀល) ឡើងទៅ ត្រូវឆ្លងកាត់ការត្រួតពិនិត្យពីជនជាប់ចោទឈ្មោះ [redacted] **រចនា** ទាំងប្រាក់ជាក់ស្តែង និងឯកសារពាក់ព័ន្ធ ហើយនិងត្រូវមានការអនុញ្ញាតពីជនជាប់ចោទឈ្មោះ [redacted] **រចនា** ទើបបេឡាករអាចចេញបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធជូនអតិថិជនបាន, ការដែលជនជាប់ចោទឈ្មោះ [redacted] **រចនា** បានដឹងច្បាស់ពេលវេលា និងសកម្មភាពដាក់ប្រាក់ពន្ធសងឱ្យអតិថិជនវិញ, ការដែលជនជាប់ចោទឈ្មោះ [redacted] **រចនា** ដឹងរឿងជនជាប់ចោទឈ្មោះ [redacted] **វណ្ណនារីរតន៍** យកប្រាក់ពន្ធ ហើយមិនប្រាប់ធនាគារកាណាឌីយ៉ា អ.ក ឱ្យដឹង ដោយលើកឡើងនូវមូលហេតុផ្សេងៗដែលមិនសមហេតុផល និងសកម្មភាពដែលជនជាប់ចោទឈ្មោះ [redacted] **រចនា** ព្យាយាមបិទបាំង បំបាត់ដានមិនឱ្យធនាគារកាណាឌីយ៉ា អ.ក ដឹងថាពួកគេយកប្រាក់ពន្ធរបស់អតិថិជនតាមរយៈការលុបប្រតិបត្តិការដាក់ប្រាក់ពន្ធសងឱ្យអតិថិជនចំនួន ០២លើក ដោយមិនឱ្យធនាគារកាណាឌីយ៉ា អ.ក ដឹងនោះ សបញ្ជាក់ឱ្យឃើញថា ជនជាប់ចោទឈ្មោះ [redacted] **រចនា** បានចូលរួមសហការណ៍ជាមួយជនជាប់ចោទឈ្មោះ [redacted] **វណ្ណនារីរតន៍** ក្នុងការគេបំបាត់ប្រាក់ពន្ធចំនួន ៦,១៦០,០០០$ (ប្រាំមួយលានដប់ប្រាំមួយម៉ឺនដុល្លាអាមេរិក) ដែលអតិថិជនក្រុមហ៊ុន គ័ន ហ្គ័ង ខនស្ត្រាក់សិន ខេមបូឌា ឯ.ក យកមកបង់តាមរយៈ ស្នាក់ការកណ្តាលធនាគារកាណាឌីយ៉ា អ.ក។

៣៩-ជនជាប់ចោទឈ្មោះ [redacted] **សុវណ្ណចរិយា** បានឆ្លើយថា ប្រតិបត្តិការដែលឈ្មោះ [redacted] **វណ្ណនារីរតន៍** បញ្ចូលប្រាក់ពន្ធចំនួន ៦,១៦០,០០០$ (ប្រាំមួយលានដប់ប្រាំមួយម៉ឺនដុល្លាអាមេរិក) សងឱ្យអតិថិជនតាមរយៈស្នាក់ការកណ្តាលធនាគារកាណាឌីយ៉ា អ.ក រហូតដល់ចំនួន ០៦លើក កាលពីថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០, ថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២០ និងថ្ងៃទី១៥ ខែមករា ឆ្នាំ២០២០ នោះ ខ្លួនមិនដឹង និងមិនបានអនុញ្ញាត (Authorize) ឬចុះហត្ថលេខានៅលើប័ណ្ណដាក់ប្រាក់ធនាគារទេ។ តុលាការមិនជឿលើចម្លើយបដិសេធរបស់ជនជាប់ចោទនេះទេ។ ផ្ទុយទៅវិញតាមតួនាទី និងទំនាក់ទំនងការងាររបស់ជនជាប់ចោទជាមួយជនជាប់ចោទឈ្មោះ [redacted] **វណ្ណនារីរតន៍** និងឈ្មោះ [redacted] **រចនា** ព្រមទាំងតាមចម្លើយរបស់ឈ្មោះ [redacted] **រចនា** ដែលបានឆ្លើយថាថ្ងៃទី២៨ ខែមករា ឆ្នាំ២០២០ ជាថ្ងៃដែលខាងអគ្គនាយកដ្ឋានពន្ធដារទូរស័ព្ទសួរនាំរឿងមិនឃើញបញ្ចូលប្រាក់ពន្ធរបស់ក្រុមហ៊ុន គ័ន ហ្គ័ង ខនស្ត្រាក់សិន ខេមបូឌា ឯ.ក ទៅក្នុងប្រព័ន្ធពន្ធដារនោះ ឈ្មោះ [redacted] **សុវណ្ណចរិយា** ក៏បានដឹងដែរ ហើយពេលឈ្មោះ [redacted] **វណ្ណនារីរតន៍** បញ្ចូលប្រាក់ពន្ធសងវិញឈ្មោះ [redacted] **សុវណ្ណចរិយា** ក៏បានដឹងនោះ សបញ្ជាក់ឱ្យឃើញថា ឈ្មោះ [redacted] **សុវណ្ណចរិយា** បានដឹងថា ថ្ងៃទី២៨ ខែមករា ឆ្នាំ២០២០ ខាងអគ្គនាយកដ្ឋានពន្ធដារទូរស័ព្ទសួរនាំរឿងមិនឃើញបញ្ចូលប្រាក់ពន្ធរបស់ក្រុមហ៊ុន គ័ន ហ្គ័ង ខនស្ត្រាក់សិន ខេមបូឌា



Scanned with CamScanner

ឯ.ក ទៅក្នុងប្រព័ន្ធពន្ធដារ និងដឹងថាឈ្មោះ [redacted] វណ្ណនារីរតន៍ បានបញ្ចូលប្រាក់ពន្ធសងចូលក្នុងប្រព័ន្ធពន្ធដារ និងធនាគារវិញ តែផ្ទុយលាក់បាំងមិនប្រាប់ធនាគារកាណាឌីយ៉ា អ.ក។

៤០-តាមតួនាទីដែលជនជាប់ចោទឈ្មោះ [redacted] សុវណ្ណចរិយា ជាអ្នកត្រួតពិនិត្យផ្ទាល់លើជនជាប់ចោទឈ្មោះ [redacted] វណ្ណនារីរតន៍ ហើយប្រាក់ពន្ធចាប់ពី ៨,០០០,០០០៛ (ប្រាំបីលានរៀល) ឡើងទៅ ត្រូវឆ្លងការការត្រួតពិនិត្យពីជនជាប់ចោទឈ្មោះ [redacted] សុវណ្ណចរិយា ទាំងប្រាក់ជាក់ស្តែង និងឯកសារពាក់ព័ន្ធ ហើយនិងត្រូវមានការអនុញ្ញាតពីជនជាប់ចោទ ឈ្មោះ [redacted] សុវណ្ណចរិយា ទើបបេឡាករអាចចេញបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធជូនអតិថិជនបាន និងការដែលជនជាប់ចោទឈ្មោះ [redacted] សុវណ្ណចរិយា បានដឹងថាខាងអគ្គនាយកដ្ឋានពន្ធដារទូរស័ព្ទសួរនាំរឿងមិនឃើញបញ្ចូលប្រាក់ពន្ធទៅក្នុងប្រព័ន្ធពន្ធដារ និងដឹងថាឈ្មោះ [redacted] វណ្ណនារីរតន៍ បានបញ្ចូលប្រាក់ពន្ធសងចូលក្នុងប្រព័ន្ធពន្ធដារ និងធនាគារវិញ តែផ្ទុយលាក់បាំងមិនប្រាប់ធនាគារកាណាឌីយ៉ា អ.ក សបញ្ជាក់ឱ្យឃើញថា ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណចរិយា បានចូលរួមសហការណ៍ជាមួយជនជាប់ចោទឈ្មោះ [redacted] វណ្ណនារីរតន៍ ក្នុងការកែបំបាត់ប្រាក់ពន្ធចំនួន ៦,១៦០,០០០$ (ប្រាំមួយលានដប់ប្រាំមួយម៉ឺនដុល្លាអាមេរិក) ដែលអតិថិជនក្រុមហ៊ុន ត័ន ហ្គ័ង ខនស្ត្រាក់សិន ខេមបូឌា ឯ.ក យកមកបង់តាមរយៈស្នាក់ការកណ្តាលធនាគារកាណាឌីយ៉ា អ.ក។

៤១-ជនជាប់ចោទឈ្មោះ [redacted] ស៊ីមន្ថា បានឆ្លើយថា ថ្ងៃទី១៨ ខែមករា ឆ្នាំ២០២០ ប្រពន្ធរបស់ខ្លួនឈ្មោះ [redacted] វណ្ណនារីរតន៍ បានទូរស័ព្ទហៅខ្លួនទៅយកនៅធនាគារកាណាឌីយ៉ា អ.ក ហើយជាទម្លាប់របស់ខ្លួន គឺទៅយកប្រពន្ធរហូត។ នៅពេលខ្លួនមកដល់ស្នាក់ការកណ្តាលធនាគារកាណាឌីយ៉ា អ.ក ប្រពន្ធរបស់ខ្លួនក៏បានឱ្យខ្លួនជួយយកអីវ៉ាន់ថង់ខ្មៅចំនួន ០៣ថង់ទៅជាន់ទី៥ ដោយប្រពន្ធខ្លួនមិនបានប្រាប់ថាអីវ៉ាន់អីទេ លុះពេលជិះឡានទៅផ្ទះទើបប្រពន្ធខ្លួនបានប្រាប់ថាប្រាក់បង់ពន្ធយកទៅប្តូរ តែមិនបានប្រាប់ថាចំនួនប៉ុន្មានទេ។ តុលាការមិនជឿលើចម្លើយរបស់ជនជាប់ចោទនេះទេ។

៤២-ការដែលជនជាប់ចោទឈ្មោះ [redacted] ស៊ីមន្ថា ជាប្តីរបស់ជនជាប់ចោទឈ្មោះ [redacted] វណ្ណនារីរតន៍ ហើយថែមទាំងជាអ្នកទៅជញ្ជូនថង់ខ្មៅទាំង ០៣ថង់ ពីជាន់ទី៥ នៃស្នាក់ការកណ្តាលអគារធនាគារកាណាឌីយ៉ា អ.ក ចុះមកជាន់ក្រោម ដោយប្រើជណ្តើរយន្តច្រកទ្វារខាងក្រោយដើម្បីគេចពីភ្នែកអ្នកដទៃយកទៅដាក់ក្នុងឡានរបស់គេនោះ សបញ្ជាក់ឱ្យឃើញថា ជនជាប់ចោទឈ្មោះ [redacted] ស៊ីមន្ថា បានដឹងជាមុន និងបានចូលរួមសហការណ៍ជាមួយប្រពន្ធរបស់គេឈ្មោះ [redacted] វណ្ណនារីរតន៍ ក្នុងការរៀបគម្រោងកែបំបាត់ប្រាក់ពន្ធចំនួន ៦,១៦០,០០០$ (ប្រាំមួយលានដប់ប្រាំមួយម៉ឺនដុល្លាអាមេរិក) ដែលអតិថិជនក្រុមហ៊ុន ត័ន ហ្គ័ង ខនស្ត្រាក់សិន ខេមបូឌា ឯ.ក យកមកបង់តាមរយៈស្នាក់ការកណ្តាលធនាគារកាណាឌីយ៉ា អ.ក។

៤៣-ជនជាប់ចោទឈ្មោះ [redacted] សុផាយ បានឆ្លើយថា ខ្លួនមិនបានចូលរួមកិបកេងប្រាក់ពន្ធ ហើយពេលឈ្មោះ ទៀង វណ្ណនារីរតន៍ យកប្រាក់ពន្ធនោះក៏ខ្លួនមិនដឹងដែរ។ នៅថ្ងៃដែលឈ្មោះ [redacted] វណ្ណនារីរតន៍ ត្រូវចាប់ខ្លួន ទើបខ្លួនបានដឹងថាគាត់យកប្រាក់ពន្ធរបស់ធនាគារ។ តុលាការមិនជឿលើចម្លើយរបស់ជនជាប់ចោទនេះទេ។

៤៤-ការដែលជនជាប់ចោទឈ្មោះ [redacted] សុផាយ ជាប្តីរបស់ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណចរិយា ដែលជាអ្នកចូលរួមសហការណ៍ជាមួយឈ្មោះ [redacted] វណ្ណនារីរតន៍ ក្នុងការកែបំបាត់ប្រាក់ពន្ធ ហើយថែមទាំងជនជាប់ចោទឈ្មោះ



Scanned with CamScanner

[redacted] សុភាយ ជាមន្ត្រីជាន់ខ្ពស់ផ្នែកព័ត៌មានវិទ្យា (IT) និងជាប្រធានក្រុមប្រព័ន្ធស្នូលធនាគារនៅស្នាក់ការកណ្តាលធនាគារកាណាឌីយ៉ា អ.ក តាំងពីឆ្នាំ២០១២ មានតួនាទីគ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាទាំងមូលក្នុងធនាគារគ្រប់ផ្នែកនោះ [redacted] ស៊ូ បញ្ជាក់ឱ្យឃើញថា ជនជាប់ចោទឈ្មោះ [redacted] សុភាយ បានដឹងជាមុន និងបានចូលរួមសហការណ៍ជាមួយប្រពន្ធរបស់គេ ឈ្មោះ [redacted] សុវណ្ណចរិយា និងជាមួយជនជាប់ចោទផ្សេងទៀតក្នុងការរៀបគម្រោងកែបំបាត់ប្រាក់ពន្ធចំនួន ៦,១៦០, ០០០$ (ប្រាំមួយលានដប់ប្រាំមួយម៉ឺនដុល្លាអាមេរិក) ដែលអតិថិជនក្រុមហ៊ុន គីន ហ្វ៊ុង ខនស្រ្តាក់សិន ខេមបូឌា ឯ.ក យកមកបង់តាមរយៈស្នាក់ការកណ្តាលធនាគារកាណាឌីយ៉ា អ.ក។

៤៥-កាលពីដើមខែមករា ឆ្នាំ២០២០ នៅស្នាក់ការកណ្តាលធនាគារកាណាឌីយ៉ា អ.ក ផ្លូវព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ពិតជាមានអង្គហេតុអំពើដែលជនជាប់ចោទឈ្មោះ [redacted] វឌ្ឍននារីរតន៍ ក្នុងតួនាទីជាបេឡាករផ្នែកទទួលប្រាក់ពន្ធនៅស្នាក់ការកណ្តាលធនាគារកាណាឌីយ៉ា អ.ក, ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណចរិយា ក្នុងតួនាទីជាមន្ត្រីជាន់ខ្ពស់ត្រួតពិនិត្យផ្នែកទទួលប្រាក់ពន្ធនៅស្នាក់ការកណ្តាលធនាគារកាណាឌីយ៉ា អ.ក, ជនជាប់ចោទឈ្មោះ [redacted] វចនា ក្នុងតួនាទីជាអនុប្រធានប្រតិបត្តិការស្នាក់ការកណ្តាលទទួលបន្ទុកផ្នែកទទួលប្រាក់ពន្ធ និងគម្រោងរដ្ឋាភិបាលនៅស្នាក់ការកណ្តាលធនាគារកាណាឌីយ៉ា អ.ក និងជនជាប់ចោទឈ្មោះ [redacted] សុភាយ ក្នុងតួនាទីជាមន្ត្រីជាន់ខ្ពស់ផ្នែកព័ត៌មានវិទ្យា (IT) និងជាប្រធានក្រុមប្រព័ន្ធស្នូលធនាគារ នៅស្នាក់ការកណ្តាលធនាគារកាណាឌីយ៉ា អ.ក បានសហការណ៍គ្នាកែបំបាត់ប្រាក់ពន្ធចំនួន ៦,១៦០,០០០$ (ប្រាំមួយលានដប់ប្រាំមួយម៉ឺនដុល្លាអាមេរិក) ដែលអតិថិជនក្រុមហ៊ុន គីន ហ្វ៊ុង ខនស្រ្តាក់សិន ខេមបូឌា ឯ.ក យកមកបង់តាមរយៈធនាគារកាណាឌីយ៉ា អ.ក យកទៅបម្រើផលប្រយោជន៍ផ្ទាល់ខ្លួនរបស់ពួកគេ ទាំងដែលពួកគេមានភារកិច្ចត្រូវប្រគល់ប្រាក់ពន្ធនោះឱ្យមកធនាគារកាណាឌីយ៉ា អ.ក វិញ ហើយសកម្មភាពរបស់ជនជាប់ចោទទាំង ០៤នាក់នេះ បានធ្វើឱ្យខូចប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ដោយធ្វើឱ្យដើមបណ្តឹងរដ្ឋប្បវេណីត្រូវទទួលខុសត្រូវប្រាក់ពន្ធនោះជាមួយអគ្គនាយកដ្ឋានពន្ធដារ។ ហើយសកម្មភាពរបស់ជនជាប់ចោទទាំង ០៤នាក់នេះ មានការជួយជ្រោមជ្រែង ជួយសម្រួលពីជនជាប់ចោទឈ្មោះ [redacted] បញ្ញាសុជាតា និងឈ្មោះ [redacted] ហៀង ក្នុងការយកប្រាក់នោះចេញទៅក្រៅធនាគារ ដោយជនជាប់ចោទទាំង ២នាក់ បានទទួលមកវិញនូវផលប្រយោជន៍ពីការជួយនេះផងដែរ និងមានការចូលរួមសហការណ៍ ជួយជ្រោមជ្រែង ជួយសម្រួល និងរួមគំនិតពីជនជាប់ចោទឈ្មោះ [redacted] ស៊ីមឆ្លា ដែលត្រូវជាប្តីរបស់ជនជាប់ចោទឈ្មោះ [redacted] វឌ្ឍននារីរតន៍។

៤៦-តាមបញ្ញត្តិមាត្រា ៣៩៣ នៃក្រមព្រហ្មទណ្ឌ បានចែងថា គ្រប់អភិបាល ឬអ្នកត្រួតពិនិត្យរបស់នីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលមូលនិធិ ឬបុគ្គលដែលត្រូវបានតុលាការជ្រើសតាំងឱ្យធ្វើជំនួសនូវកិច្ចការរបស់អ្នកទាំងនេះ ឬនិយោជិតដែលទទួលអាណត្តិពីនីតិបុគ្គលដែលប្រព្រឹត្តអំពើណាមួយដែលជាការរំលោភទំនុកចិត្ត ក្នុងគោលបំណងទទួលផលប្រយោជន៍ដល់ខ្លួន ឬតតិយជន ឬក្នុងគោលបំណងធ្វើឱ្យខូចខាតដល់នីតិបុគ្គល ហើយបានបណ្តាលឱ្យមានការខូចខាតទ្រព្យសម្បត្តិរបស់នីតិបុគ្គលនោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤,០០០,០០០៛ (បួនលានរៀល) ទៅ ១០,០០០,០០០៛ (ដប់លានរៀល) គឺជាបទ រំលោភលើទំនុកចិត្តពិសេសដោយអភិបាល ឬបុគ្គលផ្សេងទៀត។

៤៧-តាមបញ្ញត្តិមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ បានចែងថា ត្រូវចាត់ទុកជាអ្នកសមគំនិតក្នុងបទឧក្រិដ្ឋ ឬបទមជ្ឈិមចំពោះបុគ្គលណាដែលជួយសម្រួលដោយចេតនាដល់ការប៉ុនប៉ង ឬការសម្រេចបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះ ដោយផ្តល់ជំនួយការឧបត្ថម្ភរបស់ខ្លួន។ ៗ។



Scanned with CamScanner

៤៨-អំពើដែលជនជាប់ចោទឈ្មោះ [redacted] វឌ្ឍនារីរតន៍ ក្នុងតួនាទីជាបេឡាករផ្នែកទទួលប្រាក់ពន្ធនៅស្នាក់ការកណ្តាលធនាគារកាណាឌីយ៉ា អ.ក, ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណចរិយា ក្នុងតួនាទីជាមន្ត្រីជាន់ខ្ពស់ត្រួតពិនិត្យផ្នែកទទួលប្រាក់ពន្ធនៅស្នាក់ការកណ្តាលធនាគារកាណាឌីយ៉ា អ.ក, ជនជាប់ចោទឈ្មោះ [redacted] វចនា ក្នុងតួនាទីជាអនុប្រធានប្រតិបត្តិការស្នាក់ការកណ្តាលទទួលបន្ទុកផ្នែកទទួលប្រាក់ពន្ធ និងគម្រោងរដ្ឋាភិបាលនៅស្នាក់ការកណ្តាលធនាគារកាណាឌីយ៉ា អ.ក និងជនជាប់ចោទឈ្មោះ [redacted] សុមាយ ក្នុងតួនាទីជាមន្ត្រីជាន់ខ្ពស់ផ្នែកព័ត៌មានវិទ្យា (IT) និងជាប្រធានក្រុមប្រព័ន្ធស្នូលធនាគារនៅស្នាក់ការកណ្តាលធនាគារកាណាឌីយ៉ា អ.ក បានសហការគ្នាកែបំបាត់ប្រាក់ពន្ធចំនួន ៦,១៦០,០០០$ (ប្រាំមួយលានដប់ប្រាំមួយម៉ឺនដុល្លាអាមេរិក) ដែលអតិថិជនក្រុមហ៊ុន គ័ន ហ្គ័ង ខនស្រ្តាក់សិន ខេមបូឌា ឯ.ក យកមកបង់តាមរយៈធនាគារកាណាឌីយ៉ា អ.ក យកទៅបម្រើផលប្រយោជន៍ផ្ទាល់ខ្លួនរបស់ពួកគេ ទាំងដែលពួកគេមានភារកិច្ចត្រូវប្រគល់ប្រាក់ពន្ធនោះឱ្យមកធនាគារកាណាឌីយ៉ា អ.ក វិញ ហើយសកម្មភាពរបស់ជនជាប់ចោទទាំង ០៤នាក់នេះបានធ្វើឱ្យខូចប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ដោយធ្វើឱ្យដើមបណ្តឹងរដ្ឋប្បវេណីត្រូវទទួលខុសត្រូវប្រាក់ពន្ធនោះជាមួយអគ្គនាយកដ្ឋានពន្ធដារនោះ គឺមានធាតុផ្សំជាបទ រំលោភលើទំនុកចិត្តពិសេសដោយអភិបាល ឬបុគ្គលផ្សេងទៀត ដែលត្រូវផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩៣ នៃក្រមព្រហ្មទណ្ឌ។

៤៩-អំពើដែលជនជាប់ចោទឈ្មោះ [redacted]បញ្ញាសុជាតា មិនមែនជាបុគ្គលិករបស់ធនាគារកាណាឌីយ៉ា អ.ក ហើយបានជួយជ្រោមជ្រែង ជួយសម្រួលដល់ជនជាប់ចោទឈ្មោះ [redacted] វឌ្ឍនារីរតន៍ ដែលមានតួនាទីជាបេឡាករផ្នែកទទួលប្រាក់ពន្ធនៅស្នាក់ការកណ្តាលធនាគារកាណាឌីយ៉ា អ.ក ក្នុងការយកប្រាក់ពន្ធចំនួន ៦,១៦០,០០០$ (ប្រាំមួយលានដប់ប្រាំមួយម៉ឺនដុល្លាអាមេរិក) ដែលអតិថិជនក្រុមហ៊ុន គ័ន ហ្គ័ង ខនស្រ្តាក់សិន ខេមបូឌា ឯ.ក យកមកបង់តាមរយៈធនាគារកាណាឌីយ៉ា អ.ក ចេញទៅក្រៅធនាគារកាណាឌីយ៉ា អ.ក តាមរយៈការជួយជញ្ជូន ជួយមើល និងជួយយកប្រាក់នោះទៅប្តូរនោះ គឺមានធាតុផ្សំជាបទ សមគំនិតក្នុងអំពើរំលោភលើទំនុកចិត្តពិសេសដោយអភិបាល ឬបុគ្គលផ្សេងទៀត ដែលត្រូវផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៩ និងមាត្រា ៣៩៣ នៃក្រមព្រហ្មទណ្ឌ មិនមានធាតុផ្សំជាបទ រំលោភលើទំនុកចិត្តពិសេសដោយអភិបាល ឬបុគ្គលផ្សេងទៀត ដែលត្រូវផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩៣ នៃក្រមព្រហ្មទណ្ឌ ឡើយ។ គប្បីតុលាការកែប្រែបទចោទប្រកាន់លើជនជាប់ចោទរូបនេះ។

៥០-អំពើដែលជនជាប់ចោទឈ្មោះ [redacted] ស៊ីមន្ថា មិនមែនជាបុគ្គលិករបស់ធនាគារកាណាឌីយ៉ា អ.ក បានជួយជ្រោមជ្រែង ជួយសម្រួល និងរួមគំនិតជាមួយជនជាប់ចោទឈ្មោះ [redacted] វឌ្ឍនារីរតន៍ ដែលជាប្រពន្ធមានតួនាទីជាបេឡាករផ្នែកទទួលប្រាក់ពន្ធនៅស្នាក់ការកណ្តាលធនាគារកាណាឌីយ៉ា អ.ក ក្នុងការកែបំបាត់ប្រាក់ពន្ធចំនួន ៦,១៦០,០០០$ (ប្រាំមួយលានដប់ប្រាំមួយម៉ឺនដុល្លាអាមេរិក) ដែលអតិថិជនក្រុមហ៊ុន គ័ន ហ្គ័ង ខនស្រ្តាក់សិន ខេមបូឌា ឯ.ក យកមកបង់តាមរយៈធនាគារកាណាឌីយ៉ា អ.ក នោះ គឺមានធាតុផ្សំជាបទ សមគំនិតក្នុងអំពើរំលោភលើទំនុកចិត្តពិសេសដោយអភិបាល ឬបុគ្គលផ្សេងទៀត ដែលត្រូវផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៩ និងមាត្រា ៣៩៣ នៃក្រមព្រហ្មទណ្ឌ។

៥១-អំពើដែលជនជាប់ចោទឈ្មោះ [redacted] ហៀង ក្នុងនាមជាសន្តិសុខរបស់ធនាគារកាណាឌីយ៉ា អ.ក បានជួយសម្រួលដល់ជនជាប់ចោទឈ្មោះ [redacted] វឌ្ឍនារីរតន៍ ដែលមានតួនាទីជាបេឡាករផ្នែកទទួលប្រាក់ពន្ធនៅស្នាក់ការកណ្តាលធនាគារកាណាឌីយ៉ា អ.ក ក្នុងការយកប្រាក់ពន្ធចំនួន ៦,១៦០,០០០$ (ប្រាំមួយលានដប់ប្រាំមួយម៉ឺនដុល្លាអាមេរិក) ដែលអតិថិជនក្រុមហ៊ុន គ័ន ហ្គ័ង ខនស្រ្តាក់សិន ខេមបូឌា ឯ.ក យកមកបង់តាមរយៈធនាគារកាណាឌីយ៉ា អ.ក ចេញទៅក្រៅធនាគារកាណាឌីយ៉ា អ.ក តាមរយៈការជួយជញ្ជូនប្រាក់នោះ និងជួយជូនទៅប្តូរប្រាក់នោះ គឺមានធាតុផ្សំជា

Scanned with CamScanner

បទ សមគំនិតក្នុងអំពើរំលោភលើទំនុកចិត្តពិសេសដោយអភិបាល ឬបុគ្គលផ្សេងទៀត ដែលត្រូវផ្តន្ទាទោសតាមបញ្ញត្តិ មាត្រា ២៩ និងមាត្រា ៣៩៣ នៃក្រមព្រហ្មទណ្ឌ។

៥២-មានពិរុទ្ធភាពគ្រប់គ្រាន់ដើម្បីដាក់បន្ទុកលើឈ្មោះ [redacted] វណ្ណនារីរតន៍, ឈ្មោះ [redacted] រចនា, ឈ្មោះ [redacted] សុវណ្ណចរិយា និងឈ្មោះ [redacted] សុផាយ ពីបទ រំលោភលើទំនុកចិត្តពិសេសដោយអភិបាល ឬបុគ្គលផ្សេងទៀត ប្រព្រឹត្តនៅស្នាក់ការកណ្តាលធនាគារកាណាឌីយ៉ា អ.ក ផ្លូវព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីដើមខែមករា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩៣ នៃក្រមព្រហ្មទណ្ឌ។

៥៣-មានពិរុទ្ធភាពគ្រប់គ្រាន់ដើម្បីដាក់បន្ទុកលើឈ្មោះ [redacted] បញ្ញាសុជាតា, ឈ្មោះ [redacted] ស៊ីមន្ថា និងឈ្មោះ [redacted] ហៀង ពីបទ សមគំនិតក្នុងអំពើរំលោភលើទំនុកចិត្តពិសេសដោយអភិបាល ឬបុគ្គលផ្សេងទៀត ប្រព្រឹត្តនៅស្នាក់ការកណ្តាលធនាគារកាណាឌីយ៉ា អ.ក ផ្លូវព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីដើមខែមករា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៩ និងមាត្រា ៣៩៣ នៃក្រមព្រហ្មទណ្ឌ។

៥៤-នាពេលប្រព្រឹត្តបទល្មើស ជនជាប់ចោទទាំង ០៧នាក់ ជានីតិជន និងជាជនមានសមត្ថភាពពេញលេញក្នុងការយល់ដឹងពីអំពើរបស់ខ្លួន និងលទ្ធផលតាមផ្លូវច្បាប់ ដូច្នេះជនជាប់ចោទទាំង ០៧នាក់ អាចទទួលខុសត្រូវអំពើរបស់ខ្លួនតាមផ្លូវច្បាប់បាន។

៥៥-អំពើដែលជនជាប់ចោទទាំង ០៧នាក់ បានប្រព្រឹត្តធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់ របៀបរៀបរយសង្គម ប៉ះពាល់ដល់កិត្តិស័ព្ទ និងមុខជំនួញរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ ជនជាប់ចោទទាំង ០៧នាក់ មានគ្រួសារដែលត្រូវចិញ្ចឹមបីបាច់ និងថែរក្សា។ ជនជាប់ចោទខ្លះបានស្នើសុំឱ្យតុលាការជួយរកយុត្តិធម៌ និងមានជនជាប់ចោទខ្លះទៀតបានស្នើសុំឱ្យតុលាការលើកលែងចោទប្រកាន់។ គប្បីតុលាការលើកចំណុចទាំងអស់នេះមកពិចារណាក្នុងការសម្រេចសេចក្តី។

៥៦-អំពើដែលជនជាប់ចោទឈ្មោះ [redacted] ហៀង បានជួយសម្រួលដល់ការប្រព្រឹត្តបទល្មើសរបស់ជនជាប់ចោទផ្សេងទៀតក្នុងរូបភាពមួយមិនសកម្មដូចជនជាប់ចោទឈ្មោះ [redacted] បញ្ញាសុជាតា និងឈ្មោះ [redacted] ស៊ីមន្ថា និងបានមកវិញនៅផលប្រយោជន៍បន្តិចបន្តួចនោះ គប្បីតុលាការពិចារណាលើការផ្តន្ទាទោសចំពោះជនជាប់ចោទរូបនេះក្នុងកម្រិតមួយស្រាលជាងជនជាប់ចោទផ្សេងទៀត។

៥៧-ជនជាប់ចោទបានបញ្ជាក់ថា ខ្លួនបានសងប្រាក់ពន្ធឱ្យធនាគារណាឌីយ៉ា អ.ក ចំនួន ៦,១៦០,០០០$ (ប្រាំមួយលានដប់ប្រាំមួយម៉ឺនដុល្លាអាមេរិក) ដោយបានដាក់ជាមូលប្បទានប័ត្រប្រាក់រៀលបញ្ចូលទៅក្នុងគណនីរបស់ពន្ធដារវិញអស់ហើយ។ ចំណុចនេះដើមបណ្តឹងរដ្ឋប្បវេណីក៏បានបញ្ជាក់ថា ជនជាប់ចោទបានសងប្រាក់ពន្ធដែលពួកគេយកចំនួន ៦,១៦០,០០០$ (ប្រាំមួយលានដប់ប្រាំមួយម៉ឺនដុល្លាអាមេរិក) សងមកធនាគារកាណាឌីយ៉ា អ.ក គ្រប់ចំនួនហើយ។ តាមចម្លើយរបស់អ្នកទាំង ០២នេះ សបញ្ជាក់ឱ្យឃើញថា ជនជាប់ចោទទាំងអស់បានសងប្រាក់ពន្ធចំនួន ៦,១៦០,០០០$ (ប្រាំមួយលានដប់ប្រាំមួយម៉ឺនដុល្លាអាមេរិក) មកធនាគារកាណាឌីយ៉ា អ.ក វិញគ្រប់ចំនួនអស់ហើយ។

៥៨-ដើមបណ្តឹងរដ្ឋប្បវេណី បានប្តឹងទាមទារឱ្យជនជាប់ចោទទាំងអស់រួមគ្នាសងសំណងជម្ងឺចិត្តជាប្រាក់ចំនួន ៥០០,០០០$ (ហាសិបម៉ឺនដុល្លាអាមេរិក) មកឱ្យខ្លួន ដោយលើកនូវសំអាងហេតុផ្សេងៗនោះ ឃើញថាការទាមទារនេះស្របតាមមាត្រា ១៣ និង ១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ពីព្រោះតែដើមបណ្តឹងរដ្ឋប្បវេណីជាអ្នកមានភារកិច្ចទទួលខុសត្រូវក្នុងការសងប្រាក់ពន្ធដែលបាត់នោះទៅអគ្គនាយកដ្ឋានពន្ធដារ ហេតុនេះយោងតាមមាត្រា ៣៥៥ នៃក្រមនីតិវិធី



Scanned with CamScanner

ព្រហ្មទណ្ឌ តម្បីតុលាការសម្រេចឱ្យដោយផ្អែកតាមការខូចខាត និងផលប៉ះពាល់ជាក់ស្តែងដែលដើមបណ្តឹងរដ្ឋប្បវេណីបានទទួលរង។

៥៩-វត្ថុតាងចាប់យកមាន៖

ក-រថយន្តម៉ាក TOYOTA HIGHTLANDER ពណ៌ស ស៊េរីឆ្នាំ២០០៩ ពាក់ផ្លាកលេខ ភ្នំពេញ ២BF-៣៣៨៣ ចំនួន ០១គ្រឿង និងទូរស័ព្ទដៃម៉ាក NOKIA (ចុចពិល) ពណ៌ខ្មៅ (មិនដំណើរការ) ចំនួន ០១គ្រឿង ជាឧបករណ៍ដែលជនជាប់ចោទប្រើប្រាស់ធ្វើជាមធ្យោបាយក្នុងការប្រព្រឹត្តបទល្មើស គប្បីរឹបអូសជាសម្បត្តិរដ្ឋ យោងតាមមាត្រា ៦២ និងមាត្រា ៦៣ នៃក្រមព្រហ្មទណ្ឌ។

ខ-បន្ទះស៊ីមចំនួន ០១បន្ទះ ជាវត្ថុដែលមិនពាក់ព័ន្ធនិងការប្រព្រឹត្តបទល្មើសរបស់ជនជាប់ចោទ និងលែងមានភាពចាំបាច់ដែលត្រូវរក្សាទុកក្នុងការស្វែងរកការពិតទៀតហើយ គប្បីប្រគល់ឱ្យម្ចាស់ដើមយកទៅប្រើប្រាស់ជាកម្មសិទ្ធិវិញ យោងតាមបញ្ញត្តិមាត្រា ៣៥៤ នៃក្រមព្រហ្មទណ្ឌ។

៦០-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋាន សុំតម្កល់បទចោទប្រកាន់ និងស្នើសុំឱ្យតុលាការសម្រេចវិនិច្ឆ័យលើជនជាប់ចោទតាមកំណត់ច្បាប់ ដោយលើកនូវសំអាងផ្សេងៗនោះ។ ការស្នើសុំនេះមានសំអាងគ្រប់គ្រាន់ ដែលអាចឱ្យតុលាការលើកយកមកពិចារណាក្នុងការសម្រេចសេចក្តី។

៦១-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] វឌ្ឍនធារីរតន៍ និងឈ្មោះ [redacted]ស៊ីមន្ថា បានធ្វើសេចក្តីសន្និដ្ឋាន សុំឱ្យជនជាប់ចោទឈ្មោះ[redacted]វឌ្ឍនធារីរតន៍ និងឈ្មោះ [redacted]ស៊ីមន្ថា រួចខ្លួនពីបទចោទ ដោយលើកនូវសំអាងផ្សេងៗ។ ការស្នើសុំនេះមិនមានសំអាងគ្រប់គ្រាន់ ដែលអាចឱ្យតុលាការលើកយកមកពិចារណាក្នុងការសម្រេចសេចក្តី។

៦២-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ហៀង បានធ្វើសេចក្តីសន្និដ្ឋាន សុំឱ្យជនជាប់ចោទឈ្មោះ [redacted] ហៀង រួចខ្លួនពីបទចោទ ដោយលើកនូវសំអាងផ្សេងៗ។ ការស្នើសុំនេះមិនមានសំអាងគ្រប់គ្រាន់ ដែលអាចឱ្យតុលាការលើកយកមកពិចារណាក្នុងការសម្រេចសេចក្តី។

៦៣-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ[redacted]បញ្ញាសុជាតា បានធ្វើសេចក្តីសន្និដ្ឋាន សុំឱ្យជនជាប់ចោទឈ្មោះ នុត បញ្ញាសុជាតា រួចខ្លួនពីបទចោទ ដោយលើកនូវសំអាងផ្សេងៗ។ ការស្នើសុំនេះមិនមានសំអាងគ្រប់គ្រាន់ ដែលអាចឱ្យតុលាការលើកយកមកពិចារណាក្នុងការសម្រេចសេចក្តី។

៦៤-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] រចនា បានធ្វើសេចក្តីសន្និដ្ឋាន សុំឱ្យជនជាប់ចោទឈ្មោះ [redacted] រចនា រួចខ្លួនពីបទចោទ ដោយលើកនូវសំអាងផ្សេងៗ។ ការស្នើសុំនេះមិនមានសំអាងគ្រប់គ្រាន់ ដែលអាចឱ្យតុលាការលើកយកមកពិចារណាក្នុងការសម្រេចសេចក្តី។

៦៥-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ[redacted]សុរមាយ និងឈ្មោះ [redacted] សុវណ្ណចរិយា បានធ្វើសេចក្តីសន្និដ្ឋាន សុំឱ្យជនជាប់ចោទឈ្មោះ[redacted]សុរមាយ និងឈ្មោះ[redacted]សុវណ្ណចរិយា រួចខ្លួនពីបទចោទ ដោយលើកនូវសំអាងផ្សេងៗ។ ការស្នើសុំនេះមិនមានសំអាងគ្រប់គ្រាន់ ដែលអាចឱ្យតុលាការលើកយកមកពិចារណាក្នុងការសម្រេចសេចក្តី។

## ហេតុដូច្នេះសម្រេច

១-តែប្រែបទចោទប្រកាន់លើឈ្មោះ[redacted]បញ្ញាសុជាតា ភេទស្រី អាយុ ៣១ឆ្នាំ ជនជាតិខ្មែរ ពីបទ រំលោភលើទំនុកចិត្តពិសេសដោយអភិបាល ឬបុគ្គលផ្សេងទៀត ប្រព្រឹត្តនៅស្នាក់ការកណ្តាលធនាគារកាណាឌីយ៉ា អ.គ ផ្លូវព្រះមុនីវង្ស ៦៣



Scanned with CamScanner

សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីដើមខែមករា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩៣ នៃក្រមព្រហ្មទណ្ឌ មកជាបទ សមគំនិតក្នុងអំពើរំលោភលើទំនុកចិត្តពិសេសដោយអភិបាល ឬបុគ្គលផ្សេងទៀត ប្រព្រឹត្តនៅស្នាក់ការកណ្តាលធនាគារកាណាឌីយ៉ា អ.ក ផ្លូវព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីដើមខែមករា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៩ និងមាត្រា ៣៩៣ នៃក្រមព្រហ្មទណ្ឌ។

២-ផ្តន្ទាទោស៖

ក-ឈ្មោះ [redacted] វឌ្ឍនានារីរតន៍ ភេទស្រី អាយុ ៣១ឆ្នាំ ជនជាតិខ្មែរ

ខ-ឈ្មោះ [redacted] រចនា ភេទស្រី អាយុ ៣៩ឆ្នាំ ជនជាតិខ្មែរ

គ-ឈ្មោះ [redacted] សុវណ្ណចរិយា ភេទស្រី អាយុ ៣០ឆ្នាំ ជនជាតិខ្មែរ

ឃ-ឈ្មោះ [redacted] សុអាយ ភេទប្រុស អាយុ ៣១ឆ្នាំ ជនជាតិខ្មែរ

ដាក់ទោសពន្ធនាគារក្នុងម្នាក់ៗកំណត់រយៈពេល ០៤ឆ្នាំ (បួនឆ្នាំ) ពីបទ រំលោភលើទំនុកចិត្តពិសេសដោយអភិបាល ឬបុគ្គលផ្សេងទៀត ប្រព្រឹត្តនៅស្នាក់ការកណ្តាលធនាគារកាណាឌីយ៉ា អ.ក ផ្លូវព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីដើមខែមករា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩៣ នៃក្រមព្រហ្មទណ្ឌ។

៣-ផ្តន្ទាទោស៖

ក-ឈ្មោះ [redacted] បញ្ញាសុជាតា ភេទស្រី អាយុ ៣១ឆ្នាំ ជនជាតិខ្មែរ

ខ-ឈ្មោះ [redacted] ស៊ីមន្ថា ភេទប្រុស អាយុ ៣៩ឆ្នាំ ជនជាតិខ្មែរ

ដាក់ទោសពន្ធនាគារក្នុងម្នាក់ៗកំណត់រយៈពេល ០៤ឆ្នាំ (បួនឆ្នាំ) ពីបទ សមគំនិតក្នុងអំពើរំលោភលើទំនុកចិត្តពិសេសដោយអភិបាល ឬបុគ្គលផ្សេងទៀត ប្រព្រឹត្តនៅស្នាក់ការកណ្តាលធនាគារកាណាឌីយ៉ា អ.ក ផ្លូវព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីដើមខែមករា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែរមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៩ និងមាត្រា ៣៩៣ នៃក្រមព្រហ្មទណ្ឌ។

៤-ផ្តន្ទាទោសឈ្មោះ [redacted] ហៀង ភេទប្រុស អាយុ ៤៣ឆ្នាំ ជនជាតិខ្មែរ ដាក់ទោសពន្ធនាគារកំណត់រយៈពេល ០៣ឆ្នាំ និង ០៦ខែ (បីឆ្នាំ និងប្រាំមួយខែ) ពីបទ សមគំនិតក្នុងអំពើរំលោភលើទំនុកចិត្តពិសេសដោយអភិបាល ឬបុគ្គលផ្សេងទៀត ប្រព្រឹត្តនៅស្នាក់ការកណ្តាលធនាគារកាណាឌីយ៉ា អ.ក ផ្លូវព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីដើមខែមករា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៩ និងមាត្រា ៣៩៣ នៃក្រមព្រហ្មទណ្ឌ។

៥-ឱ្យឈ្មោះ [redacted] វឌ្ឍនានារីរតន៍, ឈ្មោះ [redacted] ចនា, ឈ្មោះ [redacted] សុវណ្ណចរិយា, ឈ្មោះ [redacted] សុអាយ, ឈ្មោះ [redacted] បញ្ញាសុជាតា, ឈ្មោះ [redacted] ស៊ីមន្ថា និងឈ្មោះ [redacted] ហៀង រួមគ្នាសងសំណងជម្ងឺចិត្តជាប្រាក់ចំនួន ៥០០,០០០,០០០៛ (ប្រាំរយលានរៀល) ឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណី ធនាគារកាណាឌីយ៉ា អ.ក ដែលមានលោក [redacted] អារស៍ ជាតំណាងតាមមាត្រា ៣៥៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៦-វត្ថុតាងចាប់យកមាន៖



Scanned with CamScanner

ក-រឹបអូសជាសម្បត្តិរដ្ឋនូវ៖

ក-១.រថយន្តម៉ាក TOYOTA HIGHTLANDER ពណ៌ស ស៊េរីឆ្នាំ២០០៩ ពាក់ផ្លាកលេខ ភ្នំពេញ ២BF-៣៣៨៣ ចំនួន ០១គ្រឿង។

ក-២. ទូរស័ព្ទដៃម៉ាក NOKIA (ចុចពិល) ពណ៌ខ្មៅ (មិនដំណើរការ) ចំនួន ០១គ្រឿង។

ខ-ប្រគល់ឱ្យម្ចាស់ដើមយកទៅប្រើប្រាស់ជាកម្មសិទ្ធិនូវ៖ បន្ទះស៊ីមចំនួន ០១បន្ទះ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២០, ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២០ និងថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២០ ចំពោះមុខជនជាប់ចោទឈ្មោះ[redacted]នារីរតន៍, ឈ្មោះ [redacted]រចនា, ឈ្មោះ [redacted] សុវណ្ណចរិយា, ឈ្មោះ [redacted] សុអាយ, ឈ្មោះ [redacted] បញ្ញាសុជាតា, ឈ្មោះ [redacted] ស៊ីមន្ថា និងឈ្មោះ[redacted]ហៀង ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈនៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២១។

ភាគីមានសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងរយៈពេលដែលច្បាប់កំណត់។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមជំនុំជម្រះ** |
|---|---|
| ហត្ថលេខា និងត្រា: [redacted] | ហត្ថលេខា និងត្រា: [redacted] |

---

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃអង្គារ ២រោច ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២១

| បានឃើញ<br>ចៅក្រមជំនុំជម្រះ | ក្រឡាបញ្ជី |
|---|---|
| [redacted] | [redacted] |



Scanned with CamScanner